ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ដំណើររបស់កម្ពុជាឆ្ពោះទៅកាន់ការផ្សះផ្សាដែលពោរពេញដោយការតស៊ូ និងភាពឈឺចាប់
- ហេតុអ្វីប្រវត្តិសាស្ត្រយោធាកម្ពុជាមានសារសំខាន់ឥតពីរចំពោះសន្តិសុខជាតិ និងសន្តិសុខតំបន់អាស៊ាន

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា
លេខ២៦២ ខែតុលា ឆ្នាំ២០២១

## ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៦២ ខែតុលា ឆ្នាំ២០២១

## មាតិកា

### សំបុត្រ


◆ ដំណើររបស់កម្ពុជាឆ្ពោះទៅកាន់ការផ្សះផ្សា .. ១

◆ ហេតុអ្វីប្រវត្តិសាស្ត្រយោធាកម្ពុជាមាន....... ៦


### ផ្នែកឯកសារ


◆ អ៊ូ សៀង ៖ អនុប្រធានសេដ្ឋកិច្ច........... ១០


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


◆ គង់ សារិន ៖ កងចល័តនារីក្នុងរបប ..... ១៤

◆ សួន ពិន ៖ គ្រូថ្នាំបុរាណក្នុងរបបខ្មែរ....... ១៨

◆ អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តស្វាយរៀង នាំយក កញ្ចប់អនុស្សាវរីយ៍ជូនអ្នករស់រាន....... ២០

◆ អ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តកំពង់ឆ្នាំង ចែកកញ្ចប់ អនុស្សាវរីយ៍ជូនអ្នករស់រាន............. ២២

◆ នួន មិន ៖ ជាប់ទោសនៅទួលស្រែញ.... ២៤

◆ ប៉ូយ សុត ៖ អនុប្រធានកងចល័តភូមិរំចេក .. ២៨

◆ ពិធីបង្សុកូលថ្វាយព្រះរាជកុសលដល់សម្តេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ..... ៣១

◆ មាស ពៅ ៖ នារីរោងចក្រនៅក្នុងរបប ..៣៣

◆ សំ ហន ៖ អតីតយោធាខ្មែរក្រហម....... ៣៦

◆ សំណង់ចេតិយ៍តម្កល់អដ្ឋិធាតុជនរងគ្រោះ .. ៣៩


### ផ្នែកច្បាប់


◆ សាលក្រមសំណុំរឿង០០២/០២ .........៤៣


### ផ្នែកវេទិកាសាធារណៈ


◆ រឿងរ៉ាវសង្វែបរបស់ប្រជាជននៅស្រុក អន្លង់វែងតាមរយៈវេទិកា................ ៥២


### ផ្នែកស្រាវជ្រាវរកការពិតសារ


◆ «ទួលពិយាដ» មីគ្នោត មេគោអង្គការ ....៦០




ឡុង មុនីចិន្តា
(សៀវភៅទួលពិយាដ/ ឡុង វង្សសមិទ្ធ)


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** ឆាំង យុ, ដារ៉ារដ្ឋ មេត្តា, សុខ ចន្ទ្រា, កែវ ស្រីណុច, សោម ប៊ុនថន, ផេង ពង្សរ៉ាស៊ី, ហ៊ាន ពិសី, មេក វិន, សុភ័ក្ត្រ ភាណា, សួត វិចិត្រ, ស៊ាង ចិន្តា, យី សុឃី និង ឡុង វង្សសមិទ្ធ

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដារ៉ារដ្ឋ មេត្តា **អ្នកបកប្រែ៖** លីម អ៊ុកភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** អ៊ុន សុដារី **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសុនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង


Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ដំណើររបស់កម្ពុជាឆ្ពោះទៅកាន់ការផ្សះផ្សា ដែលពោរពេញដោយការតស៊ូ និងភាពឈឺចាប់

ឆាំង យុ



សម្ដេចព្រះ នរោត្តម សីហនុ, លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងអ្នកម្នាង ម៉ូនិក សីហនុ ក្នុងជំនួបលើកដំបូងនៅឯ ហ្វែរអង់តាដឺណ័រ (សង្កាត់មួយនៅក្រៅទីក្រុងប៉ារីស) នាឆ្នាំ១៩៨៧។
រូបថត៖ ហូលីយ៉ូ អេ. ហែលគ្រេស/បណ្ណាល័យសម្ដេចម៉ែ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អត្ថបទមួយនេះ មានគោលបំណងផ្ដល់នូវព័ត៌មានមួយចំនួនស្ដីអំពីដំណើរដ៏វែងអន្លាយរបស់កម្ពុជា ដើម្បីចាកផុតពីអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាល។ មានហេតុផលជាច្រើនដែលដំណើរនេះមានសារសំខាន់ចំពោះពិភពលោក ក្នុងចំណោមនោះ គឺមេរៀនចេញពីដំណើររបស់កម្ពុជាផ្ដល់ទៅកាន់សង្គមក្រោយជម្លោះដទៃផ្សេងទៀត។ ទោះបីជាគ្មានការឆ្លើយតបត្រឹមត្រូវ ប្រយុទ្ធសាស្ត្រពារាំងចំពោះអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលជាលក្ខណៈសកលមួយយ៉ាងណាក្ដី យើងជឿជាក់ថា ប្រាកដជាមានដំណើរទូទៅមួយ ដែលសង្គមក្រោយជម្លោះអាចប្រើប្រាស់ ដើម្បីបញ្ចៀសការរាតត្បាតនៃអំពើហិង្សា។

នៅរវាងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាស្ថិតក្រោមការគ្រប់គ្រងរបស់ចលនាកុម្មុយនីស្ដខ្មែរក្រហម ដែលបានបង្កភាពភ័យខ្លាចហួសពីការស្មាន និងប្រព្រឹត្តនូវការសម្លាប់រង្គាល។ គោលដៅនៃរបបខ្មែរក្រហម គឺបំផ្លាញប្រទេសជាតិ និងចាប់ផ្ដើម "ឆ្នាំសូន្យ" របស់ខ្លួន ដែលត្រូវបានពិភពលោកស្គាល់ថា "វាលពិឃាដ"។ នៅក្នុងអំឡុងរយៈពេលតិចជាងបួនឆ្នាំ

ប៉ុណ្ណោះ របបខ្មែរក្រហម បានធ្វើឲ្យប្រជាជនខ្មែរប្រមាណជាងពីរលាននាក់ស្លាប់បាត់បង់ជីវិត។

ក្រោយពេលដែលរបបខ្មែរក្រហមបានផុតរលត់ទៅ បទពិសោធន៍របស់យើងបង្ហាញថា រាល់សង្គមក្រោយជម្លោះ ទាំងអស់ត្រូវតែបញ្ចៀសការរាតត្បាតនៃអំពើហិង្សា តាមរយៈការបង្កើតឲ្យមានសន្តិភាពជាជំហានដំបូង។ ការពិត យុត្តិធម៌ ការផ្សះផ្សា និងការអប់រំ មិនអាចព្យាបាលសង្គមជាតិឲ្យជាសះស្បើយបានឡើយ ប្រសិនបើគ្មានវត្តមាន "សន្តិភាព"។ ជួនកាលសន្តិភាពអាចសម្រេចទៅបានតាមរយៈអន្តរាគមន៍យោធា។ នេះគឺជាករណីជាក់ស្តែងក្នុងប្រទេសកម្ពុជា។ ចំពោះប្រទេសកម្ពុជា របបខ្មែរក្រហមដួលរលំទៅនៅក្នុងឆ្នាំ១៩៧៩ ដោយសារតែកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាជាមួយនឹងអន្តរាគមន៍របស់កងទ័ពវៀតណាម។

ទោះបីជាខ្មែរក្រហមត្រូវបណ្តេញចេញពីអំណាចទៅហើយក្តី ប្រទេសកម្ពុជានៅតែត្រូវបន្តយាយីដោយជម្លោះ អស្ថិរភាព និងភាពខ្ទេចខ្ទាំអស់រយៈកាលជាងពីរទសវត្សរ៍បន្តទៀត។ បន្ទាប់ពីឆ្នាំ១៩៧៩ កងកម្លាំងខ្មែរក្រហម នៅតែបន្តសង្គ្រាមជាមួយរដ្ឋាភិបាលកម្ពុជា។ នៅពេលដែលកងកម្លាំងខ្មែរក្រហមត្រូវបំបែកខ្ចាត់ខ្ចាយនិងសមាហរណកម្ម ទាំងស្រុង ទើបប្រទេសកម្ពុជាអាចចាប់ផ្តើមដំណើរការឈានទៅសម្រេចយុត្តិធម៌របស់ខ្លួនបាន។ កិច្ចខិតខំប្រឹងប្រែងដើម្បីសម្រេចយុត្តិធម៌ និងការផ្សះផ្សាជាច្រើនបានប្រព្រឹត្តទៅនៅក្នុងអំឡុងពេលសង្គ្រាម។ ជាឧទាហរណ៍ នៅក្នុងឆ្នាំ១៩៧៩ កម្ពុជាបានបង្កើត "តុលាការប្រជាជនបដិវត្តន៍" មួយដែល "កាត់ទោស" មេដឹកនាំខ្មែរក្រហមដោយកំបាំងមុខ។ ខណៈពេលដែលកិច្ចខិតខំប្រឹងប្រែងដើម្បីវិនិច្ឆ័យទោសចំពោះរបបខ្មែរក្រហម គឺជាទង្វើសមហេតុសមផល កិច្ចខិតខំប្រឹងប្រែងនេះមិនបានឈរលើបទដ្ឋានយុត្តិធម៌ដែលទទួលស្គាល់ជាផ្លូវការអន្តរជាតិទេ ហើយកិច្ចខិតខំប្រឹងប្រែងនេះក៏មិនអាចប្រព្រឹត្តទៅបានដែរ ពីព្រោះថាក្នុងខណៈនោះប្រទេសជាតិកំពុងស្ថិតនៅក្នុងសង្គ្រាមនៅឡើយ។

កិច្ចខិតខំប្រឹងប្រែងឈានទៅសម្រេចយុត្តិធម៌ពិតប្រាកដមួយទៀត បានប្រព្រឹត្តទៅតាមរយៈការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលត្រូវបានស្គាល់ថា សាលាក្តីខ្មែរក្រហម នៅដើមទសវត្សរ៍ឆ្នាំ២០០០។ វត្តមាននៃសាលាក្តីខ្មែរក្រហម ដែលជាតុលាការរួមគ្នារវាងអង្គការសហប្រជាជាតិនិងកម្ពុជា គឺជាជំហានដ៏ពិសេសសម្រាប់ប្រជាជនកម្ពុជា ពីព្រោះតុលាការនេះគឺជាកិច្ចខិតខំប្រឹងប្រែងយ៉ាងពិតប្រាកដ ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនៃរបបខ្មែរក្រហម។ ទោះបីជាយ៉ាងណាក្តី យើងចាំបាច់ត្រូវចងចាំថាដំណើរការឈានទៅសម្រេចយុត្តិធម៌ ត្រូវតែចាប់ផ្តើមចេញពីដំណើរស្វែងរកការពិតដ៏ស្មោះត្រង់មួយ។

មជ្ឈមណ្ឌលឯកសារកម្ពុជា នៅដើមដំបូងត្រូវបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៥ ជាការិយាល័យមួយរបស់សាកលវិទ្យាល័យយ៉េល បន្ទាប់ពីសភាសហរដ្ឋអាមេរិកអនុម័តឲ្យមានច្បាប់ស្តីពីយុត្តិធម៌សម្រាប់អំពើប្រល័យពូជសាសន៍ ដើម្បីធ្វើការសិក្សាស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា។ ចាប់តាំងពីឆ្នាំ១៩៩៧មក មជ្ឈមណ្ឌលឯកសារកម្ពុជា ដើរតួនាទីជាស្ថាប័នសង្គមស៊ីវិលឯករាជ្យមិនលម្អៀង ដែលផ្តោតទៅលើការចងចាំ យុត្តិធម៌ និងការផ្សះផ្សា។ បេសកកម្មស្នូលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺស្រាវជ្រាវ កត់ត្រា និងប្រមែប្រមូលឯកសារ និងវត្ថុតាងផ្សេងៗ ដែលបន្សល់ទុកពីរបបខ្មែរក្រហម ដើម្បីគាំទ្រដល់យុត្តិធម៌និងការចងចាំ។ មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាបណ្ណសារដ្ឋាននៃឯកសារទាក់ទងនឹងរបបខ្មែរក្រហមធំជាងគេបង្អស់នៅក្នុងតំបន់។ មជ្ឈមណ្ឌលឯកសារកម្ពុជា ដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញដល់ដំណើរការស្វែងរកការពិត និងឈានទៅសម្រេចយុត្តិធម៌ ដែលមិនមែនតែនៅក្នុងបន្ទប់សវនាការប៉ុណ្ណោះទេ ប៉ុន្តែគឺនៅទូទាំងប្រទេសកម្ពុជា។

យុត្តិធម៌មិនមែនមានសណ្ឋានតែមួយបែបនោះឡើយ។ យុត្តិធម៌អាចសម្រេចបានតាមរយៈការកាត់ទោសឧក្រិដ្ឋជន និងផ្តន្ទាទោសលើបុគ្គលទាំងឡាយដែលទទួលខុសត្រូវចំពោះការប្រព្រឹត្តអំពើប្រល័យពូជសាសន៍និងការសម្លាប់រង្គាល ប៉ុន្តែយុត្តិធម៌អាចនឹងរឹតតែប្រសើរ នៅពេលដែលជនរងគ្រោះមួយរូប

រូបពីឆ្វេងទៅស្តាំ៖ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ ទា បាញ់, តំណាងពិសេសអគ្គលេខាធិការអង្គការសហប្រជាជាតិ យ៉ាសុស៊ី អាកាស៊ី, ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះប្រធានឧត្តមក្រុមប្រឹក្សាជាតិ ចូលរួមពិធីទទួលស្វាគមន៍ការវិលត្រឡប់របស់ជនភៀសខ្លួនកម្ពុជា នៅទីក្រុងភ្នំពេញ នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩២។
រូបថត៖ Pernaca Sudhakaran
ប្រភព ៖ Benny Widyono





សម្តេចព្រះ នរោត្តម សីហនុ និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន អមដំណើរដោយលោកជំទាវ ប៊ុន រ៉ានី ហ៊ុន សែន បិទបញ្ចប់ជំនួបលើកដំបូងក្នុងឆ្នាំ១៩៨៧ ប្រកបដោយជោគជ័យ។
រូបថត៖ ហូលីយ៉ូ អេ. ហែលគ្រេស/បណ្ណាល័យសម្តេចម៉ែ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បានរៀបរាប់អំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងតុលាការ។ យុត្តិធម៌អាចសម្រេចបានតាមរយៈការចងក្រងនូវអ្វីដែលបានកើតឡើង និងមូលហេតុដែលហេតុការណ៍នោះកើតឡើង។ យុត្តិធម៌អាចលេចជារូបរាងឡើងនៅពេលដែលសាច់រឿងរបស់អ្នករស់រានមានជីវិតនានាត្រូវបានរៀបរាប់ម្តងទៀតនៅក្នុងសៀវភៅប្រវត្តិសាស្ត្រ

និងនៅក្នុងថ្នាក់រៀន។ យុត្តិធម៌អាចសម្រេចបានតាមរយៈការសះស្បើយផ្លូវចិត្ត ក៏ដូចជាការថែទាំដល់អ្នករស់រានមានជីវិតតាមរយៈតំហែទាំវេជ្ជសាស្រ្ត សេវាកម្មសុខភាពនិងប្រព័ន្ធគាំពារសង្គម។ តាមរយៈការលើកឡើងទាំងអស់នេះ យុត្តិធម៌គឺមានពហុសណ្ឋាន និងគឺជាផ្នែកមួយនៃដំណើរការស្តារឡើងវិញនូវអរិយធម៌ និងមនុស្សធម៌សម្រាប់សង្គមក្រោយជម្លោះមួយ។

បន្ទាប់ពីមានការបង្កើតសាលាក្តីខ្មែរក្រហមកម្ពុជា មិនត្រឹមតែគាំពារដល់ការស្វែងរកយុត្តិធម៌នៅឯសាលាក្តីនេះតាមរយៈការផ្តត់ផ្គង់ឯកសារ វត្ថុតាង និងបទសម្ភាសន៍តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគាំពារដល់ការសម្រេចបានយុត្តិធម៌ក្នុងការអប់រំ ការចងចាំ សេវាកម្មសង្គម និងការទំនុកបម្រុងដទៃទៀតដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមថែមទៀតផង។

កម្ពុជាបានបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សា សិស្សានុសិស្សកម្រិតវិទ្យាល័យ និងគ្រូបង្រៀនកម្រិតឧត្តម រាប់ពាន់នាក់អំពីប្រវត្តិសាស្រ្តខ្មែរក្រហម ដោយប្រើប្រាស់វិធីសាស្រ្តសិក្សាបែបសិស្សមជ្ឈ-មណ្ឌល។ កម្ពុជាគាំទ្រដល់សិល្បៈ វប្បធម៌ និងកិច្ចផ្តួចផ្តើមអប់រំសាធារណៈ ដើម្បីធានាថាប្រវត្តិសាស្រ្ត និងបទពិសោធន៍របស់ជនរងគ្រោះ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នឹងមិនត្រូវបានបំភ្លេចបោល។ កម្ពុជាកំពុងអនុវត្តកម្មវិធីថែទាំសុខភាព និងទំនុកបម្រុងដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលជួយដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមឲ្យទទួលបានការថែទាំនិងការគាំពារ។ កម្ពុជាបានប្រតិបត្តិកម្មវិធីមួយដែលរួមមានអ្នកស្ម័គ្រចិត្តចំនួន ៥០០នាក់ ដែលជាអ្នកដឹកនាំយុវជនជំនាន់ក្រោយជាមួយនឹងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងសហគមន៍របស់ខ្លួន។ សកម្មភាពនេះផ្តល់ជូនអ្នករស់រានមានជីវិតនូវការគាំទ្របន្ថែម និងបង្កើតជាឱកាសបន្ថែមសម្រាប់យុវជន-យុវនារីដើម្បីរៀនសូត្រ។

ប្រទេសកម្ពុជាមានការលូតលាស់គួរឲ្យកត់សម្គាល់ជាច្រើន ចាប់តាំងពី ឆ្នាំ១៩៩៩ មកម្ល៉េះ ក៏ប៉ុន្តែកម្ពុជាត្រូវឆ្លងកាត់ការតស៊ូ និងភាពឈឺចាប់ជាច្រើន ដើម្បីឈានមកដល់ចំណុចនេះ។ ទោះបីជាយ៉ាងណាក្តី



កងកម្លាំងបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ, ស្រុកកំចាយមារ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៩២។ ដំណាក់កាលទីពីរនៃបទឈប់បាញ់នៅកម្ពុជាមានសុពលភាពចាប់ពីថ្ងៃនេះតទៅ។ នៅក្នុងដំណាក់កាលទីពីរនេះ ការទទួលខុសត្រូវរបស់ អ៊ុនតាក់ រួមមាន ការត្រួតពិនិត្យបទឈប់បាញ់ ការដាក់ទ័ពបណ្តោះអាសន្ន ការរំសាយទ័ពពីភាគីទាំងបួនរបស់កម្ពុជា។ អ៊ុនតាក់ ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ លេខ៧៤៥ (១៩៩២) និងត្រូវអនុវត្តនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩២។ អ៊ុនតាក់ មានភារកិច្ចដឹកនាំកម្ពុជាឆ្លងកាត់ដំណាក់កាលអន្តរកាលទៅរកការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ដែលនឹងប្រព្រឹត្តទៅ នៅខែមេសា ឬឧសភា ឆ្នាំ១៩៩៣ ក្នុងគោលបំណងបង្កើតរដ្ឋាភិបាលប្រជាធិបតេយ្យមួយ។
រូបថត៖ អង្គការសហប្រជាជាតិ
ប្រភព៖ Benny Widyono



ប្រជាជនកម្ពុជាធ្វើមាតុភូមិនិវត្តពីជំរំជនភៀសខ្លួននៅប្រទេសថៃតាមរយៈរថភ្លើងដែលរៀបចំដោយឧត្តមក្រុមប្រឹក្សាជាន់ខ្ពស់ទទួលបន្ទុកជនភៀសខ្លួនរបស់អង្គការសហប្រជាជាតិសំដៅមកទីក្រុងភ្នំពេញ នៅខែមិថុនា ឆ្នាំ១៩៩២។ (ប្រភព៖ Benny Widyono)



បុរសម្នាក់ធ្វើត្រាប់តាមរូបផ្សាយអំពីការចុះឈ្មោះបោះឆ្នោតដោយលើកបង្ហាញបណ្ណចុះឈ្មោះបោះឆ្នោតអ៊ុនតាក់របស់គាត់។ រូបថតនេះ ថតនៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៩២។ រូបថត៖ Pernaca Sudhakaran
ប្រភព ៖ Benny Widyono



ប្រជាជនកម្ពុជាប្រមូលផ្តុំគ្នានៅក្បែរការិយាល័យបោះឆ្នោតមួយនៅខេត្តព្រៃវែង នៅថ្ងៃទីពីរនៃការបោះឆ្នោត ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២៣ ដល់ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ១៩៩៣។
រូបថតនេះ ថតនៅថ្ងៃទី ២៤ ខែឧសភា ឆ្នាំ១៩៩៣។
រូបថត៖ Pernaca Sudhakaran/ប្រភព៖ Benny Widyono

កម្ពុជាមិនដែលរួញរាសោះឡើយ។ បច្ចុប្បន្នអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណជាង៥លាននាក់ទៀតរួមទាំងជនដៃដល់ផង នៅរស់រានមានជីវិតដើម្បីរៀបរាប់អំពីរឿងរ៉ាវរបស់ខ្លួនក្នុងអំឡុងរបបខ្មែរក្រហម។

ដំណើររបស់កម្ពុជាឆ្ពោះទៅកាន់ការផ្សះផ្សាមិនទាន់បញ្ចប់ ហើយក៏នឹងគ្មានទីបញ្ចប់ដែរ។ ការរារាំងទប់ស្កាត់ ទាមទារនូវការប្តេជ្ញាដ៏មោះមុតក្នុងការចងចាំអំពីអតីតកាល។



អ្នកបើកម៉ូតូរ៉ឺម៉កដឹកមនុស្ស និងទំនិញទៅខេត្តកំពត នៅខែសីហា ឆ្នាំ១៩៩២។
រូបថត ៖ អ៊ុនតាក់ / Pernaca Sudhakaran

# ហេតុអ្វីប្រវត្តិសាស្ត្រយោធាកម្ពុជា
## មានសារសំខាន់ឥតពីរចំពោះសន្តិសុខជាតិ និងសន្តិសុខតំបន់អាស៊ាន

**ឆាំង យុ**



សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិកម្ពុជា (ខាងស្តាំ) និងឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេសរបស់សម្តេចពិជ័យសេនា ទៀ បាញ់ (ខាងឆ្វេង) អញ្ជើញពិនិត្យគម្រោងនៅឯមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង (មជ្ឈមណ្ឌលឯកសារកម្ពុជា) ដើម្បីបង្កើតជាស្តូបអនុស្សាវរីយ៍ ឈ្នះ ឈ្នះ ។ រូបថតដោយ លី កុកឆាយ ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២០។

ខណៈពេលដែលយើងរំពុកខួបលើកទី៣០នៃសន្និសីទសន្តិភាពទីក្រុងប៉ារីស យើងនឹងបំពេញកាតព្វកិច្ចបានយ៉ាងប្រសើរមួយក្នុងការទទួលស្គាល់សារសំខាន់នៃប្រវត្តិសាស្ត្រ ជាពិសេសប្រវត្តិសាស្ត្រយោធាកម្ពុជា ចំពោះតំបន់ និងពិភពលោក។ ប្រវត្តិសាស្ត្រកម្ពុជា គួរតែត្រូវទទួលស្គាល់ថាជាធនធានជាតិមួយជំរុញដល់ការអភិវឌ្ឍជាយុទ្ធសាស្ត្ររបស់ប្រទេសជាតិ ជះឥទ្ធិពល និងភាពជាអ្នកដឹកនាំរបស់កម្ពុជានៅក្នុងតំបន់អាស៊ាន។

ប្រវត្តិសាស្ត្រយោធា ត្រូវបានពិពណ៌នាថា គឺជាការសិក្សាស្រាវជ្រាវអំពីសង្គ្រាម និងការវិភាគអំពីជ័យជម្នះ និងបរាជ័យ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រវត្តិ-សាស្ត្រយោធារួមបញ្ចូលនូវធាតុផ្សំជាច្រើនដទៃទៀតលើសពីនេះ។ ប្រវត្តិសាស្ត្រយោធាគ្រោបនូវប្រធានបទជាច្រើន ដែលរួមមានវឌ្ឍនភាព និងបរាជ័យនៃរបបនីមួយៗរហូតដល់ការវិវត្តរបស់ប្រទេសជាតិនានា ព្រមទាំងសកម្មភាពដែលមនុស្សជាតិសាងកំហុសដដែលៗ



សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិកម្ពុជា និងឧត្តមសេនីយ៍ ណឹម សុវត្ថិ (ខាងស្តាំ)។ នាយទាហានបន្ទាប់ពីឯកឧត្តម ណឹម សុវត្ថិ គឺឧត្តមសេនីយ៍ឯក មាស ស៊ីណា (នៅខាងឆ្វេង) និងលោក ឆាំង យុ (អង្គុយ)។ គណប្រតិភូកិត្តិយសបានធ្វើទស្សនកិច្ចនៅទីតាំងដាក់ស្នើជាតំបន់ប្រវត្តិសាស្ត្រយោធា ស្ថិតនៅក្បែរមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ខេត្តឧត្តរមានជ័យ តាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ រូបថតដោយ លី កុកឆាយ ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២០។

ឬបានរៀនសូត្រពីកំហុសរបស់ខ្លួន។ ប្រវត្តិសាស្ត្រកម្ពុជា ពោរពេញទៅដោយមេរៀនឥតមានពីរសម្រាប់ប្រទេសរបស់ខ្លួន តំបន់ និងពិភពលោក។

ប្រទេសកម្ពុជា គឺជាចំណុចប្រសព្វដ៏សំខាន់ជាយុទ្ធសាស្ត្រមួយនៃការតស៊ូប្រទាញប្រទង់គ្នាក្នុងអំឡុងសង្គ្រាមត្រជាក់រវាង មនោគមវិជ្ជា ប្រព័ន្ធនយោបាយ និងទំនោរនៃគោលនយោបាយការបរទេស។ ប្រវត្តិសាស្ត្រកម្ពុជាដែលញ៉ាំងឲ្យកើតមាន និងជាផ្នែកខ្លះនៃប្រវត្តិសាស្ត្រ ទាក់ទងនឹងអន្តរាគមន៍ពីសំណាក់បរទេសនៅក្នុងតំបន់ សបញ្ជាក់ឲ្យឃើញថា ប្រទេសកម្ពុជាមានសារសំខាន់យ៉ាងដូចម្តេចចំពោះសន្តិសុខនៅក្នុងតំបន់ ហើយសន្តិសុខនៅក្នុងតំបន់មានសារសំខាន់យ៉ាងដូចម្តេច ចំពោះសន្តិសុខពិភពលោក។ បន្ថែមលើសពីនេះទៅទៀត ការសម្លាប់រង្គាល សង្គ្រាម និងការបំផ្លិចបំផ្លាញ កើតមានជាច្រើនលើកច្រើនសានៅក្នុងទំព័រប្រវត្តិសាស្ត្រកម្ពុជា នាចុងសតវត្សរ៍ទី២០ បានផ្តល់ជាមេរៀនសំខាន់ៗ ស្តីអំពីស្ថានភាពដែលកើតមានឡើង និងលទ្ធផលពីអស្ថិរភាពសង្គ្រាម និងអំពើប្រល័យពូជសាសន៍។ ប្រវត្តិសាស្ត្រកម្ពុជា គឺជាតឹកតាងមួយនៃស្មារតីដ៏រឹងមាំរបស់មនុស្ស ក៏ដូចជាមេរៀនស្តីពីជម្រៅនៃទុច្ចរិតភាពរបស់មនុស្ស។

ប្រវត្តិសាស្ត្រកម្ពុជា ត្រូវបានបន្ទុចបង្អាក់ជាច្រើនលើកច្រើនសា ដោយប្រទេសជិតខាង ដើម្បីទន្ទ្រានយក គ្រប់គ្រង និងដណ្តើមកាន់កាប់ទឹកដីពីប្រជាជនកម្ពុជា។ ការសិក្សាអំពីប្រវត្តិសាស្ត្រនៃទំនាក់ទំនងទំនាស់ និងជម្លោះកាលពីអតីតកាល ទាំងអស់នេះ មិនអាចត្រួសត្រាយផ្លូវសម្រាប់ការទូតឬកិច្ចការយោធានាពេលបច្ចុប្បន្នឬអនាគតទេ ក៏ប៉ុន្តែប្រវត្តិសាស្ត្រនេះគឺជាធនធានជាតិមួយ ដែលផ្តល់អំណាចដល់អ្នកដឹកនាំតាមរយៈគតិបណ្ឌិតជាយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងទំនាក់ទំនងជាមួយនឹងប្រទេសជិតខាងនិងពិភពលោក។

ប្រវត្តិសាស្ត្រកម្ពុជា ជាពិសេសប្រវត្តិសាស្ត្រយោធា ផ្តល់ជាធនធានដ៏ចាំបាច់មួយ សម្រាប់ការអភិវឌ្ឍគតិបណ្ឌិតជាយុទ្ធសាស្ត្ររបស់អ្នកដឹកនាំប្រទេសជាតិរបស់យើង អ្នកដឹកនាំក្នុងតំបន់ និងអ្នកដឹកនាំកម្រិតពិភពលោក។ ប្រវត្តិសាស្ត្រយោធាកម្ពុជាពោរពេញទៅដោយមេរៀនអំពីវិធីសាស្ត្របែបណានិងពេលវេលាសក្តិសមណាមួយដែលគួរដាក់កំហិត អត់ធ្មត់ ឬតតាំងដោយអង់អាច ក្នុងការការពារសន្តិសុខជាតិប្រកបដោយភាពវៀងវៃ។ ថ្នាក់ដឹកនាំយោធារបស់កម្ពុជា អាចចាត់ទុកប្រវត្តិសាស្ត្រយោធាកម្ពុជាថាជាធនធានជាតិមួយ ក្នុងការដុសខាត់កសាងគតិបណ្ឌិតជាយុទ្ធសាស្ត្ររបស់ខ្លួន និងការបង្កើនជំនាញវិជ្ជាជីវៈរបស់អង្គភាព និងមន្ត្រីយោធារបស់ខ្លួនថែមទៀតផង។

សន្តិសុខជាតិរបស់កម្ពុជា ពឹងផ្អែកទៅលើអង្គភាពយោធាប្រកបដោយជំនាញវិជ្ជាជីវៈ។ អង្គភាពយោធាប្រកបដោយជំនាញវិជ្ជាជីវៈ ទាមទារនូវថ្នាក់ដឹកនាំពោរពេញដោយសមត្ថភាព ដែលមិនត្រឹមជាអ្នកជំនាញរៀបចំយុទ្ធសាស្ត្រប៉ុណ្ណោះទេប៉ុន្តែថែមទាំងជាអ្នកប្រវត្តិសាស្ត្រទៀតផងពីព្រោះថាគ្មានយុទ្ធសាស្ត្រជោគជ័យណាមួយ ដែលអាចបង្កើតឡើងបានដោយគ្មានការយល់ដឹងអំពីប្រវត្តិសាស្ត្រនោះឡើយ។

ប្រវត្តិសាស្ត្រកំណត់នូវសមាសធាតុស្នូលសម្រាប់យុទ្ធសាស្ត្រជោគជ័យនានា។ ប្រវត្តិសាស្ត្រយោធានាថាយុទ្ធសាស្ត្រមួយមិនមែនរួមបញ្ចូលតែបរិបទប្រតិបត្តិការ យុទ្ធវិធី និងទ្រឹស្តីបច្ចុប្បន្នប៉ុណ្ណោះទេប៉ុន្តែថែមទាំងគួបផ្សំនូវជោគជ័យ និងកំហុសពីអតីតកាលថែមទៀតផង។ ប្រវត្តិសាស្ត្រអាចផ្តល់ជាគោលគំនិតដល់យើង ថាតើគោលបំណងនៃយុទ្ធសាស្ត្ររបស់យើងអាចទទួលយកបានឬទេ? ថាតើវិធីសាស្ត្រឈានទៅសម្រេចគោលបំណងរបស់យើង អាចបត់បែនតាមកាលៈទេសៈ ដែរឬទេ? ថាតើអ្នកដឹកនាំពីមុនៗរបស់យើងបានប្រើប្រាស់យុទ្ធសាស្ត្រដូចគ្នា ឬខុសគ្នាបែបណានាពេលកន្លងទៅ? ប្រវត្តិសាស្ត្រយោធា គឺជាសមាសធាតុស្នូលគួបផ្សំបញ្ចូលគ្នានូវយុទ្ធសាស្ត្រយោធា និងសន្តិសុខជាតិ។

ប្រជាជាតិជាសមាជិក និងសហថ្នាក់ដឹកនាំនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ត្រូវការអ្នកដឹកនាំដែលជាអ្នកប្រវត្តិសាស្ត្រផង និងជាអ្នករៀបចំយុទ្ធសាស្ត្រផង។ ប្រវត្តិសាស្ត្រយោធាកម្ពុជា មានសារសំខាន់ឥតពីរ ចំពោះសន្តិភាព និងសន្តិសុខនៅក្នុងតំបន់ពីព្រោះថាសមរភូមិ ការតស៊ូ និងយុទ្ធសាស្ត្រភូមិសាស្ត្រនយោបាយជាច្រើន ត្រូវបានផ្តោតនៅក្នុងប្រវត្តិសាស្ត្រយោធាកម្ពុជា។ ប្រទេសកម្ពុជា គឺជាចំណុចប្រជុំទម្ងន់ដ៏សំខាន់មួយក្នុងអំឡុងសង្គ្រាមជម្លោះ និងការតស៊ូជាច្រើនដែលកើតមាននៅក្នុងតំបន់នាសតវត្សរ៍ទី២០។ បន្ទាប់ពីសង្គ្រាមឥណ្ឌូចិនលើកទីមួយបានបញ្ចប់ទៅ ប្រទេសកម្ពុជាទទួលបានឯករាជ្យ ចំណែកឯនៅក្នុងអំឡុងសង្គ្រាមឥណ្ឌូចិនលើកទីពីរ ប្រទេសកម្ពុជាគឺជាចំណុចកណ្តាលមួយ



សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការពារជាតិកម្ពុជា (ខាងស្តាំ) និងឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេសរបស់សម្តេចពិជ័យសេនា ទៀ បាញ់ (ខាងឆ្វេង) និងលោក ឆាង យុ (រូបកណ្តាល) អញ្ជើញពិនិត្យគម្រោងនៅឯមជ្ឈមណ្ឌលសន្តិភាព អន្លង់វែង (មជ្ឈមណ្ឌលឯកសារកម្ពុជា) ដើម្បីបង្កើតជាស្តូបអនុស្សាវរីយ៍ ឈ្នះ ឈ្នះ ។
រូបថតដោយ លី កុកឆាយ ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២០។

នៃការទម្លាក់គ្រាប់បែកទ្រង់ទ្រាយធំបំផុតនៅក្នុងប្រវត្តិសាស្ត្រពិភពលោក។ ទីតាំងភូមិសាស្ត្រនយោបាយរបស់កម្ពុជា នៅក្នុងអំឡុងសង្គ្រាមឥណ្ឌូចិនលើកទីពីរ ញ៉ាំងឲ្យកម្ពុជាក្លាយជាវាលសមរភូមិដ៏សំខាន់មួយរវាងគូប្រកួតប្រជែងអំណាចមួយចំនួន។

នៅចន្លោះឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាបានទទួលរងទុក្ខវេទនា ពីសោកនាដកម្មហួសពីការស្មាននៅក្រោមរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ថ្វីត្បិតតែរបបខ្មែរក្រហមត្រូវផ្តួលរំលំតាំងពីឆ្នាំ១៩៧៩ទៅហើយក្តី ប្រទេសកម្ពុជាបន្តប្រឈមជាមួយនឹងសង្គ្រាម ទុរភិក្ស និងវិបត្តិមនុស្សធម៌នានាដែលបង្កឲ្យមានការបាត់បង់ជីវិត ការជម្លៀសទីតាំង ឬការប្តូរទីជម្រករបស់ប្រជាជនកម្ពុជារាប់លាននាក់។ បរាជ័យរបស់ខ្មែរក្រហម មិនត្រឹមតែជាជោគជ័យជាយុទ្ធសាស្ត្ររបស់ប្រទេសកម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាជោគជ័យជាយុទ្ធសាស្ត្រសម្រាប់អាស៊ាន និងពិភពលោកថែមទៀតផង។

ការចូលរួម សមយុទ្ធ និងយុទ្ធសាស្ត្រយោធាដែលបានអនុវត្តនៅក្នុងប្រទេសកម្ពុជានៅរវាងឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៩៣ បានអង្រួនតំបន់អាស៊ាន ហើយនៅក្នុងកម្រិតមួយ កម្លាំងចលករទាំងនេះបាន (និងនៅតែបន្ត) កំណត់សណ្ឋាននៃភូមិសាស្ត្រនយោបាយរបស់អាស៊ានបច្ចុប្បន្ន។ ប្រវត្តិសាស្ត្រយោធាកម្ពុជា គឺជាប្រវត្តិសាស្ត្រដែលមិនត្រឹមតែរួមបញ្ចូលសមរភូមិនិងសមយុទ្ធយោធាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមផ្សំនូវការសម្រេចចិត្តនយោបាយជាគោលនិងយុទ្ធសាស្ត្រសំខាន់ៗ ដែលនៅតែជាកំណត់យោងដ៏ចាំបាច់សម្រាប់ផ្តល់ដល់សន្តិសុខជាតិនិងយុទ្ធសាស្ត្រអាស៊ានជារួម នៅក្នុងតំបន់អាស៊ីអាគ្នេយ៍សព្វថ្ងៃនេះ។

ខណៈពេលដែលយើងរំឭកខួបលើកទី៣០នៃសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស យើងគួរឆ្លៀតយកឱកាសនេះ ដើម្បីសញ្ជឹងគិតអំពីអ្វីដែលយើងបានរៀនសូត្រពីប្រវត្តិសាស្ត្រនៅជុំវិញសន្ធិសញ្ញានេះ និងឆ្លុះបញ្ចាំងអំពីអ្វីខ្លះ ដែលយើងបានយល់ពីប្រវត្តិសាស្ត្រទាំងស្រុងរបស់កម្ពុជា។ គ្មានពេលវេលាណាដែលសក្តិសមជាងពេលបច្ចុប្បន្នក្នុងការរំលេចចេញនូវសារសំខាន់នៃប្រវត្តិសាស្ត្រ ស្របពេលដែលកម្ពុជាកំពុងត្រៀមខ្លួនធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ានក្នុងឆ្នាំ២០២២។ ខណៈពេលដែលកម្ពុជា កំពុងត្រៀមរៀបចំកិច្ចប្រជុំអាស៊ាន យើងគួរតែទទួលស្គាល់តួនាទីក្នុងការដឹកនាំកិច្ចប្រជុំនេះ ថាជាឱកាសមួយក្នុងការប្រើប្រាស់ធនធាននានា ក្នុងចំណោមធនធានទាំងឡាយ ជាពិសេសប្រវត្តិសាស្ត្រកម្ពុជាឲ្យមានប្រសិទ្ធភាព ឈានទៅសម្រេចបានការអភិវឌ្ឍភាពជាដៃគូសហការ និងភាពជាអ្នកដឹកនាំជារួមសម្រាប់ប្រជាជនកម្ពុជានិងប្រជាជនអាស៊ាន។ ប្រវត្តិសាស្ត្រកម្ពុជា គឺជាផ្នែកនិងធាតុផ្សំចម្បងក្នុងការឈានទៅបង្កើតសន្តិភាពនិងសន្តិសុខរួមគ្នាមួយសម្រាប់តំបន់អាស៊ាន។

លោក ឆាំង យុ គឺជានាយកប្រតិបត្តិមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាអ្នកដឹកនាំម្នាក់លើការអប់រំការរារាំងទប់ស្កាត់ និងការសិក្សាស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍។ នៅក្នុងឆ្នាំ២០១៨ លោក ឆាំង យុ ទទួលបានពានរង្វាន់ រ៉ាមុន ម៉ាកសៃសៃ ដែលត្រូវស្គាល់ថាជា "ពានរង្វាន់ណូបែលអាស៊ី" សម្រាប់ការងាររបស់លោកក្នុងការថែរក្សាការចងចាំពីអំពើប្រល័យពូជសាសន៍ និងការស្វែងរកយុត្តិធម៌សម្រាប់ប្រទេសកម្ពុជានិងពិភពលោក។ នៅក្នុងឆ្នាំ ២០០៧ លោកត្រូវបានជ្រើសរើសជាបុគ្គលដ៏មានឥទ្ធិពលបំផុតទាំង១០០ នាក់របស់ទស្សនាវដ្តី ថាមស៍។ លោក ឆាំង យុ បានបំពេញការងារជាមួយស្ថាប័ននិងអ្នកដឹកនាំសង្គមស៊ីវិលជាច្រើននៅជុំវិញពិភពលោក ដែលក្នុងនោះរួមមាន ប្រទេសអ៊ីរ៉ាក់ ប្រទេសអាហ្វហ្គានីស្ថាន ប្រទេសស៊ីរី ប្រទេសមីយ៉ាន់ម៉ា និងប្រទេសកំពុងអភិវឌ្ឍក្រោយជម្លោះដទៃផ្សេងៗទៀត។ នារយៈពេល១៨ខែចុងក្រោយនេះ លោកបានសិក្សាស្រាវជ្រាវលម្អិតអំពីប្រវត្តិសាស្ត្រយោធាកម្ពុជា និងតំបន់ប្រវត្តិសាស្ត្រយោធា ជាមួយនឹងឧត្តមសេនីយ៍ ណឹម សុវត្ថិ នៃក្រសួងការពារជាតិកម្ពុជា។

# អ៊ូ សៀង ៖ អនុប្រធានសេដ្ឋកិច្ច

## ឃុំស្រែសង្គម ស្រុកអូររាំង តំបន់១០៥ ភូមិភាគឦសាន

ដារ៉ារដ្ឋ មេត្តា



យុវនារីកងចល័តនៅស្រុកស្នួង កំពុងវាយសម្រុកបោកបែនស្រូវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អ៊ូ សៀង ភេទប្រុស អាយុ៣៣ឆ្នាំ (នៅឆ្នាំ១៩៧៨)។ ខ្ញុំមានស្រុកកំណើតនៅភូមិព្រៃកំពែង ឃុំអញ្ចើម ស្រុកមេមត់ ខេត្តកំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ)។ ខ្ញុំរៀបការរួចហើយ។ ឪពុករបស់ខ្ញុំចាកចេញពីស្រុកកំណើតទៅធ្វើការនៅចម្ការកៅស៊ូ នៅពាមជាំង ខេត្តកំពង់ចាម ដូច្នេះខ្ញុំមករៀននៅសាលាគីឡូបាយសៅ ក្នុងចម្ការកៅស៊ូ ដែរ។ ខ្ញុំរៀនកម្រិតកុមារដ្ឋាន និងអាចអានអក្សរបាន ហើយក្រោយមកក៏ឈប់រៀន។ ក្រោយឆ្នាំ១៩៦០ ខ្ញុំធ្វើជាកម្មករចៀរជ័រកៅស៊ូនៅគីឡូបាយសៅ ជាមួយឪពុកម្ដាយ។ នៅទីនោះខ្ញុំបានជួបឈ្មោះ ភិន គឺជាជីវ្រត្តកម្មករចម្ការកៅស៊ូពាមជាំង ខេត្តកំពង់ចាម, ផុន គឺជាជីវ្រត្តកម្មករចម្ការកៅស៊ូពាមជាំង ខេត្តកំពង់ចាម។

នៅឆ្នាំ១៩៦៤ ខ្ញុំទទួលការអប់រំពីឈ្មោះ ភិន, ផុន និង វ៉ាន់ ហើយខ្ញុំបានស្ម័គ្រចិត្តចូលធ្វើកិញតាមដានខ្មែរក្រហម នៅចម្ការកៅស៊ូ ពាមជាំង។ តាមរយៈ ភិន, ផុន និង វ៉ាន់ ខ្ញុំបានទាក់ទងខ្សែកិញមានឈ្មោះ ស៊ឹម គឺជាជីវ្រត្តកម្មករចម្ការកៅស៊ូនៅពាមជាំង ខេត្តកំពង់ចាម, សារ៉ែត គឺជាជីវ្រត្តកម្មករកៅស៊ូនៅពាមជាំង ខេត្តកំពង់ចាម។ យើងមានផែនការកសាងកម្លាំងនិងតាមដានខ្មែរក្រហម។

នៅឆ្នាំ១៩៦៨ វ៉ាន់, ហម និង សេង គឺជាប្រជាជននៅភូមិស្រែសង្កម ឃុំស្រែសង្កម ស្រុកអូររាំង បានណែនាំខ្ញុំឲ្យស្គាល់កម្លាំងចាស់របស់គាត់មានឈ្មោះ ឈុំ គឺជាប្រជាជនរស់នៅភូមិស្រែសង្កម, ស្វួន គឺជាប្រជាជនរស់នៅភូមិស្រែសង្កម ហើយយើងបានប្រជុំលើកអំពីផែនការ។ ហ៊ុម បានចាត់ឲ្យខ្ញុំចុះទៅភូមិលំទិត្យ រកខ្មែរក្រហម។ ក្រោយមកខ្ញុំបាននាំស្វួន និង ឈុំ ទៅជាមួយដែរ។ ប្រជាជននៅភូមិលំទិត្យ និយាយថា «សព្វថ្ងៃខ្ញុំដូចជាឆ្ងល់នៅត្រពាំងព្រៃតែសំឡេងត្រដោកក្របីរាល់តែយប់ ហើយឆ្ងល់ទៅមើលដានជើងមិនឃើញសោះ»។ ពេលត្រឡប់មកវិញខ្ញុំរាយការណ៍ទៅឲ្យវង់វ៉ែនអតីតស័ក្តិ៤ ទទួលខុសត្រូវកូនទាហាននៅបន្ទាយស្រុកកោះញែក តំបន់១០៥។ ក្រោយមកខ្ញុំបាននាំ ម៉ុល គឺជាកម្មករអាឈើ នៅតំបន់១០៥, ញើង គឺជាកម្មករអាឈើ នៅតំបន់១០៥, ឈុំ, វ៉ាន់, សេង ទៅរកខ្មែរក្រហមនៅត្រពាំងលំទិត្យ ទើបដឹងដំណឹងថាមានខ្មែរក្រហម រួចហើយក៏រាយការណ៍ឲ្យ វង់ វ៉ែន ។ វង់ វ៉ែន បានឲ្យទាហានចំនួន៥នាក់ទៅចាប់ខ្មែរក្រហម ប៉ុន្តែចាប់បានតែ១នាក់នៅត្រពាំងជីមៀត រួចនាំទៅជួប វង់ វ៉ែន នៅបន្ទាយស្រុកកោះញែក។ នៅក្នុងឆ្នាំ១៩៦៨ វង់ វ៉ែន បានហៅ វ៉ាន់, សេង និងខ្ញុំទៅប្រជុំនៅបន្ទាយកោះញែក។ វង់ បានលើកឡើងថា «សូមឲ្យបងៗទៅពិនិត្យរកខ្មែរក្រហមនៅភូមិជីមៀតម្តងទៀត ប្រសិនបើឃើញសូមរាយការណ៍ និងខិតខំកសាងកម្លាំងថែមទៀត»។ ក្រោយពីប្រជុំរួច វង់ ឲ្យលុយពួកខ្ញុំម្នាក់៥០០រៀល។

នៅឆ្នាំ១៩៧០ វង់ មកភូមិស្រែសង្កម ស្នើឲ្យមានការប្រជុំដោយអ្នកចូលរួមមាន ខ្ញុំ, សេង, ហ៊ុម, វ៉ាន់, ឈុំ, ស្វួន, ញើង, ម៉ុល និង ខ្ញុំ។ វង់ លើកឡើងថា ឥឡូវនេះកងរំដោះបានមកដល់ភូមិមរើច ហើយយើងនៅតតាំងក៏មិនឈ្នះដែរ ព្រោះកូនទាហានមានតែចំនួន១៥០នាក់។ ដើម្បីដកទាហានចេញពីបន្ទាយដោយសុវត្ថិភាព ឥឡូវសូមបងៗយករទេះទៅដឹកកាំភ្លើង និងគ្រាប់យកមកលាក់នៅព្រៃចាស់មាត់ច្បារ។ ប្រជុំរួចយើងបានអនុវត្តផែនការដឹកសម្ភាររយៈពេល២ថ្ងៃទើបអស់។ នៅខែមេសា ក្រុមរំដោះបានមកចាប់ វង់។ រយៈពេល៣ថ្ងៃក្រោយមក ខ្ញុំឃើញ កាំភូន សេដ្ឋកិច្ចតំបន់១០៥ (បានបាញ់សម្លាប់ខ្លួនឯងនៅក្នុងឆ្នាំ១៩៧៧) មករស់នៅក្នុងភូមិស្រែសង្កម និងអប់រំប្រជាជនដែលរស់នៅភូមិស្រែសង្កម។ ម៉ី គឺជាអនុលេខាតំបន់១០៥។ ម៉ី និង កាំភូន បានមកលេងផ្ទះ សេង ហៅ វ៉ាន់, ខ្ញុំ និង ហ៊ុម។ ម៉ី បានអប់រំយើងខ្ញុំថា បងៗដឹងខ្សែគិញទាំងអស់គ្នាដូច្នេះត្រូវប្រយ័ត្នកុំឲ្យមានគ្រោះថ្នាក់។ យើងត្រូវកសាងកម្លាំងនៅក្នុងជួរទាហានឲ្យបានកាន់តែច្រើន។ ខ្ញុំ និង កាំភូន ទទួលខុសត្រូវគិញទាំងអស់។ ក្រោយមកខ្ញុំ និង វ៉ាន់ កសាងកម្លាំងបានចំនួន២នាក់ មានឈ្មោះ មាស និង យ៉ន។ ក្រោយមកខ្ញុំ និង វ៉ាន់បាននាំយ៉ន និង មាស ទៅធ្វើសកម្មភាពនៅមន្ទីរយោធាមាត់ច្បារ។ ខ្ញុំបានបញ្ជាឲ្យរើសដុំថ្មគប់ទៅលើដំបូលផ្ទះប្រជាជនហើយនាំគ្នារត់។ ក្រោយមក ហ៊ឹម និង សេង ប្រាប់ខ្ញុំថា កម្លាំងរបស់គាត់មានពីរនាក់រួមមាន យ៉ុន គឺជាប្រជាជននៅភូមិជីមាត ស្រុកកោះញែក និង សុខ ប្រជាជននៅភូមិជីមាត ស្រុកកោះញែក។ ខ្ញុំនាំ សុខ និង យ៉ុន ដើរបំផុសប្រជាជននៅភូមិចាខ្លប់ មិនឲ្យឪពុកម្តាយអនុញ្ញាតឲ្យកូនចូលធ្វើយោធា។

នៅឆ្នាំ១៩៧១ កាំភូន មកដល់ផ្ទះ ម៉ី ហើយ បានឲ្យ ហ៊ុម មកហៅខ្ញុំ, វ៉ាន់ និង សេង ទៅជួប។ ម៉ី ប្រាប់ថា នៅមានកម្លាំងចំនួន៣នាក់ទៀត មានឈ្មោះ ស្វាយ គឺជាគណៈស្រុកកោះញែក តំបន់១០៥, រ៉ា គឺជាអនុលេខាស្រុកកោះញែក តំបន់១០៥ និង មានីត គឺជាកម្មាភិបាលក្តាប់កងវរសេនាតូច យោធាតំបន់១០៥។ ថ្ងៃក្រោយឈ្មោះ រ៉ា, មានីត និង ស្វាយ ហៅខ្ញុំចូលរួមធ្វើសកម្មភាពដុតរោងដាក់អង្ករអស់ចំនួន ១ខ្នង ដែលមានផ្ទុកអង្ករចំនួន៥០បាវ និងអំបិលចំនួន៣០បាវ។

នៅឆ្នាំ១៩៧៣ ម៉ី, កាំភូន, ស្វាយ, រ៉ា, មានីត, ភុត គឺជាកម្មាភិបាលទទួលខុសត្រូវកម្មករ ក្នុងតំបន់១០៥ និងបង ហ៊ុម បានហៅខ្ញុំ, វ៉ាន់, សេង, ឈុំ, ស្វួន ទៅផ្ទះរបស់គាត់ ហើយបានណែនាំយើងឲ្យបានស្គាល់កម្លាំងចាស់ចំនួន៣នាក់ទៀត មានឈ្មោះ ខាំ គឺជាគណៈ



ប្រជាជននៅក្នុងសហករណ៍ស្រុកកោះធំ កំពុងនាំគ្នាប្រមូលផលពោតដើម្បីឧត្ដម្ភកងទ័ពបដិវត្តន៍នៅសមរភូមិមុខៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្រុកច្បារ នៅតំបន់១០៥, ប៊ុន គឺជាប្រធានយោធាស្រុកអូររាំង និង សឿង គឺជាសេដ្ឋកិច្ចយោធាស្រុកអូររាំង។ នៅក្នុងប្រជុំ មុី បានលើកឡើងថា យើងទាំងអស់គ្នាដែលជាខ្មែរគិញត្រូវប្រយ័ត្នគ្រោះថ្នាក់ដល់ខ្លួនមុននឹងធ្វើសកម្មភាព, ត្រូវធ្វើសកម្មភាពគ្រប់កន្លែងកុំឲ្យដកកម្លាំងយោធានៅខាងមុខបាន, ត្រូវកសាងកម្លាំងទាហានឲ្យបានច្រើនៗ។ ក្រោយមក ខាំ, ប៊ុន, សឿង, បានមកហៅខ្ញុំ, វ៉ាន់ និង ឈុំ, ម៉ុល ទៅមន្ទីរយោធាតំបន់ស្រុកកោះញែក ហើយនៅម៉ោង១០យប់ យើងក៏ទៅដុតឃ្លាំងដាក់កាំភ្លើង និង គ្រាប់អស់១ឃ្លាំង។

នៅក្នុងឆ្នាំ១៩៧៥ មុី, កាំភួន, ស្វាយ, វ៉ា, ភុន, ឈុំ, ប៊ុន, ង៉ែម, សឿង, ធឿន មកផ្ទះមុី ដើម្បីប្រជុំ។ មុីបានទទួល ហើយបានណែនាំកម្លាំងចាស់ម្នាក់ទៀតឈ្មោះ ឌឹក ជនជាតិយួន (វៀតណាម) កម្មាភិបាលទទួលខុសត្រូវខាងកងទ័ពយួន។ ថ្ងៃក្រោយមកមានកងទ័ពយួនចំនួន១៥នាក់ចូលមកមន្ទីរ ស្វាយ ហើយចូលលាក់ខ្លួនក្នុងព្រៃចាស់ខាងកើតភូមិស្រែហ៊ុយ។ មុីបានប្រាប់ទៅ ឌឹក ឲ្យចូលវាយនៅភ្នំខាងមណ្ឌលគិរី ចម្ងាយ៨គីឡូម៉ែត្រពីព្រំដែនដែលក្រុមរំដោះរស់នៅឯកម្លាំងនៅខាងក្នុង ធ្វើសកម្មភាពក្រោយ កុំឲ្យយោធាដកកម្លាំងទៅជួយបាន។

នៅឆ្នាំ១៩៧៦ កាំភួន, ស្វាយ, វ៉ា, មានិត, ភុត, មុី, បានមកផ្ទះ សេង ហើយពេលនោះ សេង ទៅហៅខ្ញុំ នឹង ហ៊ុមគឺជា ប្រជាជននៅភូមិស្រែសង្កម, ឈុំ គឺជាប្រជាជននៅភូមិស្រែសង្កម, វ៉ាន់ គឺជា សង្កមកិច្ចនៅភូមិស្រែសង្កម ទៅជួបគ្នានៅផ្ទះគាត់។ ពេលប្រជុំ មុី បានលើកឡើងឲ្យយើងទាំងអស់គ្នាធ្វើសកម្មភាពរាល់ថ្ងៃ និងពេលយប់។ ពិសេសកសាងកម្លាំងឲ្យបានច្រើនដើម្បីបង្កប់ក្នុងបដិវត្តន៍។ ក្រោយមក កាំភួនបានមកផ្ទះខ្ញុំ ហើយយើងនាំគ្នាទៅធ្វើសកម្មភាពយកដុំថ្មគប់ទៅលើមន្ទីរយោធាធ្វើឲ្យមានការឆោឡោពេញមន្ទីរ។ យើងនាំគ្នារត់ត្រឡប់មកវិញហើយបានរាយការណ៍ប្រាប់ មុីឲ្យបានដឹង។ ក្រោយមកខ្ញុំ, យឿន, សុីម, អួន បានចុះធ្វើសកម្មភាពនៅភូមិស្រែសង្កម។ ខ្ញុំបានដើរចូលផ្ទះប្រជាជនធ្វើឲ្យមានការឆោឡោពេញភូមិ។

ក្រោយមកទៀតខ្ញុំ, មុី, ស្វាយ, កាំភួន, វ៉ា, មានីត, ភុត, ខាំ, និង ឌឹក ជួបគ្នាដើម្បីរៀបចំផែនការ។ សេង ប្រាប់ខ្ញុំ វ៉ាន់ និង ហ៊ឹម ទៅព្រៃចាស់ខាងស្រែហ៊ុយ។ ឌឹក នាំកងទ័ពចំនួន៥០នាក់ទៅអូរប៉ូត និង ភ្នំណាំណា ចំនួន៧០នាក់ ដោយ ទាហានរំដោះមិនបានដឹងទេ។

នៅឆ្នាំ១៩៧៧ ខ្ញុំ វ៉ាន់ ,សេង បានដើរធ្វើសកម្មភាពតាមមន្ទីរយោធានៅក្នុងភូមិស្រែសង្គម។ ពេលនោះ ខ្ញុំដើរគប់និងដើរបាញ់លើមន្ទីរធ្វើឲ្យយោធា ឆោឡោពេញមន្ទីរ។ ក្រោយមកខ្ញុំ វ៉ាន់ និង សេង កសាងបានកម្លាំងចំនួន៤នាក់ មានទ្រី, ស៊ិក, ស្រ៊ា និង ស្រាល។ នៅខែតុលា ឆ្នាំ១៩៧៧ ឌឹក បានឲ្យយើងត្រៀមអង្ករ សម្ភារសឹកដើម្បីទទួលកងកម្លាំងរបស់គាត់ដែលត្រៀមកម្លាំងវាយចូលមណ្ឌលគិរី។ មុីយល់ព្រមត្រៀមអង្ករ និងថ្នាំពេទ្យ ហើយបន្ទាប់ពីប្រជុំរួចយើងបំបែកគ្នា។ ក្រោយមកខ្ញុំ, វ៉ាន់, សេង, ស្ងួន គឺជាឈ្លបនៅភូមិស្រែសង្គម ដើរធ្វើសកម្មភាពនៅមន្ទីរស្រែសង្គម ដោយដើរគប់ផ្ទះរបស់ប្រជាជន។ ក្រោយមក អង្គការបានចាប់ មុី។ អត់ពី មុី យើងនៅមាន កាំភួន និង ភុត គឺជាអ្នកទទួលខុសត្រូវបន្ត។ ក្រោយពីអង្គការចាប់ មុី យើងបាននាំគ្នាប្រជុំនៅផ្ទះសេង។ យើងមានការប្រុងប្រយ័ត្ន និងកសាងកម្លាំងបន្តប់នៅក្នុងជួរបដិវត្តន៍។ យើងបានទៅធ្វើសកម្មភាពនៅតាមមន្ទីរយោធាតំបន់១០៥ ដោយអ្នកចូលរួមជាមួយខ្ញុំមាន វ៉ាន់, សេង និង វ៉ា។ យើងបានទៅដល់មន្ទីរយោធាតំបន់១០៥នៅម៉ោង១០យប់ និងនាំគ្នាចូលទៅបាញ់នៅមន្ទីរ១០៥ដោយប្រើកាំភ្លើងខ្លី ធ្វើឲ្យកើតមានការឆោឡោពេញមន្ទីរយោធា។ ក្រោយមក អង្គការបានចាប់ ស្វាយ។ មិនយូរប៉ុន្មានខ្ញុំឃើញយោធាស្រុកអូររាំង តំបន់១០៥ មកចាប់ខ្ញុំ នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៧៧។ អង្គការបាននាំខ្ញុំមកសន្តិសុខតំបន់១០៥ ភូមិភាគឦសាន ហើយបានបញ្ជូនបន្តមកអង្គភាពនៅភ្នំពេញ នៅខែវិច្ឆិកា ឆ្នាំ១៩៧៧។

**កំណត់ចំណាំ ៖ អត្ថបទនេះ ដកស្រង់ចេញពីចម្លើយសារភាពឯកសារ J00484 ។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយសារភាពរបស់ អ៊ូ សៀង ពិតប្រាកដយ៉ាងណានោះទេ?**



កងចល័តកំពុងកាស់គល់ឈើ និងរានដីដើម្បីដាំដុះស្រូវ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គង់ សារិនៈ កងចល័តនារីក្នុងរបបខ្មែរក្រហម

សុខ ចន្ទ្រា



គង់ សារិន ផ្តល់បទសម្ភាសន៍ដល់ សុខ ចន្ទ្រា អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ស្វាយរៀង ខែសីហា ឆ្នាំ២០២១។ (សុខ ចន្ទ្រា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សុខ ចន្ទ្រា គឺជាអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងខេត្តស្វាយរៀង។ ថ្មីៗនេះ សុខ ចន្ទ្រា បានទៅសួរសុខទុក្ខអ៊ុំ គង់ សារិន ដែលរស់នៅក្បែរផ្ទះរបស់ខ្លួន និងស្តាប់រឿងរ៉ាវរបស់អ៊ុំ គង់ សារិន គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបានរៀបរាប់ដូចខាងក្រោម៖

ខ្ញុំឈ្មោះ គង់ សារិន កើតនៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៥៧ នៅភូមិចន្ទ្រា ឃុំបន្ទាយក្រាំង ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង។ ខ្ញុំបានផ្លាស់មករស់នៅក្នុងភូមិស្វាយតាភ្លូ ឃុំប្រាសាក់ ស្រុកស្វាយជ្រំ ខេត្តស្វាយរៀងបន្ទាប់ពីរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩។ ឪពុករបស់ខ្ញុំឈ្មោះ ឈុន ស្រី ចំណែកម្តាយរបស់ខ្ញុំឈ្មោះ ហ៊ីង កៀង។ ខ្ញុំមានបងប្អូនពីរនាក់ ហើយខ្ញុំគឺជាកូនទីពីរ។

នៅអំឡុងឆ្នាំ១៩៧២ ខ្ញុំរៀនថ្នាក់ទីប្រាំបួន។ នៅពេលនោះមានការទម្លាក់គ្រាប់បែកបេ៥២យ៉ាងច្រើន ហើយខ្ញុំត្រូវរត់គេចខ្លួន ដូច្នេះខ្ញុំរៀនមិនបានជាប់លាប់ទេ។ កាលនោះកងទ័ពវៀតកុងបានចូលមកបាញ់នៅម្តុំត្រឡោងខុស ដែលប្រជាជននៅទីនោះហៅជាទូទៅថាសំយ៉ោង ស្ថិតនៅក្បែរៗភូមិរបស់ខ្ញុំ។ ខ្ញុំចូលដេកនៅក្នុងស្រះដើម្បីលាក់ខ្លួន ចំណែកប្រជាជននៅក្នុងភូមិជួបប្រទះនូវការលំបាកវេទនា និងស្លាប់ជាបន្តបន្ទាប់។ ឪពុករបស់ខ្ញុំគឺជាទាហាន លន់ នល់។ កាលនោះឪពុករបស់ខ្ញុំមានជំងឺ។ ម្តាយរបស់ខ្ញុំបាននាំឪពុករបស់ខ្ញុំពីក្រុងស្វាយរៀងទៅព្យាបាលនៅភូមិទាហាន ស្ថិតនៅខាងលិចផ្សារប្រសូត្រ។ ចំណែកខ្ញុំស្នាក់នៅជាមួយបង និងជីតារបស់ខ្ញុំនៅផ្ទះនៅឯស្រុកកំណើត។ នៅពេលនោះទីតាំងនៅខាងលិចភូមិទាហានគ្រប់គ្រងដោយទាហានលន់ នល់ ហើយទីតាំងចាប់ពីភូមិទាហានទៅទិសខាងកើតគ្រប់គ្រងដោយចលនាបដិវត្តន៍ខ្មែរក្រហម។ ឪពុករបស់ខ្ញុំបានលាក់កាំភ្លើងខ្លីនៅក្នុងអាវ ហើយនិយាយប្រាប់មេកងនៅភូមិទាហានតាមត្រង់ថា «អូនអើយ បងមកព្យាបាលជំងឺឥឡូវអូនឯងចង់ធ្វើអ្វីក៏ធ្វើ

ទៅ ព្រោះអូនដឹងប្រវត្តិបងហើយ»។ ឪពុករបស់ខ្ញុំ ហ៊ាននិយាយដូច្នេះ ដោយសារតែឪពុករបស់ខ្ញុំនិង មេកងស្គាល់គ្នា និងត្រូវជាបងប្អូននឹងគ្នា។ មេកង តបថា «មិនអីទេបង បើបងមិនធ្វើអ្វីខ្ញុំ ខ្ញុំក៏មិនធ្វើអ្វី បងឯងដែរ» ទើបឪពុករបស់ខ្ញុំរួចខ្លួននៅពេលនោះ។ រហូតដល់ឪពុកខ្ញុំធ្លាក់ខ្លួនឈឺធ្ងន់មើលមិនជា ទើប ឪពុកខ្ញុំសុំមេកងត្រឡប់មកក្រុងស្វាយរៀងវិញ។ មេកង អនុញ្ញាតដោយប្រាប់ឪពុករបស់ខ្ញុំថា «បងឯងទៅក៏ទៅ ចុះៗ ប៉ុន្តែបងកុំរាយការណ៍បេះបុះទៅបានហើយ» បន្ទាប់មកម្ដាយរបស់ខ្ញុំនាំឪពុករបស់ខ្ញុំដើរកាត់តាម ភូមិបាសាក់ ឆ្លងមកវត្តកោះជុំសំដៅចូលមកក្នុងក្រុង ស្វាយរៀងវិញ។ នៅខណៈនោះដែរ ខ្ញុំបានស្នើសុំ ប្រធានកងចល័តដែលត្រូវជាបងប្អូនជីដូនមួយរបស់ ខ្ញុំឆ្លងព្រែក មកជូនដំណើរឪពុកម្ដាយរបស់ខ្ញុំមកដល់ ត្រឹមភូមិទាហានក្រោម ព្រោះខ្មែរក្រហមមិនអនុញ្ញាត ឲ្យកងចល័តចេញចូលពីតំបន់មួយទៅតំបន់មួយឡើយ លើកលែងតែចាស់ៗទើបខ្មែរក្រហមអនុញ្ញាតឲ្យចេញ ចូលនៅពេលឈឺថ្កាត់ម្ដងៗ។ ក្រោយមកឪពុករបស់ខ្ញុំ ទៅព្យាបាលជំងឺបន្តនៅភ្នំពេញ ហើយមិនយូរប៉ុន្មាន គាត់បានស្លាប់នៅទីនោះ។ ពេលបូជាសពឪពុករបស់ខ្ញុំ រួចហើយ ម្ដាយរបស់ខ្ញុំយកធាតុរបស់ឪពុកខ្ញុំត្រឡប់ មកខេត្តស្វាយរៀងវិញ។ ក្រោយមកម្ដាយរបស់ខ្ញុំ សុំអនុញ្ញាតពីខាង លន់ នល់ ដែលគ្រប់គ្រងនៅក្នុង ក្រុងស្វាយរៀងយកធាតុប្ដីទៅធ្វើបុណ្យនៅស្រុក កំណើតនៅឃុំបន្ទាយក្រាំង ស្រុកកំពង់រោទិ៍។ អ្នក គ្រប់គ្រងបានយល់ព្រមតាមសំណើររបស់ម្ដាយខ្ញុំ និង ប្រាប់ម្ដាយខ្ញុំឲ្យដើរតាមថ្នល់ជាតិ ព្រោះបើដើរតាមផ្លូវ វាង (ផ្លូវកាត់) គឺអាចជាន់មីនផ្ទុះស្លាប់។ ពេលម្ដាយ របស់ខ្ញុំដើរចេញមក ខាង លន់ នល់ ធ្វើជាស្រែកថា «គ្នាយើងរត់ចូលខ្មាំងហើយកនយើង» ហើយក៏នាំគ្នា បាញ់កាំភ្លើង ប៉ុន្តែមិនឲ្យចំម្ដាយរបស់ខ្ញុំឡើយ។ នៅ ពេលម្ដាយខ្ញុំចូលទៅដល់តំបន់កងទ័ពរំដោះខ្មែរក្រហម គ្រប់គ្រង ខ្មែរក្រហមនាំគ្នាស្រែកថា មានខ្មាំងរត់ចូល មកហើយ គឺប្រពន្ធទាហានរត់ចូល ហើយក៏នាំគ្នា បាញ់អបអរ»។ ខ្ញុំបារម្ភពីម្ដាយរបស់ខ្ញុំខ្លាំងណាស់។ ក្រោយមកប្រជាជននៅក្នុងភូមិប្រាប់ថា «មិត្តនារី ដែលត្រូវជាម្ដាយរបស់មិត្តមកដល់ហើយ»។ ពេល ឮដូច្នេះ ខ្ញុំត្រេកអរយ៉ាងខ្លាំង។ យើងជួបគ្នា និងយំ នៅពេលឃើញធាតុឪពុក។ យើងបានសុំកងទ័ពរំដោះ ខ្មែរក្រហមដើម្បីធ្វើបុណ្យជូនឪពុករបស់ខ្ញុំ ប៉ុន្តែមិន មានព្រះសង្ឃទេ។

នៅអំឡុងឆ្នាំ ១៩៧៨ ខ្ញុំបានរៀបការជាមួយប្ដី របស់ខ្ញុំឈ្មោះ រាម សារ៉ុធ។ កាលនោះខ្មែរក្រហម រៀបចំពិធីរៀបការឲ្យខ្ញុំដែលសរុបទាំងអស់ចំនួន ២៥គូ។ យើងរៀបការក្នុងយប់តែមួយជាមួយគ្នា។ នៅមុនពេលរៀបការ ប្ដីរបស់ខ្ញុំស្នើសុំទៅប្រធានកង របស់គាត់ ប៉ុន្តែគូខ្លះត្រូវបានខ្មែរក្រហមបង្ខិតបង្ខំ។ គណអធិបតីរៀបចំឲ្យយុវជន-យុវនារី អង្គុយទល់ មុខគ្នា រួចហើយហៅឈ្មោះឲ្យឡើងកាន់ដៃគ្នា និង មានមេក្រុមម្នាក់ឡើងស្រែកប្ដេជ្ញា។

នៅឆ្នាំ១៩៧៨ ដដែល ខ្មែរក្រហមជម្លៀសគ្រួសារ ខ្ញុំទៅកន្ទុត ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។ ខ្មែរ ក្រហមចាត់តាំងឲ្យខ្ញុំរែកដី ជីកប្រឡាយដែលមាន ជម្រៅ ២០ម៉ែត្រ។ ខ្ញុំចូលធ្វើការនៅម៉ោង៧ ព្រឹក រហូតដល់ថ្ងៃត្រង់ទើបសម្រាកហូបបាយ។ នៅពេល រសៀល ខ្ញុំបន្តរែកដីរហូតដល់ម៉ោង៥ ទើបឈប់ ហូបបាយ។ ខ្ញុំពិបាកស្វែងរកទឹកផឹកខ្លាំងណាស់ព្រោះ មនុស្សច្រើនហើយអណ្ដូងមានតែមួយ។ ខ្ញុំត្រូវរង់ចាំ មួយម៉ោងទៅពីរម៉ោងទម្រាំបានទឹកកន្លះធុងយកមក ផឹក។ ខ្ញុំស្លៀកពាក់ខោអាវដដែលៗ បណ្ដាលឲ្យកើត មានចៃសាចនៅលើកលើខ្នងលើក្លៀកនិងចង្កេះព្រោះ គ្មានទឹកផឹកជម្រះខ្លួន។ ពេលផឹកទឹកហើយ ប្រធានកង ដឹកនាំឲ្យខ្ញុំទៅចូលរួមប្រជុំ រហូតដល់ម៉ោង១២ ឬ ម៉ោង ១យប់។ យើងអង្គុយងោក ហើយព្រឹកឡើង យើងធ្វើការទាំងងងុយដេក។ ពេលខ្លះយើងជំពប់ ជើងបណ្ដាលឲ្យខ្ទាយដីពីបង្គី។ ចំណែកអាហារ គឺខ្ញុំ ទទួលបបរខាប់មួយវែក និងសម្លមួយចានចែកគ្នា ៥នាក់។ ខ្ញុំហូបមិនគ្រាន់ទេ ដូច្នេះខ្ញុំលួចខ្សឹបប្រាប់

សមាជិកក្នុងកងជាមួយគ្នាឲ្យលួចបេះស្លឹកឈើ និងបន្លែពេលចេញពីប្រជុំដើម្បីយកឲ្យខ្ញុំស្លឲ្យហូប។ ខ្ញុំមិនហ៊ានស្លឲ្យប្រធានកងដឹងទេ។ ប្រសិនបើប្រធានកងដឹង យើងប្រាកដជាស្លាប់ទាំងអស់គ្នាមិនខាន។ ខ្ញុំប្រាប់ឲ្យអ្នកនៅក្នុងកងជាមួយចាំមើលផ្លូវ ចំណែកខ្ញុំគឺជាអ្នកដាំស្ល។ ពេលសម្លកំពុងតែពុះ ហើយប្រធានកងចល័តជិះកង់មក អ្នកចាំមើលផ្លូវត្រូវស្រែកប្រាប់ថា មកហើយរឿយ! នៅពេលខ្ញុំឮដូច្នេះ ខ្ញុំត្រូវចាក់ទឹករំលត់ភ្លើង។ នៅពេលខ្លះប្រធានកងចល័តស្រែកសួរថា នារីអើយកំពុងធ្វើអី ខ្ញុំឆ្លើយតបវិញថា គ្មានធ្វើអីទេបង ខ្ញុំរៀបចូលដេកហើយ។ ឮដូច្នេះប្រធានកងចល័តក៏ជិះផុតទៅ ទើបខ្ញុំបង្កាត់ភ្លើងស្លម្តងទៀត។ យើងឃ្លានយ៉ាងខ្លាំង និងភិតភ័យផង ទម្រាំតែសម្លឆ្អិន។ ខ្មែរក្រហមបានបែកចំនួនមនុស្សទៅតាមក្រុមរួមមាន ៖ «ក», «ខ», «គ», និង «ឃ» ។ ក្រុម «ក» មានចំនួនសមាជិកតិចជាងគេ គឺ១០នាក់។ ក្រុម «ខ» មានសមាជិកចំនួន ៣០នាក់ ហើយក្នុងមួយ «គ» មាន ៣ «ខ» មានសមាជិកចាប់ពី ៩០នាក់ ទៅមួយរយនាក់ជាង។ ខ្ញុំនៅក្នុងក្រុម «ខ»។

នៅពេលដែលនរណាម្នាក់ប្រព្រឹត្តខុស ដំបូងខ្មែរក្រហមយកអ្នកនោះទៅព្រមាននិងធ្វើការទិតៀនក្នុងចំណោមប្រជាជននៅក្នុងឃុំដែលអង្គុយជារង្វង់ ហើយអ្នកដែលប្រព្រឹត្តខុសខ្មែរក្រហមឲ្យអង្គុយនៅចំកណ្តាល។ ខ្មែរក្រហមឲ្យប្រជាជនមើលអ្នកប្រព្រឹត្តខុស ហើយកុំឲ្យប្រជាជនយកគំរូតាម។ នៅពេលនោះមានមន្ទីរសន្តិសុខមួយស្ថិតនៅម្តុំស្ពានអូរក្រញូង ឬវត្តបុស្សីសាញ់។ ខ្មែរក្រហមនាំអ្នកទោសនៅស្រុកកំពង់រោទិ៍ មកឃុំនៅមន្ទីរសន្តិសុខវត្តបុស្សីសាញ់។ ខ្ញុំធ្លាប់ឃើញកងចល័តឈ្មោះ ក្រឹង អតីតទាហានលន់ នល់ ដែលនៅលីវ។ ក្រឹង ឃើញកន្ទុយបារីដែលគេបោះចោលលើដី ក៏ទៅរើសយកមកជក់។ ពេលនោះ មានកងចល័តម្នាក់ស្រែកប្រាប់ថា «អ្ហែងប្រយ័ត្ន តែគេឃើញដឹងតែមានទោសហើយ» ។ ប្រឹង តបវិញថា «ស្អីអើយ គ្រាន់តែបារីបោះចោលចឹងគ្នារើសជក់ម៉ា ហឹតចឹងក៏មានទោសដែរ» ស្របពេលដែលប្រធានសន្តិសុខជិះកង់មកពីក្រោយ ចំណែកប្រធានកងមិនមាត់កទេ។ លុះដល់ពេលល្ងាច ខ្មែរក្រហមហៅឈ្មោះ ក្រឹង មកអង្គុយកណ្តាលហ្វូងប្រជុំ។ ប្រធានអង្គប្រជុំលើកឡើងថា «មិត្តឯងសាហាវណាស់ មិត្តឯងឃ្លានណាស់ ឥឡូវយើងយកថ្នាំជក់ដែលដាំបានមកមូរជាមួយសន្លឹកសៀវភៅពីរសន្លឹកឲ្យមិត្តឯងជក់ឲ្យឆ្អែត។ មិត្តឯងមិនត្រូវបង្ហុយផ្សែងចោលទេ គឺបឺតផ្សែងចូលក្នុងពោះ»។ នៅពេលប្រធានអង្គប្រជុំនិយាយចប់ កងឈ្លបយកបារីឲ្យ ក្រឹង បឺត។ គ្រាន់តែ ក្រឹង បឺតតែមួយភ្លែតក៏ប្រកាច់នៅនឹងមុខអង្គប្រជុំ។ ប្រជាជនផ្អើលឈូរឆរ ខណៈនោះប្រធានកងស្រែកថា «មិត្តៗត្រូវនៅឲ្យស្ងៀម» គ្រាន់តែឮដូច្នេះប្រជាជនក៏អង្គុយចុះវិញ។ មួយសន្ទុះក្រោយមក ក្រឹង ដឹងខ្លួនឡើងវិញ រួចកងឈ្លបយកគាត់ទៅដាក់នៅមួយកន្លែងដោយមានឆ្មាំម្នាក់ចាំយាម។ ព្រលឹមឡើងខ្មែរក្រហមយក ក្រឹង ចេញទៅ ហើយចាប់តាំងពីថ្ងៃនោះមកបាត់ ក្រឹង រហូត។

វេលាថ្ងៃមួយ ខ្ញុំឈឺគ្រុន ហើយលេបថ្នាំដែលខ្មែរក្រហមចែកឲ្យមិនបានធូរស្បើយ ខ្ញុំក៏ទៅរកអ្នកនៅក្នុងកងជាមួយកោសខ្យល់ឲ្យ។ កាលនោះ ខ្ញុំកោសខ្យល់តែជាមួយទឹកប៉ុណ្ណោះ ព្រោះគ្មានប្រេង។ ពីរថ្ងៃក្រោយមក ខ្ញុំចេញទៅធ្វើការវិញ ព្រោះមានកងឈ្លបខ្មែរក្រហមតាមសង្កេតមើល អ្នកណាឈឺពិតប្រាកដឬធ្វើពុត ប្រសិនបើធ្វើពុតជាឈឺកងឈ្លបនឹងកត់ឈ្មោះ រួចយកអ្នកជំងឺនោះទៅដាក់មួយឡែក។ នៅពេលដែលកងឈ្លបយកទៅហើយអ្នកជំងឺនោះដឹងតែបាត់ដំណឹងហើយ។

នៅរដូវច្រូតស្រូវ ខ្មែរក្រហមចាត់តាំងឲ្យក្រុមនារី និងយុវជនទៅច្រូតស្រូវនៅព្រំដែនវៀតណាម។ យើងច្រូតស្រូវទាំងយប់ងងឹតដោយមិនហ៊ានតមាត់ឡើយ។ យើងពិបាកចងកណ្តាប់ណាស់ដោយសារយប់ងងឹតមើលមិនឃើញ ដូច្នេះយើងប្រមូលស្រូវដែលច្រូតបានដាក់ចូលគ្នាដើម្បីចងជាកណ្តាប់ រួចហើយទើបបែងចែកកណ្តាប់គ្នា។ នៅពេលប្រធានក្រុមសួរថា តើមិត្តច្រូតបានប៉ុន្មានកណ្តាប់? ខ្ញុំឆ្លើយតបថា

ប្រូតបានពីរកណ្តាប់។ ប្រធានក្រុមបញ្ជាខ្ញុំឲ្យប្រូតស្រូវថែមទៀតដើម្បីបានត្រឡប់ទៅផ្ទះវិញ។ នៅយប់ទីពីរ ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យទៅប្រូតស្រូវនៅកន្លែងដដែល យប់នោះវៀតណាមបានដឹង និងបាញ់ត្រូវកងចល័តម្នាក់ឈ្មោះ ណិ ធ្លុះភ្លៅ។ កងចល័តបាននាំគ្នារត់ ចំណែកឈ្មោះ ណិ បានស្រែកហៅខ្ញុំឲ្យជួយ «បងៗជួយខ្ញុំផងៗ» ព្រោះត្រូវគ្រាប់រត់មិនរួច។ ខ្ញុំទៅជួយគ្រាគាត់។ ពេលនោះវៀតណាមនៅតែបន្តបាញ់ក្បែរៗជើងរបស់ខ្ញុំ។ ខ្ញុំគ្រា ណិ ដើរបានចម្ងាយប្រហែលបាន១៥០ម៉ែត្រ ប្រធាន«ខ» មកជួយគ្រាបន្តទៀត ហើយ ណិ នៅតែអរគុណខ្ញុំមកដល់បច្ចុប្បន្ន។

មានថ្ងៃមួយ ប្រពន្ធពូ មុន្នី ទៅស៊ុងនៅកន្លែងខ្ញុំដែរ។ គាត់មាត់រអិលណាស់ នៅពេលឃើញមេឃស្រទំនិងពពកខ្មៅ គាត់និយាយថា «ឱលោកអើយលោកភ្លៀងមកឲ្យច្រើនមក ហើយរន្ទះបាញ់ពួកអាយួនឲ្យងាប់ឲ្យអស់ទៅ កុំឲ្យវាបាញ់ខ្មែរ» ស្រាប់តែផ្លេកបន្ទោរប្រាវមកបាញ់ចំគាត់ស្លាប់តែម្តង។ ប្រជាជននាំគ្នានិយាយថា នៅកន្លែងនៅនោះមានអ្នកថែរក្សា។ នៅពេលយប់ ខ្មោចប្រពន្ធ ពូមុន្នី លងបន្លាចអ្នកភូមិសឹងគ្រប់គ្នា។ ខ្ញុំក៏ធ្លាប់ខ្មោចប្រពន្ធ ពូមុន្នី លងបន្លាចដែរ ហើយចាប់តាំងពីពេលនោះមកទើបខ្ញុំជឿថាមានខ្មោចលង។

ពូរបស់ខ្ញុំម្នាក់គឺជាទាហាន លន់ នល់ ត្រូវបានខ្មែរក្រហមយកទៅរៀនសូត្រ ហើយបាត់ដំណឹងរហូត។ តាមការពិតខ្មែរក្រហមយកគាត់ទៅវាយសម្លាប់ចោល ព្រោះខ្ញុំឃើញសាកសពមនុស្សជាច្រើននៅក្នុងអណ្តូង។ ខ្ញុំធ្លាប់ឃើញឈ្លបខ្មែរក្រហមវាយសម្លាប់ឈ្មោះ សារិន ជាប់និន្នាការជាគ្រូបង្រៀន និងប្រពន្ធរបស់គាត់នៅក្រោលគោដែរ។ កងឈ្លបយកគាត់ទៅវាយទាំងយប់ ព្រោះខ្ញុំឮសូរសម្រែកស្រែកអូយៗ។ ព្រឹកឡើងបាត់គ្រូ សារិន និងប្រពន្ធរបស់គាត់ រួមទាំងកូនពីរនាក់ទៀតឈ្មោះ សូរិយា និង ចន្ទ្រា គឺនៅរស់តែកូនច្បងឈ្មោះ ង៉ោ ល ម្នាក់ប៉ុណ្ណោះ ព្រោះ ង៉ោ ល ធ្វើការនៅកងចល័តផ្សេង។ ព្រឹកឡើង ង៉ោ ល មករកឪពុកម្តាយនិងប្អូនៗអត់ឃើញក៏យំ។ ង៉ោ ល យំមិនហ៊ានឲ្យប្រធានកងដឹងឡើយព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់ទៀត។

នៅឆ្នាំ១៩៧៩ ខ្ញុំនាំគ្រួសារដើរត្រឡប់មកស្រុកកំណើតវិញ។ ខ្ញុំធ្វើដំណើរបានចម្ងាយ ២០គីឡូម៉ែត្រក៏នាំគ្នាសម្រាក បន្ទាប់មកទើបបន្តដំណើរទៀត។ ខ្ញុំមកដល់ភូមិស្វាយតាភ្លុំដំបូងមិនទាន់មានប្រជាជនមករស់នៅច្រើនទេ ព្រោះម្ចាស់ផ្ទះត្រូវបានខ្មែរក្រហមជម្លៀសទៅស្រុកឆ្ងាយមិនទាន់ត្រឡប់មកវិញ ចំណែកប្រជាជនខ្លះក៏មិនត្រឡប់មកស្រុកដែរ។ ខ្ញុំនិងគ្រួសារនាំគ្នាធ្វើស្រែចម្ការ និងបន្តរស់នៅភូមិស្វាយតាភ្លុំរហូតមកដល់បច្ចុប្បន្ន។



ផ្ទះរបស់ គង់ សារិន នៅឃុំបាសាក់
ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ខែសីហា ឆ្នាំ២០២១។
(ស៊ុខ ចន្ទ្រា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សួន ពិន ៖ គ្រូថ្នាំបុរាណក្នុងរបបខ្មែរក្រហម

*កែវ ស្រីណុច*



សួន ពិន ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ កែវ ស្រីណុច អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តកំពត។ ភូមិថ្នង់ ឃុំបន្ទាយមាស ខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត ។
(កែវ ស្រីណុច/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សួន ពិន ភេទប្រុស អាយុ៨០ឆ្នាំ។ ខ្ញុំមានស្រុកកំណើតនៅភូមិថ្នង់ ឃុំបន្ទាយមាសខាងកើត ស្រុកបន្ទាយមាស ខេត្តកំពត។ កាលពីក្មេង ខ្ញុំរៀនសូត្របានតិចតួចប៉ុណ្ណោះ។ នៅពេលដែលខ្ញុំមានអាយុ ១៨ឆ្នាំ ខ្ញុំសម្រេចចិត្តបួសជាព្រះសង្ឃ ហើយសឹកវិញនៅពេលដែលខ្ញុំមានអាយុ២៩ឆ្នាំ។ ក្នុងសម័យ លន់ នល់ ខ្ញុំរៀបការជាមួយប្រពន្ធរបស់ខ្ញុំឈ្មោះ មួ ខន ស្របពេលដែលសង្គ្រាមស៊ីវិលបានផ្ទុះឡើងរវាងក្រុមខ្មែរក្រហម និងរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ នៅឆ្នាំ១៩៧៣ ក្រុមគ្រួសាររបស់ខ្ញុំបានបរទេះគោភៀសខ្លួនទៅរស់នៅខាងជើងស្រុកឈូក ព្រោះនៅក្នុងភូមិខ្ញុំមានយន្តហោះទម្លាក់គ្រាប់បែកជាច្រើន។ ខ្ញុំរស់នៅខាងជើងស្រុកឈូករហូតដល់ចុងឆ្នាំ១៩៧៤ បន្ទាប់មកខ្ញុំនិងគ្រួសាររបស់ខ្ញុំបានវិលត្រឡប់មករស់នៅស្រុកកំណើតវិញ ដោយចាប់ផ្តើមធ្វើស្រែបង្កបង្កើនផលចិញ្ចឹមជីវិត។

នៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះឡើងកាន់កាប់អំណាច នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ

១៩៧៥ មានប្រជាជនជាច្រើនត្រូវខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញនិងទីប្រជុំជនមកកាន់ជនបទ។ នៅក្នុងភូមិថ្មង់ដែលខ្ញុំរស់នៅមានប្រជាជនថ្មី (ប្រជាជន ១៧ មេសា) ប្រហែលជាង៣០គ្រួសារ ត្រូវបានខ្មែរក្រហមជម្លៀសមករួមទាំងជនជាតិភាគតិចចាម និងចិន។ ខ្មែរក្រហមបានធ្វើទុក្ខបុកម្នេញ និងលត់ដំប្រជាជនថ្មីយ៉ាងខ្លាំង។ ជនជាតិភាគតិចចាម ដែលគោរពសាសនាអ៊ីស្លាមហើយតមមិនបរិភោគសាច់ជ្រូក ត្រូវខ្មែរក្រហមបង្ខិតបង្ខំឲ្យហូបសាច់ជ្រូក និងសាច់ឆ្កែ។ ខ្មែរក្រហម ព្យាយាមធ្វើយ៉ាងណាឲ្យតែកើតមានទំនាស់ជាមួយនឹងប្រជាជនដើម្បីយកលេសនាំជនជាតិភាគតិចចាមដែលមិនគោរពបញ្ជាទៅសម្លាប់ចោល។ ជនជាតិភាគតិចចាមទាំងអស់នាំគ្នាហូបសាច់ជ្រូកព្រោះខ្លាចកម្មាភិបាលខ្មែរក្រហមចោទថាជាខ្មាំងហើយនាំយកទៅសម្លាប់។ ចំណែកជនជាតិភាគតិចចិនជាច្រើននាក់ ត្រូវកម្មាភិបាលខ្មែរក្រហមយកសម្លាប់ទាំងគ្មានកំហុស ដើម្បីឲ្យប្រជាជនដទៃទៀតខ្លាចរអាកម្មាភិបាលខ្មែរក្រហម។

ខ្ញុំត្រូវកម្មាភិបាលខ្មែរក្រហមចាត់តាំងឲ្យធ្វើជាពេទ្យជំនាញថ្នាំបុរាណ។ ទោះបីជាខ្ញុំគឺជាពេទ្យ ប៉ុន្តែស្ថានភាពរបស់ខ្ញុំក៏មិនខុសប្លែកពីប្រជាជនផ្សេងទៀតដែរ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យខ្ញុំរស់នៅជួបជុំជាមួយគ្រួសារទេ។ យើងត្រូវទៅធ្វើការងារដាច់ដោយឡែកពីគ្នា។ នៅពេលនោះ គ្មាននរណាអាចជួយនរណាបានឡើយ។ មនុស្សភាគច្រើនប្រកាន់ខ្ជាប់ក្នុងចិត្តថា «ក្បាលនរណា សក់អ្នកនោះ»។ ខ្ញុំរស់នៅរងទុក្ខវេទនាបំផុតនៅក្នុងរបបខ្មែរក្រហម។ ខ្ញុំត្រូវខ្មែរក្រហមប្រើឲ្យដើររកថ្នាំ និងស្លថ្នាំ។ ក្រៅពីនេះ ខ្មែរក្រហមបានប្រើឲ្យខ្ញុំធ្វើជីសម្រាប់ដាក់ស្រូវ ដែលជីនោះផ្សែផ្សំពីលាមកមនុស្ស។ កម្មាភិបាលខ្មែរក្រហម មានចេតនាធ្វើយ៉ាងណាឲ្យតែខ្ញុំមានទំនាស់ដើម្បីរកលេសចោទថាខ្ញុំគឺជាខ្មាំងប្រឆាំងអង្គការ និងយកខ្ញុំទៅសម្លាប់ចោល។ ខ្ញុំមានសំណាង ព្រោះខ្ញុំមិនបានធ្វើការងារវែកដីដូចប្រជាជនដទៃទៀត។ ការងាររបស់ខ្ញុំ គឺយកថ្នាំចែកជូនឲ្យប្រជាជនណាដែលឈឺលេបព្យាបាលជំងឺ។ ថ្នាំនៅក្នុងសម័យខ្មែរក្រហមគឺមានថ្នាំអាចម៍ទន្សាយផ្សំចេញពីឫសឈើដែលមានរូបរាងមូលតូចដូចអាចម៍ទន្សាយ និងមានថ្នាំស្លមួយមុខទៀត។ រាល់ពេលដែលមានអ្នកជំងឺឈឺធ្ងន់មិនមានថ្នាំសម្រាប់ព្យាបាល គ្រូពេទ្យតែងតែយកទឹកដូងជំនួសឲ្យសេរ៉ូមចាក់ឲ្យអ្នកជំងឺ។ នៅពេលដែលមានអ្នកជំងឺត្រូវបានសែងមកដល់មន្ទីរពេទ្យ គ្រូពេទ្យតែងតែរត់ទៅហៅគ្រូខ្មែរ ព្រោះគ្រូពេទ្យសម័យនោះមិនមានសមត្ថភាពព្យាបាលជំងឺទេ។

ខ្ញុំនៅចាំបានថាថ្ងៃមួយ នារីកងចល័តម្នាក់ដែលជាអ្នកកាប់ដើមទន្ទ្រានខែត្រធ្វើជីនៅក្នុងភូមិត្នោតចុងស្រង់បានចាប់យកគីង្គក់មកអាំងហូបដោយមិនបានសម្អាតឡើយ ព្រោះដោយសារតែភាពស្រេកឃ្លានខ្លាំងពេក។ នារីនោះហូបបណ្តើរនិយាយបណ្តើរថា «ឆ្ងាញ់ណាស់ៗ» ហើយហូបអស់គីង្គក់អាំងមួយម្នាក់ឯង។ បន្ទាប់ពីហូបគីង្គក់អាំងរួច នារីនោះក៏ពុលពងគីង្គក់ ហើយរួញអណ្តាតនិយាយលែងរួច។ ពេទ្យនៅកងចល័តបានសែងនារីនោះមកដល់មន្ទីរពេទ្យនៅភូមិពោធិ៍ ហើយពេទ្យមករកថ្នាំរបស់ខ្ញុំ។ នៅក្នុងក្បួនគម្ពីរថ្នាំខ្មែរសរសេរថា «យកអាចម៍គោសម្បុរខ្មៅ ទៅកូរជាមួយទឹករួចច្រោះយកកាកចេញ ហើយយកទឹកដែលច្រោះរួចនោះផឹក»។ ក្នុងកាលៈទេសៈបង្ខំដូច្នេះ ខ្ញុំមិនអាចរកគោសម្បុរខ្មៅបានទេ ខ្ញុំបានសម្រេចចិត្តយកអាចម៍គោសម្បុរសមកធ្វើថ្នាំឲ្យអ្នកជំងឺផឹកជំនួសវិញ។ សំណាងល្អ នារីដែលពុលគីង្គក់នោះបានជាឡើងវិញ ហើយវាគឺជារឿងហួសចិត្តណាស់សម្រាប់ខ្ញុំ។

ក្រោយពីរបបខ្មែរក្រហមបានដួលរលំនៅឆ្នាំ ១៩៧៩ ខ្ញុំបានត្រឡប់មករស់នៅជួបជុំក្រុមគ្រួសារប្រពន្ធកូនវិញ ដោយប្រកបមុខរបរធ្វើស្រែចម្ការ និងដាំបន្លែ។ រហូតមកដល់សព្វថ្ងៃ ខ្ញុំមានកូន៧ នាក់។ កូនៗរបស់ខ្ញុំរៀបការអស់ហើយ។ បច្ចុប្បន្ននេះ ខ្ញុំរស់នៅតែពីរនាក់ប្តីប្រពន្ធប៉ុណ្ណោះ។

# អ្នកស្ម័គ្រចិត្តកម្ពុជានាំយកកញ្ចប់អនុស្សាវរីយ៍
## ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តស្វាយរៀង

*សោម ប៊ុនថន*







អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តស្វាយរៀង ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខែតុលា ឆ្នាំ២០២១។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តស្វាយរៀង)

នៅវេលាព្រឹក ថ្ងៃពុធ ទី២០ ខែតុលា ឆ្នាំ២០២១ សោម ប៊ុនថន ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានដឹកកញ្ចប់អនុស្សាវរីយ៍ចំនួន៣០០ពីការិយាល័យនៅទីក្រុងភ្នំពេញយកទៅចែកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលក្រុមអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាប្រចាំខេត្តស្វាយរៀង បានជួបសម្ភាសន៍។ បច្ចុប្បន្នក្រុមអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន៣២នាក់ នៅស្រុករមាសហែក, ស្រុកស្វាយទាប, ស្រុករំដួល, ស្រុកចន្ទ្រា, ស្រុកកំពង់រោទ៍, ស្រុកស្វាយជ្រំ និងក្រុងស្វាយរៀង នៃខេត្តស្វាយរៀង កំពុងសម្ភាសន៍ និងសួរនាំយាយតាឪពុកម្ដាយអំពូមីង អំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម និងបញ្ហាសុខភាព ដោយអនុវត្តតាមវិធានការពារកុំពារការពាររបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលកម្ពុជា។ អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាប្រចាំខេត្តស្វាយរៀងនឹងបន្តសម្ភាសន៍ និងនាំយកកញ្ចប់អនុស្សាវរីយ៍ រួមមាន១) ព្រឹត្តិបត្រព័ត៌មានណែនាំអំពីសុខភាព, ២) ដែល, ៣) សាប៊ូលាងដៃ, ៤) ម៉ាស់, ៥) នំ, ៦) សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩), ៧) សៀវភៅអំពើប្រល័យពូជសាសន៍និងការសម្លាប់រង្គាលនៅក្នុងប្រវត្តិសាស្ត្រពិភពលោក, ៨) ឧបករណ៍សង្គ្រោះបឋម, ៩) សេវាកម្មពិនិត្យសុខភាពនៅ


















អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តស្វាយរៀង ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខែតុលា ឆ្នាំ ២០២១ ។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តស្វាយរៀង)

តាមមន្ទីរពេទ្យឯកជនក្នុងសហគមន៍ដោយឥតគិតថ្លៃ, និង ១០) សម្ភារជំនួយដល់ជនពិការ ទៅចែកជូនដល់យាយតាឪពុកម្តាយអ៊ំពូមីងដែលរស់នៅតំបន់ដាច់ស្រយាលក្នុងខេត្តស្វាយរៀងដោយផ្ទាល់ដៃ។

# អ្នកស្ម័គ្រចិត្តកម្ពុជាចែកកញ្ចប់អនុស្សាវរីយ៍ ជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខេត្តកំពង់ឆ្នាំង

**យី សុយី**












អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តកំពង់ឆ្នាំង ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅខែតុលា ឆ្នាំ២០២១ ។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តកំពង់ឆ្នាំង)

ពីថ្ងៃទី៣០ ដល់ថ្ងៃទី៣១ ខែតុលាឆ្នាំ ២០២១ ក្រុមការងារអ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំខេត្តកំពង់ឆ្នាំង បានរៀបចំប្រអប់អនុស្សាវរីយ៍ចំនួន៦៥០ ប្រអប់ ចែកជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រួមមាន៖ លោកយាយ លោកតា អ៊ំពូ មីង ដែលបានផ្ដល់បទសម្ភាសន៍ទាក់ទងនឹងរឿងរ៉ាវពីរបបខ្មែរក្រហម និងសុខភាព ក្នុងនោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងស្រុកបរិបូណ៌ ទទួលបាន ៣៥៨ ប្រអប់, ស្រុកទឹកផុស ទទួលបាន១២២ ប្រអប់, ស្រុករលាប្អៀរ ទទួលបាន៣៦ ប្រអប់, ស្រុកកំពង់លែង ទទួលបាន ១៧ ប្រអប់, ស្រុកកំពង់ត្រឡាច ទទួលបាន ៦១ប្រអប់ និងស្រុកសាមគ្គីមានជ័យ ទទួលបាន ៥៦ប្រអប់។

ខ្ញុំនិងក្រុមការងារអ្នកស្ម័គ្រចិត្តកម្ពុជាប្រចាំខេត្តកំពង់ឆ្នាំង សូមគោរពថ្លែងអំណរគុណ លោកយាយ លោកតា អ៊ិំពូ មីង ដែលបានចំណាយពេលនិយាយរឿងរ៉ាវដែលឆ្លងកាត់ និងចងចាំនៅក្នុងរបបខ្មែរក្រហម។








អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ខេត្តកំពង់ឆ្នាំង ចែកកញ្ចប់អនុស្សាវរីយ៍ជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅថ្ងៃទី៣០ ដល់ ថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០២១។ (អ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តកំពង់ឆ្នាំង)








# នួន មិន៖ ជាប់ទោសនៅទួលស្រេញទាំង មិនដឹងពីទោសកំហុសពិតប្រាកដ

*ផេង ពង្សរ៉ាស៊ី*



នួន មិន ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ ភូមិបឹងក្រទឹប ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ខែតុលា ឆ្នាំ២០២១។ (ផេង ពង្សរ៉ាស៊ី /មជ្ឈមណ្ឌលឯកសារកម្ពុជា)

អស់រយៈពេលជាង៤០ឆ្នាំក្រោយរបបខ្មែរក្រហមដួលរលំ និងជាង៤០ឆ្នាំក្រោយជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខទួលស្រេញ នួន មិន មិនដែលមានសុខភាពល្អប្រសើរឡើយ។ ឆ្នាំនេះ គាត់មានអាយុ៧៦ឆ្នាំហើយ ហើយបញ្ហាសុខភាពរបស់គាត់ក៏កាន់តែទ្រុឌទ្រោមជាងឆ្នាំមុនៗដែរ។ គាត់ខស្បាហ៍ឈឺ និងចុកចាប់ខ្លួនប្រាណដោយសារស្នាមរបួសចាស់រើឡើងវិញ។ សព្វថ្ងៃ មិនរស់នៅជាមួយប្រពន្ធនិងកូនៗ ក្នុងផ្ទះឈើប្រក់សង្កសីតូចល្មមមួយនៅក្នុងភូមិកំណើតរបស់គាត់ គឺភូមិបឹងក្រទឹប ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ មិន មិនអាចប្រកបការងារអ្វីបានឡើយក្នុងពេលបច្ចុប្បន្ន។ គាត់រស់នៅពឹងផ្អែកលើប្រាក់ចំណូលបន្តិចបន្តួចដែលបានមកពីការធ្វើស្រែចម្ការ និងការឧបត្ថម្ភពីកូនៗ ដែលកំពុងធ្វើកម្មករសំណង់នៅភ្នំពេញ។ ជាមួយនឹងភាពគ្រាំគ្រាដោយសារការធ្វើទារុណកម្មរបស់ខ្មែរក្រហម មិនមានជំងឺប្រចាំកាយមួយទៀត គឺជំងឺរបេង។ រូបរាងកាយរបស់គាត់មានសភាពស្គមស្គាំង ដង្ហើមខ្លី និងទន់ជ្រាយ។ ដោយសារតែជំងឺប្រចាំកាយនេះហើយ ទើប

គាត់មិនត្រូវបានអនុញ្ញាតឲ្យទទួលវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូចអ្នកភូមិឯទៀតៗ។

កាលពីជាង៤៧ឆ្នាំមុនគឺក្នុងខែមេសា ឆ្នាំ១៩៧៤ មិន ត្រូវបានចោទប្រកាន់ពីកម្មាភិបាល គឺជាកងសន្តិសុខស្រុកកំពង់ត្របែកឈ្មោះ គង់ ថាគាត់មានជាប់ពាក់ព័ន្ធនឹង «សន្តិសម្ព័ន្ធ» ហើយត្រូវបញ្ជូនខ្លួនទៅកាន់វត្តសំព័រក្នុងភូមិទ័ពសៀម ឃុំកន្សោមអក ស្រុកកំពង់ត្របែក ដើម្បីឃុំឃាំងនិងសួរចម្លើយ។ ស្ថិតក្នុងការឃុំឃាំងក្នុងបរិវេណវត្តសំព័រ មិន ត្រូវកងសន្តិសុខខ្មែរក្រហមម្នាក់ឈ្មោះ ម៉ែន ពុត គឺជាកងសន្តិសុខស្រុកកំពង់ត្របែកធ្វើទារុណកម្មយ៉ាងដំណំក្នុងពេលសួរចម្លើយ។ ពុត គឺជាអ្នកភូមិជាមួយ មិន និងជាមនុស្សធ្លាប់រាប់អានគ្នាយ៉ាងជិតដិត។ ដោយមូលហេតុខ្លួនមិនបានប្រព្រឹត្តកំហុសដូចការចោទប្រកាន់ មិន មិនបានឆ្លើយតបទៅនឹងសំណួរដែលសួរថា៖ «តើឯងពិតជាជាប់ពាក់ព័ន្ធនឹង សន្តិសម្ព័ន្ធ ជាមួយខ្មាំងមែនអត់?»។ មិន ត្រូវកងសន្តិសុខប្រចាំវត្តសំព័រ សួរចម្លើយបីដង ហើយគាត់ក៏ទទួលរងការធ្វើទារុណកម្មគ្រប់ពេលសួរចម្លើយដែរ ដោយសារតែបានផ្តល់ចម្លើយដែលកងសន្តិសុខមិនចង់បាន។ មិនបានរំឭកប្រាប់ថា៖ «អា ពុត វាវាយខ្ញុំនឹងខ្សែតីសម្រាប់វាត់ក្របី។ ខ្នងរបស់ខ្ញុំរបកស្បែកគ្រប់ពេលដែលវាវាយខ្ញុំម្តងៗ»។ ការធ្វើទារុណកម្ម គឺមិនមែនមានតែមួយប្រភេទទេ។ ក្រៅពីរំពាត់ខ្សែតី ពុត នៅមានដែកភ្លៅរទេះមួយទៀតដែលតែងតែដាក់ជាប់ខ្លួនជានិច្ចរាល់ពេលចល័តពីកន្លែងមួយទៅកន្លែងមួយទៀត។ បើតាមការផ្តល់ព័ត៌មានពីអតីតអ្នកទោសទួលម្រេញចំនួនពីរនាក់ផ្សេងទៀតដែលយើងបានជួបគឺ សុខ សុផល និង ទែន ឡាង បានឲ្យដឹងដូចគ្នាថា ពុត បានប្រើប្រាស់ដែកភ្លៅរទេះនេះសម្លាប់អ្នកទោសដែលជាប់ឃុំនៅក្នុងមន្ទីរសន្តិសុខទួលម្រេញអស់ជាច្រើននាក់ ហើយ ពុត តែងតែយកដែកភ្លៅរទេះនោះតាមខ្លួនជានិច្ចគ្រប់ពេលដែលខ្លួនធ្វើដំណើរចេញចូលក្នុងមន្ទីរសន្តិសុខម្តងៗ។

នៅខែឧសភា ឆ្នាំ១៩៧៤ មិន ត្រូវផ្លាស់ប្តូរទៅកាន់មន្ទីរសន្តិសុខទួលម្រេញជាមួយអ្នកទោសប្អូនប្រាំនាក់ផ្សេងទៀត។ កងសន្តិសុខម្នាក់មានស្ពាយកាំភ្លើងផង បានបណ្តើរ មិន និងអ្នកទោសប៉ុន្មាននាក់ទៀតកាត់វាលស្រែជាច្រើនឆ្ពោះមកកាន់មន្ទីរសន្តិសុខទួលម្រេញ។ មិន បានបញ្ជាក់ថាការផ្លាស់ប្តូរនេះគឺដោយសារមូលហេតុគាត់ និងអ្នកឯទៀតមិនព្រមឆ្លើយទៅនឹងសំណួរទាក់ទងនឹងពាក្យ «សន្តិសម្ព័ន្ធ»។ មិនបានប្រាប់ថា គាត់ក្នុងពេលនោះនៅតែមិនយល់ពាក្យចោទប្រកាន់នេះ ថាមានន័យយ៉ាងដូចម្តេចឡើយ។ ដើរបណ្តើរ គិតបណ្តើរ ប៉ុន្តែនៅតែគិតមិនយល់ពីអត្ថន័យនៃពាក្យ «សន្តិសម្ព័ន្ធ» ដដែលៗ។ មកដល់បរិវេណមន្ទីរសន្តិសុខទួលម្រេញ មិន បានរៀបរាប់ថាគាត់ បានឃើញទិដ្ឋភាពដ៏គួរឲ្យភ័យខ្លាចនិងនឹកស្មានមិនដល់ថាមានមនុស្សរាប់រយនាក់កំពុងជាប់ឃុំឃាំងនៅទីនោះឡើយ។ នៅក្នុងបរិវេណមន្ទីរសន្តិសុខ មិនបានមើលឃើញរោងឃុំឃាំងអ្នកទោសស្ត្រីមួយ រោងឃុំឃាំងអ្នកទោសបុរសមួយ មន្ទីរសួរចម្លើយមួយ មន្ទីររោងបាយមួយ និងមន្ទីរធ្វើការរបស់កម្មាភិបាលមួយ។ ក្រៅពីនេះ គាត់ សង្កេតឃើញអ្នកទោសរាប់រយនាក់កំពុងធ្វើពលកម្មទាំងជើងជាប់ខ្នោះខ្លះ និងមិនមានខ្នោះខ្លះ។

តាមរបាយការណ៍ស្រាវជ្រាវពីទីតាំងឧក្រិដ្ឋកម្មប្រព្រឹត្តដោយខ្មែរក្រហម នៅទូទាំងប្រទេសកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំ១៩៩៧ បានបង្ហាញថា មន្ទីរសន្តិសុខទួលម្រេញ បានលេចរូបរាងឡើងនៅឆ្នាំ១៩៧៣ ដោយមានឈ្មោះមួយទៀតថា «មន្ទីរសន្តិសុខតំបន់២៤» របស់ខ្មែររំដោះ។ ចាប់តាំងពីពេលដែលមន្ទីរសន្តិសុខនេះបង្កើតឡើងរហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឆ្មាំគុកនៅមន្ទីរសន្តិសុខនេះ ឃុំឃាំងនិងសម្លាប់អ្នកទោសរាប់រយនាក់ ដែលអ្នកទាំងនោះជាប្រភេទប្រជាជនមូលដ្ឋានមកពីភូមិឃុំនានាក្នុងស្រុកមួយចំនួន ក្នុងខេត្តព្រៃវែង ក្រោមការចោទប្រកាន់ពីបទដូចៗគ្នាគឺ «សន្តិសម្ព័ន្ធ»។ ពីឆ្នាំ១៩៧៥ រហូតដល់ដើមឆ្នាំ១៩៧៨ អ្នកទោសដែលជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខនេះ គឺមានទាំងប្រជាជនចាស់ដែលជាប់ពាក់ព័ន្ធនឹង «សន្តិសម្ព័ន្ធ» រស់នៅក្នុងខេត្តព្រៃវែង

និងប្រជាជនថ្មីដែលបានជម្លៀសមកពីទីក្រុងភ្នំពេញ ព្រមទាំងប្រជាជនជាច្រើននាក់ផ្សេងទៀតមកពីខេត្តស្វាយរៀង។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧៨ មកកងសន្តិសុខនៅក្នុងមន្ទីរនេះបានសម្លាប់អ្នកទោសទ្រុងង បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏អ្នកទោសដែលជាប្រជាជនមូលដ្ឋានមួយចំនួន ត្រូវបានដោះលែងឲ្យរួចខ្លួនពីមន្ទីរឃុំឃាំងនិងការសម្លាប់ ហើយបានវិលត្រឡប់មកកាន់ភូមិស្រុកជួបជុំគ្រួសារវិញ។ តាមរបាយការណ៍ដដែលបានបង្ហាញថា ក្រោមការគ្រប់គ្រងមន្ទីរសន្តិសុខរបស់សមមិត្ត និន, សឹម, កែវ, សាម៉ាន់, ម៉ែនពុត, និង ណាវ ដែលជាកម្មាភិបាលទទួលបន្ទុកសន្តិសុខប្រចាំស្រុកកំពង់ត្របែក មានអ្នកទោសរាប់ពាន់នាក់ត្រូវបានសម្លាប់នៅទីតាំងមួយចំនួនក្នុងស្រុកកំពង់ត្របែក និងជុំវិញមន្ទីរសន្តិសុខទួលម្រេញដូចជា ត្រពាំងត្នោត ត្រពាំងឈូក ទួលច្រេះ ទួលរកា ត្រពាំងរុនឫស្សីជួរ និងឫស្សីចិន ហើយរណ្តៅសាកសពទាំងអស់ត្រូវបានគាស់កកាយឡើងដើម្បីរកមាស និងវត្ថុមានតម្លៃចេញពីខ្លួនសាកសព នៅក្រោយឆ្នាំ១៩៧៩។

នួន មិន និងអ្នកភូមិបីបួននាក់ទៀត ត្រូវបានចាប់ខ្លួននិងបញ្ជូនទៅកាន់មន្ទីរសន្តិសុខទួលម្រេញក្នុងថ្ងៃតែមួយនៅខែមេសា ឆ្នាំ១៩៧៤ ដោយមូលហេតុជាប់ពាក់ព័ន្ធនឹងសន្តិសម្ព័ន្ធ។ នៅក្នុងមន្ទីរសន្តិសុខទួលម្រេញ មិន បានទទួលរងទារុណកម្មតែម្តងគត់ បន្ទាប់ពីគាត់បានទទួលរងទារុណកម្មចំនួនបីលើកនៅក្នុងមន្ទីរសន្តិសុខវត្តសំព័រ។ ក្នុងពេលសួរចម្លើយនៅទួលម្រេញ កម្មាភិបាលសួរចម្លើយ បានសួរសំណួរដដែលទៅកាន់ មិន ថា«តើឯងជាប់ពាក់ព័ន្ធនឹងសន្តិសម្ព័ន្ធ អ្វីខ្លះ?»។ សម្រាប់ មិន សំណួរនេះនៅតែជាសំណួរដែលពិបាកឆ្លើយបំផុត ព្រោះគាត់មិនបានយល់ច្បាស់ពីពាក្យសន្តិសម្ព័ន្ធ។ គាត់នៅតែរកចម្លើយឆ្លើយប្រាប់ទៅកម្មាភិបាលសន្តិសុខមន្ទីរវិញមិនបាន។ មិន តែងតែសួរត្រឡប់ទៅកាន់អ្នកសួរចម្លើយវិញថា តើ «សន្តិសម្ព័ន្ធ» មានន័យយ៉ាងដូចម្តេច? ហើយចម្លើយតបចំពោះសំណួររបស់ មិន ក៏ត្រូវបានឆ្លើយត្រឡប់មកវិញដែរ។ ចាប់តាំងពីសួរចម្លើយលើកដំបូង មិន បានទទួលចម្លើយខុសៗគ្នាទាក់ទងនឹងការពន្យល់ពាក្យ «សន្តិសម្ព័ន្ធ» ដែលចម្លើយទាំងនោះ ត្រូវបាន មិន រៀបរាប់ថា មិនជាប់ពាក់ព័ន្ធនឹងសកម្មភាពប្រចាំថ្ងៃដែលគាត់បានធ្វើមុនពេលចាប់ខ្លួនឡើយ។ ចុងបញ្ចប់នៃការសួរចម្លើយ មិន នៅតែជាអ្នកដែលទទួលរងនូវការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរបំផុតដដែល។ មិន ត្រូវកងសន្តិសុខប្រចាំមន្ទីរប្រើឲ្យធ្វើពលកម្មធ្ងន់ៗនៅជុំវិញមន្ទីរ និងឆ្ងាយពីមន្ទីរ មុនពេលដែលគាត់ត្រូវបានបញ្ជូនឲ្យទៅកាន់មន្ទីរឃុំឃាំងទួលវែងបន្តទៀត។ ថ្ងៃមួយ ក្នុងពេលដែល មិន កំពុងធ្វើពលកម្មឆ្ងាយពីមន្ទីរសន្តិសុខ គាត់បានជួបជាមួយអ្នកទោសវ័យចំណាស់ម្នាក់ដែលបានជាប់ក្នុងមន្ទីរឃុំឃាំងទួលម្រេញមុនគាត់។ អ្នកទោសវ័យចំណាស់ម្នាក់នោះ បានខ្សឹបប្រាប់ មិន ឲ្យឆ្លើយតាមអ្វីដែលក្រុមសន្តិសុខចង់បានដើម្បីឆាប់បានរួចខ្លួនពីមន្ទីរឃុំឃាំង។ មិន មិនបានយកចិត្តទុកដាក់ស្តាប់ចំពោះពាក្យទាំងនេះឡើយ ព្រោះគាត់គិតថា គាត់ពុំបានធ្វើអ្វីដែលខុសទៅនឹងវិន័យ បម្រាម ឬក្បត់នឹងចលនាខ្មែររំដោះឡើយ។

ក្នុងអំឡុងខែមករា ឆ្នាំ១៩៧៥ មិន ត្រូវកងសន្តិសុខបញ្ជូនឲ្យទៅជាប់ឃុំឃាំងបន្តនៅក្នុងមន្ទីរសន្តិសុខទួលវែង ស្ថិតក្នុងឃុំជាំងដែក ស្រុកកំពង់ត្របែក។ នៅទីនោះ មិន ត្រូវសួរចម្លើយម្តងទៀតអំពីសកម្មភាពដែលជាប់ពាក់ព័ន្ធនឹងសន្តិសម្ព័ន្ធជាមួយខ្មាំង។ ដូចលើកមុនៗដែរ មិនបានសួរត្រឡប់ទៅកាន់កងសន្តិសុខពីអត្ថន័យពាក្យ «សន្តិសម្ព័ន្ធ»។ លើកនេះមិនបានទទួលចម្លើយខុសពីចម្លើយមុនៗ ដែលចម្លើយលើកក្រោយនេះត្រូវគ្នានឹងអ្វីដែលគាត់បានប្រព្រឹត្តកាលពីគាត់មិនទាន់ត្រូវបានចាប់ខ្លួន។ មិន បានរំពឹកឡើងវិញពីចម្លើយរបស់អ្នកសួរចម្លើយ ប្រាប់ថា៖ «សន្តិសម្ព័ន្ធមានន័យថា សមមិត្តឯង! គេប្រើឲ្យធ្វើអ្វីក៏មិនធ្វើ ហើយគេស្នើសុំអ្វីក៏មិនឲ្យគេ»។ ចុងបញ្ចប់ មិន បានស្វែងយល់ច្បាស់ពីពាក្យនេះ ហើយបានឆ្លើយសារភាពប្រាប់ទៅអ្នកសួរចម្លើយថា គាត់ពិតជាជាប់ពាក់ព័ន្ធនឹង សន្តិសម្ព័ន្ធមែន គឺបានប្រកែកជាមួយគណៈឃុំជាញឹកញាប់ចំពោះការស្នើសុំឲ្យ

គាត់ធ្វើកិច្ចការផ្សេងៗក្នុងឃុំ និងធ្លាប់បានបដិសេធជាមួយកម្មាភិបាលឃុំដែរចំពោះការស្នើសុំប្រើប្រាស់របស់របរផ្ទាល់ខ្លួនគាត់។ ចម្លើយសារភាពនេះ បានធ្វើឲ្យគាត់បានរួចខ្លួនពីការឃុំឃាំង ហើយគាត់ត្រូវបានដោះលែងមកផ្ទះវិញនៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៥។

ស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ដោយសារតែគាត់មានប្រវត្តិជាប់គុកនៅទួលស្រែញ មិន ត្រូវបានចាត់ចូលក្នុងប្រភេទប្រជាជនថ្មី និងស្ថិតក្រោមការតាមដានជាប្រចាំពីកម្មាភិបាលមូលដ្ឋាន។ គាត់ត្រូវធ្វើកិច្ចការធ្ងន់ៗជាច្រើនប្រភេទ និងមិនទទួលបានរបបអាហារគ្រប់គ្រាន់ឡើយ។ នៅចុងឆ្នាំ១៩៧៨ មិន និងគ្រួសារបានផ្លាស់ប្តូរទីលំនៅជាញឹកញាប់តាមបញ្ជារបស់ខ្មែរក្រហម។ ប៉ុន្តែគាត់មិនបានជាប់ក្នុងបញ្ជីឈ្មោះដែលត្រូវបញ្ជូនទៅកាន់ខេត្តពោធិ៍សាត់ឡើយ។ ការផ្លាស់ទីលំនៅរបស់ មិន ចុងក្រោយ គឺផ្លាស់ទៅកាន់ទីប្រជុំជនអ្នកលឿង។ នៅទីនោះ គាត់ត្រូវបានកងកម្លាំងស្ម័គ្រចិត្តវៀតណាមកៀងឲ្យត្រឡប់មកកាន់ស្រុកកំណើតវិញជាមួយប្រជាជនឯទៀត។ នៅឯស្រុកកំណើត អាជ្ញាធរឃុំជាងដែកត្រូវបានរៀបចំឡើងវិញ ហើយអតីតកម្មាភិបាលខ្មែរក្រហមកម្រិតមូលដ្ឋាន រាប់ចាប់តាំងពីគណៈឃុំរហូតដល់ប្រធានរោងបាយ ត្រូវបានស្នើសុំឲ្យចូលខ្លួននៅក្នុងអង្គមីទ្ទីញមួយ ដើម្បីនិយាយសារភាពពីទោសកំហុសដែលខ្លួនបានប្រព្រឹត្តកាលពីពេលកន្លងមក នៅចំពោះមុខហ្វូងមនុស្សរាប់ពាន់នាក់ដែលសុទ្ធសឹងតែជាប្រជាជនធ្លាប់ទទួលរងគ្រោះដោយសារតែកម្មាភិបាលទាំងនោះ ក្នុងន័យសុំការអនុគ្រោះនិងយល់យោគពីអ្នកភូមិ ចំពោះទោសកំហុសដែលបានកើតឡើងនាពេលកន្លងមក។ មិន បានចូលរួមនៅក្នុងអង្គមីទ្ទីញនោះ។ គាត់មានចិត្តមិនស្ងប់ទាល់តែសោះ ហើយមិនចង់ស្តាប់ការសារភាពទោសកំហុសរបស់អ្នកទាំងនោះឡើយ។ គាត់បានប្រាប់ថា គាត់មានបំណងប្រាថ្នាចង់សងសឹងទៅលើឈ្មោះ គង់ ដែលបានចាប់គាត់កាលពីឆ្នាំ១៩៧៤។ ក្រៅពី មិន នៅមានអ្នកភូមិជាច្រើននាក់ទៀតដែលមានចិត្តចង់សងសឹកចំពោះអតីតកម្មាភិបាលទាំងនោះ។ ប៉ុន្តែបំណងប្រាថ្នាទាំងអស់ ត្រូវបានរារាំងពីអាជ្ញាធរឃុំ។ បន្ទាប់ពីអង្គមីទ្ទីញបញ្ចប់ទៅ អតីតកម្មាភិបាលខ្មែរក្រហមមួយចំនួនបានបង្វិចិត្តផ្លាស់ប្តូរទីលំនៅទៅរស់នៅកន្លែងផ្សេង ហើយអ្នកខ្លះទៀតបានបន្តស្នាក់នៅក្នុងភូមិរហូតដល់ពេលបច្ចុប្បន្ន។ មិន បានឲ្យដឹងថា អតីតកម្មាភិបាលខ្មែរក្រហមភាគច្រើនបានស្លាប់បាត់បង់ជីវិតអស់ហើយ។

ក្នុងជំនួបជាមួយ មិន កាលពីពេលថ្មីៗនេះ គាត់នៅចងចាំយ៉ាងច្បាស់ពីទិដ្ឋភាពមន្ទីរឃុំឃាំង និងបទពិសោធន៍ជីវិតរបស់គាត់ក្រោមការធ្វើទារុណកម្មពីកម្មាភិបាលខ្មែរក្រហមដែលជាអ្នករាប់អានគ្នាស្និទ្ធស្នាល។ មិន នៅតែមានការគុំគួន និងចង់សងសឹកទៅលើឈ្មោះ គង់ និង ពុត ដដែល។ ប៉ុន្តែគាត់នៅតែមិនអាចសម្រេចបំណងប្រាថ្នាបាន ព្រោះ គង់ បានផ្លាស់ប្តូរទីលំនៅទៅកាន់កន្លែងផ្សេង ហើយបាត់ដំណឹងរហូតដល់បច្ចុប្បន្ន។ ចំណែក ពុត ត្រូវបានបាញ់សម្លាប់ចោល ទាំងដែលជាប់ចំណង បន្ទាប់ពីបានលោតចេញពីលើទូកចម្លងមួយចូលទៅក្នុងទឹកនៅឯកំពង់ចម្លងអ្នកលឿងក្នុងគោលបំណងសម្លាប់ខ្លួន។




នួន មិន ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម និងសុខភាពដល់អ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តព្រៃវែង។ ភូមិបឹងក្រទីប ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ខែតុលា ឆ្នាំ២០២១។ (ផេង ពងរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប៉ូយ សុត ៖ អនុប្រធានកងចល័តភូមិរំចេក

**ហ៊ាន ពិសី**

ខ្ញុំឈ្មោះ ប៉ូយ សុត ភេទប្រុស អាយុ៦៣ឆ្នាំ។ ខ្ញុំរស់នៅភូមិរំចេក ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ភូមិរំចេក គឺជាភូមិដ៏ចំណាស់មួយ ហើយកាលពីមុនសម្បូរដើមឈើធំៗ និងសត្វព្រៃរស់នៅ។ ប្រជាជននៅភូមិនេះភាគច្រើនរស់នៅដោយប្រកបរបរធ្វើស្រែចម្ការ និងបរបាញ់សត្វ។

ខ្ញុំមិនបានសិក្សារៀនសូត្រទេ ដោយសារសង្គ្រាមបានកើតឡើង។ នៅឆ្នាំ១៩៧០ ភូមិរំចេកស្ថិតក្រោមការគ្រប់គ្រងរបស់ខ្មែររំដោះ ដឹកនាំដោយឈ្មោះ រ៉ុង និងមនុស្ស៤នាក់ទៀត។ រ៉ុង បានដឹកនាំប្រជាជនឲ្យចូលរួមសកម្មភាពផ្សេងៗ និងបង្ហាត់បង្រៀនប្រជាជនឲ្យយល់ដឹងអំពីនយោបាយរបស់ខ្មែរក្រហម។ រ៉ុង បង្កើតឲ្យមានមន្ទីរស្នូរថ្នាំបុរាណមួយកន្លែង មានទីតាំងស្ថិតនៅចម្ងាយ៥០០ម៉ែត្រពីភូមិរំចេក។ ប្រជាជនដែលមានវ័យចាស់ៗក្នុងភូមិត្រូវបាន រ៉ុង ជ្រើសរើសឲ្យចូលរួមស្ម័គ្រចិត្តធ្វើជាគ្រូពេទ្យស្នូរថ្នាំ។ ចំណែកយុវជនយុវជនមួយចំនួនត្រូវបានឲ្យចូលក្នុងក្រុមសិល្បៈស្រុក ដែលមានគ្រូ ឈ្មោះ នាង គឺជាអ្នកបង្ហាត់បង្រៀន។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះនៅទីក្រុងភ្នំពេញ រ៉ុង បានឡើងតំណែងធ្វើជាគណៈស្រុកអន្លង់វែង ដែលមានឈ្មោះ ម៉ែន គឺជានីរសារ។ ខ្មែរក្រហមបង្កើតឲ្យមានជាសហករណ៍នៅក្នុងភូមិ ដែលអ្វីៗគ្រប់យ៉ាងត្រូវចាត់ចូលជាសម្បត្តិរួមទាំងអស់។ ខ្មែរក្រហមបានបញ្ចូលខ្ញុំ និងប្រជាជនផ្សេងទៀតឲ្យក្នុងកងចល័តស្រុកអន្លង់វែង ដោយមានឈ្មោះ រ៉ុង គឺជា



ប៉ូយ សុត រស់នៅភូមិរំចេក ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (សូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នកដឹកនាំ។ យើងលើកភ្លឺស្រែ នៅតាមភូមិជាច្រើន រួមមាន ភូមិរហាល ភូមិលំទង និងភូមិផ្អាវ។ នៅឆ្នាំ១៩៧៧ ខ្ញុំឮដំណឹងមកថា មេដឹកនៅភូមិភាគឧត្តរក្បត់។ ក្រោយមក រ៉ុង បានបាត់ខ្លួននិងគ្មាននរណាម្នាក់ទទួលដំណឹងពី រ៉ុង ឡើយ។ តាវ៉ន គឺជាកម្មាភិបាលមកពីភូមិភាគនិរតី ចូលមកគ្រប់គ្រងជំនួស ដោយមានឈ្មោះ ម៉ែន គឺជានីរសារដដែល។ បន្ទាប់មកទៀត តាវ៉ន ធ្វើការជ្រើសរើសខ្ញុំឲ្យឡើងធ្វើជាអនុប្រធានក្រុមកងចល័ត។ តាវ៉ន បែកកន្សែងសូត្រមួយ ស្បែកជើង

មួយគូ និងសម្លៀកបំពាក់មួយឈុតឲ្យខ្ញុំ។ កិច្ចការងារជាអនុប្រធានកងចល័តក្រៅពីដឹកនាំក្រុមកងចល័តធ្វើការហើយ ខ្ញុំត្រូវឡើងទៅប្រជុំជារៀងរាល់ខែ។ ការប្រជុំនេះគឺខ្ញុំត្រូវរាយការណ៍អំពីសកម្មភាពការងារផ្សេងៗដែលយើងបានធ្វើនៅក្នុងកងចល័ត។ ជាទូទៅខ្ញុំពុំសូវរាយការណ៍ត្រង់ៗនោះទេ ខ្ញុំតែងតែលាក់បាំងរាល់កំហុសរបស់ប្រជាជនមួយចំនួនដែលបានប្រព្រឹត្ត ព្រោះខ្ញុំមានការអាណិតអាសូរដល់អ្នកភូមិ ដែលត្រូវខ្មែរក្រហមយកទៅដាក់ទោស។ ទោះបីខ្ញុំព្យាយាមលាក់បាំងយ៉ាងណា ក៏មិនអាចជួយបានគ្រប់គ្នាដែរ។ អ្នកភូមិឈ្មោះ លឿន និង ឡូន ត្រូវបានខ្មែរក្រហមដាក់ពិន័យបន្តុំបាយ ព្រោះតែអ្នកទាំងពីរឈប់សម្រាកមុនម៉ោងធ្វើការ។ ឈ្មោះ រឿន ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ដោយសារលួចលាក់មានស្នេហាធ្វើឲ្យខុសសីលធម៌។

ចាប់តាំងពីពេលដែលកម្មាភិបាលមកពីភូមិភាគនិរតីចូលមកគ្រប់គ្រង ជីវិតរបស់ប្រជាជនមានការលំបាកថែមមួយកម្រិតទៀត។ ការងារគ្រប់យ៉ាងគឺត្រូវដាក់ឲ្យយើងធ្វើដោយមិនគិតពេលវេលា។ ខ្ញុំនៅចាំថា បន្ទាប់ពីយើងហូបបាយពេលល្ងាចរួច ខ្មែរក្រហមចាប់ផ្ដើមគោះជួងឲ្យយើងចុះធ្វើការបន្តទៀតដោយគិតចាប់ពីម៉ោង៧យប់ ទៅដល់ពាក់កណ្ដាលអធ្រាត្រ។ ការហូបចុក បើទោះបីខ្ញុំជាអនុប្រធានកងចល័ត ក៏ខ្ញុំនៅតែទទួលបានរបបអាហារពីរពេលដូចទៅនឹងប្រជាជនឯទៀតដែរ។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមជម្លៀសខ្ញុំនិងប្រជាជនចេញពីអន្លង់វែង ទៅកាន់ស្រុកក្រឡាញ់ខេត្តសៀមរាប។ មុនពេលជម្លៀស តាវ៉ន បានធ្វើការប្រជុំនិងសួរទៅកាន់ប្រជាជនទាំងអស់ថា «តើមាននរណាដែលចង់រស់នៅអន្លង់វែងនេះបន្ត? ប្រសិនបើមានខ្មែរក្រហមនឹងបែកដីឲ្យនៅ? នីម បានឲ្យដំណឹងមកខ្ញុំ និងប្រជាជនមុនថា ប្រជាជននឹងត្រូវសម្លាប់ប្រសិនបើមិនព្រមជម្លៀសចេញទៅតាមការស្នើរបស់អង្គការ។ ខ្ញុំនិងប្រជាជនផ្សេងទៀតយល់ព្រមដោយមិនស្ទាក់ស្ទើរនៅក្នុងការជម្លៀសទៅកាន់ស្រុកក្រឡាញ់។ ខ្មែរក្រហមបានជម្លៀសយើងឲ្យមករស់នៅភូមិដំណាក់ខ្លាស់ ហើយធ្វើការនៅទីនោះ។ លុះដល់រដូវវស្សាភូមិដំណាក់ខ្លាស់ ត្រូវលិចទឹកពិបាករស់នៅ ខ្មែរក្រហមក៏ជម្លៀសយើងឲ្យមកទប់ទំនប់នៅក្នុងស្រុកក្រឡាញ់វិញ។ ពេលទៅដល់ការដ្ឋានលើកទំនប់ ខ្ញុំឃើញមានមនុស្សយ៉ាងច្រើនដែលកំពុងស៊ិតស៊ាញក្នុងការធ្វើការងារលើកទំនប់។ អាហារហូបចុកពិតជាពិបាកណាស់សម្រាប់ខ្ញុំនិងប្រជាជនជាច្រើនផ្សេងទៀត។ យើងទាំងអស់គ្នានឹងត្រូវបន្តុំបាយ ប្រសិនបើការងារលើកទំនប់មិនទាន់រួចរាល់ទៅតាមផែនការដែលកំណត់។ យើងពុំមានផ្ទះសម្បែងរស់នៅត្រឹមត្រូវឡើយ យើងតែងតែសម្រាកនៅក្រោមដើមឈើឬនៅតាមគុម្ពោតព្រៃ។ លុះក្រោយមកយើងត្រូវបានជម្លៀសចេញពីស្រុកក្រឡាញ់ទៅកាន់ឃុំសំបួរវិញម្ដង។

នៅដើមឆ្នាំ១៩៧៩ ពេលដែលវៀតណាមវាយលុកចូលមកដល់ប្រទេសកម្ពុជា ខ្ញុំនិងប្រជាជនទាំងអស់នៅឃុំសំបួរចាប់ផ្ដើមបែកខ្ញែកគ្នាអស់។ ខ្ញុំ និងគ្រួសារបានរត់ភៀសខ្លួនមកកាន់ស្រុកវ៉ារិន ដោយប្រើរយៈពេល៥យប់៥ថ្ងៃទើបទៅដល់។ យើងរស់នៅស្រុកវ៉ារិនបានរយៈពេល២ខែ ទើបខ្ញុំនិងគ្រួសារសម្រេចចិត្តវិលមកភូមិរំចេកដែលជាភូមិកំណើតវិញ។ ការធ្វើដំណើរគឺស្ថិតនៅក្នុងស្ថានភាពលំបាកវេទនាបំផុតសម្រាប់យើង ដោយសារយើងពុំមានអាហារសម្រាប់ហូបចុកគ្រាប់គ្រាន់។ យើងនាំគ្នាជីកក្ដួចមកធ្វើជាអាហារហូបដើម្បីរស់ជីវិត។ បើទោះបីជាលំបាកយ៉ាងនោះ ក៏ខ្ញុំតែបន្តរស់នៅភូមិរំចេករហូតដល់ខ្ញុំរៀបការនៅឆ្នាំ១៩៨១ ។

ក្រោយមកនៅឆ្នាំ១៩៨៣ វៀតណាមចាប់ផ្ដើមចូលមកដល់ស្រុកអន្លង់វែង។ ដូច្នេះប្រជាជនទាំងអស់ត្រូវបានខ្មែរក្រហមជម្លៀសចេញទៅកាន់ស្រែណូយ ស្រុកវ៉ារិនជាថ្មីម្ដងទៀត។ លុះឆ្នាំ១៩៩០ ខ្ញុំ

និងគ្រួសារ ប្រជាជនជាច្រើននាក់ផ្សេងៗទៀតត្រូវបានបញ្ជូនពីស្រែណូយមករស់នៅភូមិអូរតាម៉ែច ស្រុកអន្លង់វែងវិញ ដោយមាន តាម៉ុក គឺជាអ្នកគ្រប់គ្រង។ ចាប់តាំងពីពេលនោះមកជីវិតយើងមានភាពប្រសើរជាងមុន។ យើងមានអាហារហូបចុកគ្រាប់គ្រាន់។ តាម៉ុក បានអនុញ្ញាតឲ្យយើងដាំដំណាំទុកសម្រាប់ផ្គត់ផ្គង់គ្រួសារបានថែមទៀត។ នៅឆ្នាំ១៩៩៨ អន្លង់វែងក៏ចាប់ផ្តើមធ្វើសមាហរណកម្មបញ្ចប់សង្គ្រាម។ ខ្ញុំនិងប្រជាជនទាំងអស់នៅអន្លង់វែង មានសេរីភាពពេញលេញនៅក្នុងការរស់នៅ និងលែងមានសង្គ្រាមរ៉ាំរ៉ៃដូចពីពេលមុនទៀត។



ផ្ទះរបស់ ប៉ូយ សុត នៅភូមិរំចេក ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។
(ស្ទូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ប៉ូយ សុត ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់ ហ៊ាន ពិសី អ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ ភូមិរំចេក ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។
(ស្ទូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពិធីបង្សុកូលថ្វាយព្រះរាជកុសលដល់សម្តេច ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ

## ព្រះវររាជបិតាជាតិខ្មែរ នៅវត្តលង្កា

*សុភ័ក្ត្រ ភាណា*





លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា, ឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ អេ. ហែលជ្រេស និង សម្តេចព្រះធម្មលិខិតបណ្ឌិត សៅរ៍ ចន្ទដុល្ល ព្រះចៅអធិការ វត្តលង្កា និមន្តចូលរួមពិធីបង្សុកូលថ្វាយព្រះរាជកុសលដល់ សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ នៅវត្តលង្កា នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ អេ. ហែលជ្រេស អតីតអ្នកសរសេរព្រះរាជជីវប្រវត្តិរបស់សម្តេចព្រះ បរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតា ជាតិខ្មែរ និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌល

ឯកសារកម្ពុជា នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ បានចូលរួមប្រារព្ធពិធីបង្សុកូលថ្វាយព្រះរាជកុសលដល់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ នៅវត្តលង្កា។ ពិធីបង្សុកូលនេះទទួលបានការចូលរួមពីសំណាក់ពុទ្ធបរិស័ទយាយជីតាជី និងព្រះសង្ឃ។

វត្តលង្កា នឹងប្រារព្ធពិធីបង្សុកូលថ្វាយព្រះរាជកុសលដល់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ ជារៀងរាល់ឆ្នាំ។











លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា, ឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ អេ. ហែលជ្រេស និងសម្តេចព្រះធម្មលិខិតបណ្ឌិត សៅរ៍ ចន្ទផុល្ល ព្រះចៅអធិការវត្តលង្កា និមន្តចូលរួមពិធីបង្សុកូលថ្វាយព្រះរាជកុសលដល់សម្តេចព្រះបរមរតនកោដ្ឋ នរោត្តម សហនុ ព្រះវររាជបិតាជាតិខ្មែរ នៅវត្តលង្កា នាព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មាស ពៅ ៖ នារីរោងចក្រនៅក្នុងរបបខ្មែរក្រហម

**មេក វិន**

មាស ពៅ ភេទស្រី អាយុ៦៦ឆ្នាំ មានស្រុកកំណើតនៅភូមិតាំងបន្ទាយ ឃុំវាលពន់ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ ពៅ បច្ចុប្បន្នរស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ពៅ បាននិយាយរៀបរាប់ពីការតស៊ូ និងបទពិសោធន៍របស់ខ្លួនក្នុងសម័យខ្មែរក្រហមដូចខាងក្រោម៖

កាលពីកុមារភាព ខ្ញុំរស់នៅក្នុងគ្រួសារមួយដែលមានជីវភាពធូរធារ។ ខ្ញុំគឺជាក្មេងស្រីម្នាក់ដែលរៀនបានខ្ពស់ជាងគេក្នុងចំណោមបងប្អូនទាំងអស់។ ខ្ញុំមានបងប្អូនបង្កើតចំនួន៨នាក់ ហើយខ្ញុំគឺជាកូនពៅ។ ថ្វីត្បិតតែគ្រួសាររបស់ខ្ញុំមានជីវភាពធូរធាក៏ពិតមែន ប៉ុន្តែការប្រកបមុខរបរធ្វើស្រែចម្ការមិនដែលខកខាននោះឡើយ។ ឪពុករបស់ខ្ញុំមិនសូវជាមានពេលទំនេរក្នុងការជួយធ្វើស្រែចម្ការប៉ុន្មានទេ ព្រោះគាត់ជាក្រុមប្រឹក្សាឃុំដែលត្រូវទៅធ្វើការជាប្រចាំ។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ខ្ញុំមើលឃើញថាការរស់នៅមានភាពសម្បូរសប្បាយ និងមានភាពកក់ក្តៅនៅក្នុងគ្រួសារ ជាពិសេសប្រជាជនមានសិទ្ធិសេរីភាពក្នុងការរស់នៅប្រចាំថ្ងៃ។ ក្នុងឆ្នាំ១៩៦៨ ខ្ញុំផ្អាកការសិក្សាមួយរយៈដោយសារកងទ័ព លន់ នល់ ផ្តាច់ផ្លូវ និងស្ពានមួយចំនួនដែលជាហេតុធ្វើឲ្យសិស្សគ្រប់គ្នាមិនអាចធ្វើដំណើរបាន។ កាលណោះ ខ្ញុំទើបតែមានអាយុ១៦ឆ្នាំ។ ភាពវឹកវរនេះចេះតែកើតមានជាបន្តបន្ទាប់រហូតដល់ឆ្នាំ១៩៧០ នៅតាមសាលារៀនមិនថាអនុវិទ្យាល័យ ឬវិទ្យាល័យទេត្រូវបិទទាំងស្រុង។ ចំណែកឯគ្រូបង្រៀនក៏បែកខ្ញែកគ្នាដែរ។



មាស ពៅ រៀបរាប់រឿងរ៉ាវរបស់គាត់ប្រាប់ មេក វិន អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ អន្លង់វែង ខែតុលា ឆ្នាំ២០២១។ (សូត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅចន្លោះឆ្នាំ១៩៧១ និងឆ្នាំ១៩៧២ នៅក្នុងភូមិតាំងបន្ទាយ មានការទម្លាក់គ្រាប់បែកយ៉ាងសន្ធោសន្ធៅ។ កាលណោះ ខ្ញុំនិងគ្រួសារមិនទាន់ជម្លៀសចេញពីភូមិកំណើតទេ ប្រជាជននៅក្នុងភូមិអាចចេញទៅធ្វើស្រែម្តងម្កាល។ នៅពេលដែលយន្តហោះមកទម្លាក់គ្រាប់បែកនៅវាលស្រែម្តងៗ ខ្ញុំរួមទាំងអ្នកភូមិដទៃទៀតដែលកំពុងដកសំណាបនាំគ្នារត់គេចគ្រាប់បែក បេ៥២ ដែលទាហាន លន់ នល់ បានទម្លាក់។

ការទម្លាក់គ្រាប់បែកនេះធ្វើឲ្យខូចខាតទ្រព្យសម្បត្តិសម្ភារ និងធ្វើឲ្យស្លាប់ប្រជាជនក្នុងភូមិព្រៃម៉ិចអស់ជាច្រើននាក់។

នៅដើមឆ្នាំ១៩៧៣ ខ្ញុំបានសម្រេចចិត្តចូលខាងខ្មែរក្រហម។ បន្ទាប់មក ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅរោងចក្រស្ករសក្រុងខ្ទង់ដុង្គ ខេត្តកំពង់ស្ពឺ។ ចាប់តាំងពីពេលនោះមក ខ្ញុំត្រូវបានចាកចេញពីស្រុកកំណើត និងឃ្លាតឆ្ងាយពីឪពុកម្តាយបងប្អូនរហូតមក។ ចំណែកឪពុកម្តាយរបស់ខ្ញុំត្រូវបានជម្លៀសចេញទៅខេត្តកោះកុង។ បន្ទាប់មក ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើជាមេក្រុមកិនអំពៅ និងរែកស្ករ។ ក្នុងមួយក្រុមខ្ញុំមានសមាជិកចំនួន១០នាក់ មានទាំងប្រុសទាំងស្រី។ ការហូបចុកមិនមានការខ្វះខាតឡើយ ថែមទាំងមានបន្ថែមមានដូចជា ស្ករស ល្ពៅ និងដំឡូង។ ក្នុងមួយថ្ងៃ ខ្ញុំហូបអាហារចំនួនបីដង ហើយកម្មករទាំងអស់អាចជ្រើសរើសហូបបាយ ឬបបរ។ កាលណោះ ប្រធានមន្ទីរនៅក្នុងរោងចក្រស្ករសឈ្មោះ ឆយ។ ការគ្រប់គ្រងរបស់ ឆយ ល្អណាស់គឺមិនដែលស្តីបន្ទោស ឬវាយធ្វើបាបកម្មករទេ។ ខ្ញុំធ្វើការក្នុងរោងចក្រស្ករស រហូតដល់ឆ្នាំ១៩៧៥ ខ្មែរក្រហក៏ទទួលជ័យជម្នះ។ បន្ទាប់មកទៀត ខ្ញុំរួមទាំងកម្មករជាច្រើននាក់ បានធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញ។ កាលនោះ ប្រធានមន្ទីរយកឡានមកដឹកកម្មករក្នុងមួយឡានមានកម្មករចំនួន៣០នាក់។ នៅពេលដែលខ្ញុំធ្វើដំណើរទៅដល់ភ្នំពេញ ខ្ញុំឃើញផ្សែងភ្លើងដែលកំពុងឆេះ និងផ្ទះថ្មដែលបាក់បែក។ លើសពីនេះ ខ្ញុំធំក្លិនស្អុយចេញពីសាកសពនៅទីនោះ។ ប្រជាជនដែលរស់នៅទីក្រុងភ្នំពេញត្រូវបានខ្មែរក្រហមជម្លៀសទៅជនបទទាំងអស់។ បន្ទាប់ពីខ្ញុំស្នាក់នៅទីនោះរយៈពេលមួយសប្តាហ៍ ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅធ្វើការនៅរោងចក្រធ្វើមង ស្ថិតនៅជិតវិទ្យាល័យបាក់ទូក។ កាលណោះ កម្មករដែលធ្វើការនៅក្នុងរោងចក្រធ្វើមង មានចំនួន៣០០នាក់។ ប្រធានគ្រប់គ្រងនៅរោងចក្រមង ឈ្មោះ តុង។ គាត់គឺជាមនុស្សមានសីលធម៌ល្អ មិនដែលបង្ខំឲ្យកម្មករធ្វើការធ្ងន់ៗឡើយ។ ចំពោះការហូបចុក ខ្ញុំទទួលបានការផ្គត់ផ្គង់របបអាហារគ្រប់គ្រាន់។ មិនតែប៉ុណ្ណោះ តុង បានបញ្ជាឲ្យចុងភៅធ្វើម្ហូបជារៀងរាល់ថ្ងៃសម្រាប់ក្រុមកម្មករទាំងអស់។ នៅព្រឹកព្រលឹម ចុងភៅឆាមីសួរទុកឲ្យកម្មករម្នាក់មួយចានៗជារៀងរាល់ថ្ងៃ។ នៅពេលដែលកម្មាភិបាលក្រសួងពាណិជ្ជកម្ម វ៉ន វ៉េត ចុះមកទស្សនកិច្ចម្តងៗ តុង មិនដែលរាយការណ៍ប្រាប់ពីកម្មករដែលមានភាពខ្ជិលច្រអូស មិនធ្វើការទៅដល់ វ៉ន វ៉េត ឡើយ។ មងដែលយើងផលិតបានត្រូវបញ្ជូនទៅតាមសហករណ៍និងតំបន់។ ជារៀងរាល់ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ខ្ញុំរួមទាំងកម្មករដទៃទៀតត្រូវទៅកាប់ដី ជីកប្រឡាយ លើកភ្លឺដើម្បីធ្វើស្រែ។ នៅពេលទំនេរពីការងារ កម្មករក្នុងរោងចក្រធ្វើមង អាចដាំបន្លែ និងឪឡឹកទុកសម្រាប់ហូបខ្លួនឯងបានថែមទៀត។

ពេលរដូវវស្សាចូលមកដល់ ខ្ញុំនិងកម្មករដទៃទៀតនាំគ្នាឡើងទៅទន្លេរយៈពេលកន្លះខែទៅមួយខែដើម្បីធ្វើប្រហុក និងផ្អកចំនួន១០០ពាង ទុកសម្រាប់ហូបក្នុងរោងចក្រធ្វើមង។ កាលណោះខ្ញុំឮកម្មករធ្វើការនៅក្នុងរោងចក្រកង់នាំគ្នានិយាយពីការយកមនុស្សទៅសម្លាប់ចោល និងយកទៅដាក់គុកព្រៃស។ មិនត្រឹមតែប៉ុណ្ណោះ ថែមទាំងបានប្រាប់ខ្ញុំកុំឲ្យធ្វើអ្វីខុសពីបទបញ្ជារបស់ប្រធាន ឬធ្វើខុសសីលធម៌នៅក្នុងរោងចក្រ។ ខ្ញុំធ្វើការក្នុងរោងចក្រមងរហូតដល់ឆ្នាំ១៩៧៩ កងទ័ពវៀតណាមវាយចូលមកដល់ទីក្រុងភ្នំពេញ។ ខ្ញុំរួមទាំងកម្មករជាច្រើននាក់ទៀតបានធ្វើដំណើរចាកចេញពីភ្នំពេញដោយថ្មើរជើង។ ប្រជាជនជាច្រើននាក់បានដើរលើផ្លូវថ្នល់បន្តបន្ទាប់គ្នារាប់ពាន់នាក់សំដៅទៅព្រំដែនថៃ។ ខ្ញុំរួមទាំងអ្នករួមដំណើរទាំងអស់បានធ្វើដំណើរឆ្លងពីភូមិមួយទៅភូមិមួយ ចេញពីខេត្តមួយទៅខេត្តមួយទៀតរហូតទៅដល់ទឹកដីនៃខេត្តបាត់ដំបង។ បន្ទាប់ពីធ្វើដំណើរទៅដល់ទីនោះហើយអ្នកនាំផ្លូវបានឲ្យយើងឈប់សម្រាកនៅស្រុកបវេលរយៈពេលមួយសប្តាហ៍សិន។ ក្រោយមក ខ្ញុំរួមទាំងប្រជាជនជាច្រើននាក់ទៀតបន្តដំណើរឆ្ពោះទៅភ្នំ១០០៧។

នៅក្នុងឆ្នាំ១៩៨០ ខ្ញុំធ្វើដំណើរទៅដល់ភ្នំ១០០៧។

បន្ទាប់ពីទៅដល់ទីនោះហើយ ខ្ញុំចូលធ្វើជាកងនារីដឹកជញ្ជូន។ ការងារដែលខ្ញុំត្រូវធ្វើក្នុងកងដឹកជញ្ជូនគឺខ្ញុំត្រូវដឹកជញ្ជូនគ្រាប់ទៅឲ្យកងទ័ពនៅសមរភូមិមុខ។ គោលដៅដែលខ្ញុំទៅញឹកញាប់គឺ តំបន់ជាំក្សាន្ត។ នៅចុងឆ្នាំ១៩៨០ ខ្ញុំរៀបការប្ដី។ បន្ទាប់ពីមានគ្រួសារហើយ ខ្ញុំផ្លាស់ទៅតាមប្ដីខ្ញុំនៅអណ្ដែងមុតដែលស្ថិតនៅក្នុងទឹកដីអូរស្មាច់។ ខ្ញុំ និងគ្រួសាររស់នៅ ទីនោះរយៈពេល៨ខែ ក៏ផ្លាស់មកនៅកងអង្គភាព៨០៨វិញ។ ខ្ញុំនិងគ្រួសាររស់នៅអង្គភាព៨០៨ អស់រយៈពេលមួយឆ្នាំក៏ផ្លាស់ទៅនៅជាំសាង៉ាំ។ ខ្ញុំរស់នៅលើភ្នំរហូតដល់ឆ្នាំ១៩៩០ តាម៉ុក បញ្ជាឲ្យប្រជាជនចុះមកនៅអន្លង់វែង ហើយខ្ញុំទៅសង់ផ្ទះរស់នៅក្នុងភូមិលំទង។

នៅឆ្នាំ១៩៩៣ អ៊ុនតាក់ចូលមកដល់ទឹកដី អន្លង់វែង។ ខ្ញុំរួមទាំងប្រជាជនមួយចំនួនធំរត់ទៅនៅ ជំរំភូណាយក្នុងទឹកដីថៃវិញ។ ការរស់នៅក្នុងជំរំភូណាយប្រជាជនមានការហូបចុកគ្រប់គ្រាន់។ អាហារហូបចុកទាំងអស់មានដូចជា អង្ករ អំបិល ប៊ីចេង ទឹកដោះគោ ត្រីខមីខ្ញាញ់ ជាដើម គឺ តាម៉ុក ជាអ្នកបើកឲ្យ។ ប្រជាជនអាចទៅលក់ដូរជាមួយជនជាតិថៃ និងអាចរកប្រាក់ចំណូលបានថែមទៀត។ ខ្ញុំរស់នៅក្នុងជំរំភូណាយរហូតដល់ឆ្នាំ១៩៩៨ តំបន់អន្លង់វែងចាប់ផ្ដើមដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិ បញ្ចប់នូវសង្គ្រាមក្នុងប្រទេស។ កាលណោះ តាម៉ុក បញ្ជាកងកម្លាំងចែកដីឲ្យប្រជាជនដែលរស់នៅក្នុងស្រុកអន្លង់វែងក្នុងមួយគ្រួសារចំនួន៥០ម៉ែត្រដើម្បីធ្វើជាផ្ទះសម្បែងសម្រាប់រស់នៅ។ បន្ទាប់ពីអន្លង់វែងទទួលបានសន្តិភាពហើយ ខ្ញុំត្រឡប់មករស់នៅក្នុងភូមិអូរគគីរកណ្ដាលវិញ។ នៅក្នុងឆ្នាំ១៩៩៩ ខ្ញុំចាប់ផ្ដើមចូលបង្រៀនក្មេងៗថ្នាក់មត្តេយ្យដោយស្ម័គ្រចិត្ត។ ដោយសារតែខ្ញុំមានចំណេះដឹងបន្តិចបន្តួច ហើយមានការគោរពស្រឡាញ់ពីប្រជាជន ទើបប្រជាជនជ្រើសរើសខ្ញុំឲ្យឡើងជាប្រធានភូមិនៅក្នុងឆ្នាំ២០០៦។ ខ្ញុំបន្តបង្ហាត់បង្រៀនសិស្ស និងធ្វើជាមេភូមិរហូតមកដល់បច្ចុប្បន្ននេះ។



រូបខាងស្ដាំ៖ មាស ពៅ ផ្ដល់បទសម្ភាសន៍ដល់ មេក វិន អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសន្តិភាព អន្លង់វែង។ អន្លង់វែង ខែតុលា ឆ្នាំ២០២១។ (សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សំ ហាន៖ អតីតយោធាខ្មែរក្រហម

ស្នួត វិចិត្រ



សំ ហាន ផ្តល់បទសម្ភាសន៍ដល់ ស្នួត វិចិត្រ អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ អន្លង់វែង ខែតុលា ឆ្នាំ២០២១។ (ស្នួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សំ ហាន ភេទប្រុស អាយុ៦៣ឆ្នាំ មានទីកន្លែងកំណើតនៅក្នុងឃុំជាំងទង ស្រុកត្រាំកក់ ខេត្តតាកែវ។ បច្ចុប្បន្ន ហាន កំពុងរស់នៅក្នុងឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ហានបាននិយាយរៀបរាប់ពីការតស៊ូរបស់ខ្លួនដូចខាងក្រោមថា៖

នៅត្រឹមឆ្នាំ១៩៧០ ខ្ញុំមានអាយុប្រហែល១២ឆ្នាំ នៅពេលនោះ ប្រទេសជាតិរបស់យើងកំពុងមានភាពវឹកវរក្នុងព្រឹត្តិការណ៍រដ្ឋប្រហារ ទម្លាក់សម្តេចព្រះនរោត្តម សីហនុ ចេញពីតំណែងជាព្រះប្រមុខរដ្ឋ។ ខ្ញុំឃើញក្បួនបាតុកម្មដ៏ធំមួយបានដង្ហែរចេញពីវត្តមៀនចារ ឆ្ពោះទៅកាន់ទីប្រជុំនៃខេត្តតាកែវដោយមានសំឡេងស្រែកបន្ទរថា «ជយោ សម្តេចឪ! អ្នកណាមិនទៅដុតផ្ទះចោល!»។ ទិដ្ឋភាពនៃសំឡេងដ៏កងរំពងទាំងនោះមិនបានធ្វើឲ្យព្រឹត្តិការណ៍ប្រឆាំងតវ៉ាមានភាពធូរស្រាលនោះទេ ប៉ុន្តែវាថែមទាំងបានជំរុញឲ្យមានការប្រើប្រាស់អំពើហិង្សា និងការបាញ់កាំភ្លើងស្រោចទៅលើក្រុមបាតុករដែលចេះតែរុលទៅមុខកាន់តែច្រើនឡើងថែមទៀត។ ដោយសារស្ថានភាពក្នុងភូមិឋានរបស់ខ្ញុំប្របូកប្របល់ ខ្ញុំក៏ចូលទៅក្នុងព្រៃជាមួយប្រជាជនមួយចំនួនដែលរស់នៅក្នុងភូមិជាមួយគ្នា។

លុះដល់ឆ្នាំ១៩៧១ ខ្ញុំវិលត្រឡប់មកផ្ទះវិញ ដោយបានជួបជុំជាមួយឪពុកម្តាយ និងបងប្អូនៗ ខ្ញុំបន្តរស់នៅក្នុងភូមិដោយប្រកបរបរធ្វើស្រែចម្ការ និងចិញ្ចឹមគោ។ ថ្ងៃមួយមិត្តភក្តិរបស់ខ្ញុំម្នាក់បានមកលេងនៅផ្ទះរបស់ខ្ញុំ។ យើងស្គាល់គ្នាអំឡុងពេលយើងនៅសិក្សា និងរួមដំណើរជាមួយគ្នាចូលទៅក្នុងព្រៃអំឡុងពេលរដ្ឋប្រហារ។ គាត់ចូលបម្រើនៅក្នុងចលនាខ្មែរក្រហមនៅពេលដែលខ្ញុំ និងប្រជាជនផ្សេងទៀតត្រឡប់មកភូមិវិញ។ ខ្ញុំឃើញស្បែកជើងដែលផលិតចេញពីសម្បកកង់ឡានមួយសម្រាប់ពាក់ជាប់នៅនឹងជើងរបស់គាត់ ទើបខ្ញុំដឹងថា គាត់គឺជាកងរំដោះរបស់ខ្មែរក្រហម។ ក្រោយមកខ្ញុំក៏ស្ម័គ្រចិត្តចូលរួមជាមួយចលនាខ្មែរក្រហម ដោយបានស្នាក់នៅខាងក្រោយវត្តព្រៃស្បាត។

មួយរយៈក្រោយមក ខ្ញុំមានគ្រោះថ្នាក់ដោយសារខ្ទាតអំបែងគ្រាប់ត្រូវចំក្បាល ហើយត្រូវបានបញ្ជូនទៅសម្រាកព្យាបាលនៅពេទ្យក្នុងអង្គភាពលេខ៣៥០។ អង្គភាព ៣៥០ មិនមានទីតាំងច្បាស់លាស់ទេ វាគឺជាអង្គភាពចល័ត ហើយលាក់ការណ៍បំផុតក្នុងការជួយសង្គ្រោះកងទ័ពដែលរងរបួសនៅសមរភូមិ។ សំ ហោ ដែលត្រូវជាបងប្រុសបង្កើតរបស់ខ្ញុំគ្រប់គ្រងនៅទីនោះ។ គាត់បានមើលថែខ្ញុំយ៉ាងយកចិត្តទុកដាក់បំផុត រហូតដល់ខ្ញុំជាសះស្បើយ និងអាចត្រឡប់ទៅសមរភូមិវិញ។

លុះដល់ឆ្នាំ១៩៧៣ ខ្ញុំប្តូរមកនៅក្នុងកងវរសេនាធំលេខ៤០៦ដែលដឹកនាំដោយ ស៊ី គឺជាប្រធានអង្គភាព។ មុខសញ្ញាកងកម្លាំងរបស់ខ្ញុំ គឺប្រយុទ្ធជាមួយទាហានលន់ នល់ នៅម្តុំកំបូល ខាងលិចភ្នំពេញ។ យើងវាយប្រយុទ្ធគ្នាយ៉ាងស៊ិតស្វាញ និងមានការទម្លាក់គ្រាប់បែកដ៏សន្ធឹកសន្ធាប់ពីទាហានលន់នល់អស់រយៈពេលជាច្រើនខែ។ ទោះជាយ៉ាងណាក៏ដោយ ក៏កងកម្លាំងរបស់ខ្ញុំនៅតែមានភាពក្លាហាន និងមិនខ្លាចបាត់បង់ជីវិតឡើយ។ យើងជឿទុកចិត្តគ្នា និងមិនបោះបង់គ្នាទោះបីកងកម្លាំងរបស់យើងស្លាប់នៅកណ្តាលព្រៃជ្រៅ។

រហូតដល់ឆ្នាំ១៩៧៥ កងកម្លាំងរបស់ខ្ញុំវាយរហូតដល់ព្រលានយន្តហោះពោធិ៍ចិនតុង។ កងកម្លាំងរបស់ខ្ញុំមានតួនាទីដើរបោសសម្អាតរៀបចំផ្ទះសម្បែង និងប្រមែប្រមូលរបស់របរមានតម្លៃដើម្បីរក្សាទុកជូនអង្គភាព។ ជីវិតរបស់យើងនៅពេលនោះ គឺមិនចង់បានអ្វីទាំងអស់ជាកម្មសិទ្ធិផ្ទាល់ខ្លួនឡើយ។ ជាក់ស្តែងមាសប្រាក់ជាច្រើនដែលយើងប្រមូលបានគឺរក្សាទុកជារបស់រួម។ ក្រោយមកយើងផ្លាស់ទៅកាន់ទួលគីតាមបណ្តោយផ្លូវជាតិលេខ៣ ។ ខ្ញុំឃើញប្រជាជនជម្លៀសជាច្រើននាក់កំពុងធ្វើដំណើរនៅតាមដងផ្លូវ។ យើងមានតួនាទីយាមកាម និងត្រួតពិនិត្យទៅលើរថយន្តដឹកទំនិញដែលកងកម្លាំងរបស់យើងប្រមែប្រមូលបាន។ នៅពេលនោះ គ្មានកងរំដោះណាម្នាក់មានចិត្តលោភលន់ចង់បានរបស់របរ ឬមាសប្រាក់របស់ប្រជាជនឡើយ។ កងទ័ពរំដោះមួយចំនួននៅទួលគីខ្លះក៏មានភាពសាហាវព្រៃផ្សៃ ដោយបានសម្លាប់ប្រជាជនដែលបានជម្លៀសចេញពីក្រុងភ្នំពេញដែរ។ ក្រោយមកខ្ញុំទទួលដំណឹងថា បងប្រុសរបស់ខ្ញុំដែលជាប្រធានអង្គភាពពេទ្យត្រូវបានបញ្ជូនទៅនៅកំពង់សោម និងត្រូវបានសម្លាប់នៅរោងកុនមួយកន្លែងនៅទីនោះ។

អស់រយៈពេលជាច្រើនខែក្រោយមក ប្រធានអង្គភាពបញ្ជូនខ្ញុំទៅព្រំប្រទល់វៀតណាមដើម្បីឈរជើងការពារនៅទីនោះ។ ខ្ញុំឃើញប្រជាជនវៀតណាមមកស្ទូងស្រូវនៅតំបន់ព្រំដែននៃទឹកដីរបស់យើង ប៉ុន្តែយើងបានប្រាប់ឲ្យប្រជាជនទាំងនោះឆាប់ដកខ្លួនចេញបន្ទាប់ពីប្រមូលផលរួច។

លុះដល់អំឡុងឆ្នាំ១៩៧៨ កងកម្លាំងរបស់យើងប៉ះទង្គិចជាមួយកងទ័ពវៀតណាម ហើយយើងវាយប្រយុទ្ធគ្នាយ៉ាងខ្លាំង។ កងកម្លាំងរបស់យើងសរុបចំនួន៤អនុសេនាធំ ត្រៀមតាមមុខសញ្ញាពីភ្នំដិនរហូតទៅដល់ព្រៃស្នាច់ ដើម្បីវាយតទល់ជាមួយកម្លាំងថ្មើរជើង និងរថក្រោះរបស់កងទ័ពវៀតណាម។ យើងវាយពីផ្សារអន្ទង់បិណ្ឌ រហូតទៅដល់កោះគគីរ ដោយរឹបអូសបានរថក្រោះវៀតណាមជាច្រើនគ្រឿង។ យើង

បានប្រើកាំភ្លើងធំ ដើម្បីវាយប្រហារទៅលើកងរថក្រោះរបស់វៀតណាម ដោយសារទីតាំងយុទ្ធសាស្ត្រនៅទីនោះគឺមានភាពបត់បែនចុះឡើងៗ និងមានសភាពជាជ្រលងៗ យើងវាយប្រយុទ្ធគ្នារហូតដល់រដូវវស្សា។ ក្រោយមកទៀត ដោយសារកងទ័ពរបស់យើងមានចំនួនតិច ទើបផ្តល់លទ្ធភាពឲ្យកងទ័ពវៀតណាមវាយប្រហារចូលមក ហើយបណ្តាលឲ្យស្លាប់កងកម្លាំងខ្មែរក្រហមអស់ជាច្រើន។ ក្នុងរយៈពេលខ្លីប៉ុណ្ណោះ កងទ័ពរបស់យើងទទួលបរាជ័យ និងបានបាក់បែកខ្ចាត់ខ្ចាយដាច់ខ្សែរយៈពីគ្នា។ កងកម្លាំងដែលនៅរស់ជីវិតនាំគ្នាហែលឆ្លងកាត់ព្រែកស្តោះទៅកាន់ព្រំដែនថៃ ដើម្បីគេចខ្លួន។ យើងធ្វើដំណើរទៅដល់ខេត្តកំពង់ឆ្នាំង ដោយឮស្នូរគ្រាប់កាំភ្លើងបេនៅពីក្រោយជាប់ជានិច្ច ទើបធ្វើឲ្យយើងប្រញាប់ប្រញាល់បន្តដំណើរទៅមុខ។ យើងស្ពាយអីវ៉ាន់ និងរបស់របរមួយចំនួន ដូចជា ចាន ឆ្នាំង និងសម្លៀកបំពាក់។

នៅចន្លោះឆ្នាំ១៩៨៤-១៩៨៥ ខ្ញុំធ្វើការនៅខេត្តប៉ៃលិន។ ខ្ញុំរស់នៅទីនោះ ជាមួយនឹងក្រុមគ្រួសារបានមួយរយៈ ទើបធ្វើដំណើរមកកាន់តំបន់អន្លង់វែង និងរស់នៅទីនោះមកទល់បច្ចុប្បន្ន។



សំ ហន ផ្តល់បទសម្ភាសន៍ដល់ ស្មួត វិចិត្រ អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ អន្លង់វែង ខែតុលា ឆ្នាំ២០២១។
( ស្មួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# សំណង់ចេតិយ៍ តម្កល់អដ្ឋិធាតុជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិត និងរំឭកអំពីរឿងរ៉ាវ

## ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមនៅឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម

*សាំង ចិន្តា*



ចេតិយ៍ អដ្ឋិតម្កល់ធាតុជនរងគ្រោះនៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រុមការងារឃុំគគរ សាងសង់ចេតិយ៍តម្កល់អដ្ឋិធាតុជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិត និងរំឭកអំពីរឿងរ៉ាវដែលបានកើតឡើងនៅឃុំគគរនៅក្នុងរបបខ្មែរក្រហម នៅកណ្តាលវាលស្រែ ស្ថិតនៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ការសាងសង់ចេតិយ៍នេះធ្វើឡើងដើម្បីឆ្លើយតបទៅនឹងស្នើសុំរបស់ តុង សុភា គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាក្មេងកំព្រាឪពុកត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់នៅមន្ទីរសន្តិសុខគគរ ស្ថិតនៅក្នុងវត្តគគរ នៅក្នុងឆ្នាំ១៩៧៨។

## ប្រវត្តិមន្ទីរសន្តិសុខឃុំគគរ

ឃុំគគរ ដែលស្ថិតនៅតាមដងទន្លេមេគង្គនិងមានចម្ងាយប្រហែល១៥គីឡូម៉ែត្រពីទីរួមខេត្តកំពង់ចាម ដោយមានភូមិទាំងអស់ចំនួន៤។ នៅក្នុងឃុំគគរ មានទីតាំង ធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់ប្រជាជនដែលត្រូវបានខ្មែរក្រហមចោទប្រកាន់ទាំងអស់ចំនួន៣៖ ទី១) ទីវាលស្រែនៅភូមិចំការសាមសិប ទី២) ឡដុតថ្នាំជក់ និង ទី៣) មន្ទីរសន្តិសុខគគរ ដែលស្ថិតនៅក្នុងវត្តគគរ។ មន្ទីរសន្តិសុខឃុំគគរ បង្កើតឡើងនៅក្នុងឆ្នាំ១៩៧៥។ បន្ទាប់ពីការមកដល់របស់កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានគ្រប់គ្រងភូមិសាស្ត្រឃុំគគរ ការកាប់សម្លាប់ប្រជាជនកាន់តែច្រើនឡើងចាប់ពីឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៨។ ប្រជាជនមូលដ្ឋានត្រូវបានយកទៅសម្លាប់នៅវាលស្រែ ខណៈពេលដែលអតីតកម្មាភិបាលភូមិភាគបូព៌ាកម្រិតមូលដ្ឋាន និងអ្នកពាក់ព័ន្ធត្រូវបានចាប់ឃុំឃាំងនិងសម្លាប់នៅមន្ទីរសន្តិសុខឃុំគគរ។ នៅពេលនោះ ជនជាតិភាគតិចចាមនៅភូមិកំពង់ក្របីជាច្រើននាក់ត្រូវបានចាប់ខ្លួន និងដឹកយកទៅសម្លាប់នៅក្នុង ឡដុតថ្នាំជក់ នៅក្នុងភូមិចំការសាមសិប។ ជនរងគ្រោះរាប់រយនាក់ត្រូវបានស្លាប់បាត់បង់ជីវិតនៅពេលនោះ។ នៅពាក់កណ្តាលឆ្នាំ១៩៧៨ មន្ទីរសន្តិសុខគគរ ត្រូវបានប្រើប្រាស់ទៅជាឃ្លាំងសម្រាប់ស្តុកទុកសម្ភារ និងស្រូវអង្ករ។

ទីតាំងចេតិយ៍នេះបង្កើតឱកាសសម្រាប់ការនិយាយអំពីប្រវត្តិសាស្តខ្មែរក្រហម (១៩៧៥-១៩៧៩) និងជាទីតាំងរំឭកការចងចាំជាសមូហភាព និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍

លោក លន់ លាងហេង អាយុ៦៦ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាមេឃុំគគរ ថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមការងារ ដែលសាងសង់ចេតិយ៍រំឭកអំពីជនរងគ្រោះដែលបានស្លាប់នៅក្នុងមូលដ្ឋានរបស់គាត់។ លោកលាងហេង បញ្ជាក់ថា៖ “ចេតិយ៍នេះ គឺជានិមិត្តរូបសម្រាប់ការចងចាំដ៏ជូរជត់របស់រូបខ្ញុំផ្ទាល់ និងប្រជាជននៅមូលដ្ឋានឃុំគគរដែលបានឆ្លងកាត់របបខ្មែរក្រហម។ ចេតិយ៍នេះ ដើរតួនាទីផ្សព្វផ្សាយ និងផ្តល់សក្ខីភាពអំពី



វាលស្រែនៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (ទូច វណ្ណេត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រវត្តិសាស្ត្រខ្មែរក្រហមដល់ក្មេងជំនាន់ក្រោយ ដើម្បីធ្វើការស្វែងយល់ និងពិភាក្សាអំពីរឿងរ៉ាវដែលបានកើតឡើងនៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីចូលរួមទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលនៅក្នុងកម្រិតមូលដ្ឋានរបស់ខ្លួន។

តុង សុភា អាយុ៥៥ឆ្នាំ អតីតកុមារមូលដ្ឋានរៀនថ្នាក់ទី១ និងជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានរំឭកអំពីការដេកលើដៃឪពុកជាចុងក្រោយ មុនពេលដែលត្រូវបានកងឈ្លបចាប់ខ្លួនយកទៅសម្លាប់ចោលនៅមន្ទីរសន្តិសុខគគរ និងគូសបញ្ជាក់អំពីការស្នើសុំសាងសង់ចេតិយ៍នេះ៖

ខ្ញុំឈ្មោះ តុង សុភា កើតនៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៦៦ នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ តុង វ៉ិន និងម្តាយឈ្មោះ ប៉ិច សែអេង។ ខ្ញុំគឺជាកូនទី៣ក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន៤នាក់។ នៅពេលដែលកើតមានសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមផ្ទុះឡើងនៅដើមឆ្នាំ១៩៧០ ខ្ញុំទើបតែមានអាយុប្រហែល៥ឆ្នាំ។ នៅពេលនោះ ឪពុកម្តាយបានពរខ្ញុំនិងបងប្អូនផ្សេងទៀតរត់ចេញពីភូមិចំការសាមសិប ដែលជាសមរភូមិប្រទាញប្រទង់។ នៅឆ្នាំ១៩៧១ គ្រួសាររបស់ខ្ញុំវិលត្រឡប់មកភូមិវិញ និងរស់នៅរហូតដល់ឆ្នាំ១៩៧៥ ទើបឪពុកម្តាយ និងបងស្រី២នាក់របស់ខ្ញុំ ត្រូវបានបញ្ជូនទៅធ្វើការនៅតាមកងចល័តរៀងៗខ្លួន។ នៅពេលនោះ ខ្ញុំមានអាយុ៩ឆ្នាំ និងត្រូវបានបញ្ជូនទៅកងចល័តកុមារមូលដ្ឋានដើម្បីរៀនសូត្រ និងដើររើសលាមកសត្វមកធ្វើជីដាក់ស្រែ។ កងកុមារ គឺមានទាំងកុមារា និងកុមារី សរុបទាំងអស់ប្រហែលចំនួន៣០នាក់ ដែលមានមិត្តបងឈ្មោះ លឹម គឺជាប្រធានកងកុមារ។ សមមិត្តនារី ឃាង គឺជាគ្រូបង្រៀនថ្នាក់ទី១នៅក្នុងភូមិចំការសាមសិប។ ខ្ញុំនិងកុមារមូលដ្ឋានផ្សេងទៀតក្រោកពីព្រលឹមដើរទៅរៀនជាមួយអ្នកគ្រូ ឃាង នៅក្រោមផ្ទះរបស់តា សៀ ដែលជាប្រជាជនមូល។ នៅពេលព្រឹក អ្នកគ្រូ ឃាង បង្រៀនអក្សរ និងលេខអស់រយៈពេលប្រហែល ៣ម៉ោង។ បន្ទាប់មក អ្នកគ្រូ ឃាង ដឹកនាំកុមារមូលដ្ឋានទាំងអស់ទៅធ្វើពលកម្ម ដោយបានដើរលើកអាចម៍គោពីផ្ទះរបស់ប្រជាជនមូលដ្ឋានដើម្បីធ្វើជីដាក់ស្រូវ រហូតដល់ម៉ោង១២ថ្ងៃត្រង់ ទើបអ្នកគ្រូ និងកុមារមូលដ្ឋានទាំងអស់ដើរទៅហូបបាយនៅរោងបាយសហករណ៍។ បន្ទាប់ពីសម្រាកថ្ងៃត្រង់បន្តិច កុមារមូលដ្ឋានទាំងអស់ ដឹកនាំដោយអ្នកគ្រូ ឃាង ត្រូវបន្តដើរប្រមូលអាចម៍គោយកទៅទុកនៅកន្លែងធ្វើជី ដាក់ស្រែរហូតដល់ម៉ោង៥ល្ងាច។ ពេលនោះ គឺមិនទាន់មានសាលារៀន និងម៉ោងសិក្សាជាប់លាប់នោះឡើយ។ អ្នកគ្រូ ឃាង បង្រៀនកុមារមូលដ្ឋានដោយបានចល័តនៅក្រោមផ្ទះរបស់ប្រជាជនមូលដ្ឋាន។ នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំមានវ័យធំបន្តិច។ នៅពេលនោះ ខ្ញុំត្រូវបានផ្លាស់ទៅកងចល័តទី២ដើម្បីដើរទៅធ្វើស្រែ និងបន្ទាប់មកទៀតត្រូវបានផ្លាស់មកភូមិវិញដើម្បីដើរប្រមូលអាចម៍គោវិញ។ នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានបញ្ជូនទៅជញ្ជូនកណ្តាប់ស្រូវអស់រយៈពេលប្រហែល២ខែ។ នៅពេលនោះ ខ្ញុំមានអាយុ១១ឆ្នាំ។ ក្រោយមកទៀត ខ្ញុំទទួលបានការអនុញ្ញាតឲ្យវិលត្រឡប់មកផ្ទះវិញ។ ចាប់ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ កងទ័ពខ្មែរក្រហមមកពីភូមិភាគនិរតីចូលមកគ្រប់គ្រងក្នុងភូមិ និងចាប់ផ្តើមចាប់អ្នកភូមិជាច្រើនគ្រួសារយកទៅសម្លាប់ចោលនៅមន្ទីរសន្តិសុខគគរ។ ឪពុករបស់ខ្ញុំក៏ត្រូវបានចាប់យកទៅសម្លាប់ផងដែរ។ នៅយប់ដ៏ស្ងប់ស្ងាត់មួយនៅឆ្នាំ១៩៧៨ កងឈ្លបខ្មែរក្រហមប្រហែល៤នាក់មកហៅឪពុករបស់ខ្ញុំ ខណៈពេលដែលខ្ញុំកំពុងដេកលក់កើយដៃរបស់គាត់។ ពេលនោះគឺជាគ្រាចុងក្រោយដែលខ្ញុំដេកលើដៃរបស់ឪពុក។ ខ្ញុំឃើញឪពុកខ្ញុំចុះពីលើផ្ទះ និងត្រូវបានកងឈ្លបចាប់ចងស្លាបសេកបណ្តើរជាមួយអ្នកភូមិប្រហែល១២នាក់ផ្សេងទៀតទៅមន្ទីរសន្តិសុខគគរ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានជួបឪពុករបស់ខ្ញុំទៀតទេ។ គ្រាចុងក្រោយដែលកងឈ្លបខ្មែរក្រហមយកឪពុករបស់ខ្ញុំទៅសម្លាប់ចោល គឺនៅតែដក់ជាប់ក្នុងការចងចាំរបស់ខ្ញុំ។ ខ្ញុំសូមឧទ្ទិសកុសលជូនចំពោះវិញ្ញាណក្ខន្ធឪពុករបស់ខ្ញុំនៅចេតិយ៍រំឭកអំពីជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) នេះ។













# ការិយាល័យ
# ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖

truthchenda.s@dccam.org

សូមអរគុណ!















# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

ដារ៉ាវដ្ឋ មេត្តា

(តពីលេខមុន)

...សង់ព្រលានយន្តហោះយោធា កំពង់ឆ្នាំង មន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល និងតាមរយៈការប្រព្រឹត្តចំពោះជនជាតិចាម និងជនជាតិវៀតណាម។

**៦៥៤.** អង្គជំនុំជម្រះបានសម្រេចពីមុនរួចមកហើយថា ការសម្លាប់រង្គាលត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនាឆ្នាំ១៩៧៥។ ពាក់ព័ន្ធនឹងភាពប្រមើលឃើញជាមុនថាជាបទល្មើស និងភាពអាចដឹងថាមានច្បាប់ចែងអំពីការសម្លាប់រង្គាលដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អង្គជំនុំជម្រះពិចារណាទៅលើក្របខណ្ឌនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងតួនាទីរបស់ជនជាប់ចោទក្នុងនាមជាសមាជិកនៃអាជ្ញាធរគ្រប់គ្រងប្រទេសកម្ពុជា។ បន្ទាប់ពីបានថ្លឹងថ្លែងលើកត្តាទាំងនេះដោយមិនលម្អៀង អង្គជំនុំជម្រះសន្និដ្ឋានថា ជនជាប់ចោទអាចប្រមើលឃើញ និងដឹងជាទូទៅថា ការសម្លាប់រង្គាលត្រូវបានផ្តន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគិតត្រឹមឆ្នាំ១៩៧៥។

**៦៥៥.** ធាតុផ្សំសត្យានុម័តនៃការសម្លាប់រង្គាល រួមមាន អំពើសកម្ម អំពើអសកម្ម ឬការរួមបញ្ចូលគ្នានៃអំពើទាំងពីរនេះ ដែលនាំឲ្យមានការបាត់បង់ជីវិតមនុស្សក្នុងទ្រង់ទ្រាយធំៗ ការកំណត់បទល្មើស ការសម្លាប់រង្គាល មិនតម្រូវឲ្យមានការបង្ហាញនូវចំនួនជនរងគ្រោះក្នុងកម្រិតអប្បបរមាណាមួយនោះទេ។ លក្ខខណ្ឌតម្រូវនៃទ្រង់ទ្រាយធំ ត្រូវបានវាយតម្លៃទៅតាមករណីនីមួយៗដោយផ្អែកលើកត្តាពេលវេលា និងទីកន្លែងនៃការសម្លាប់ ការសម្រិតសម្រាំងជនរងគ្រោះ និងវិធីកំណត់គោលដៅជនរងគ្រោះ និងថាតើការសម្លាប់មានចេតនាសំដៅលើក្រុមរួមណាមួយ ជាជាងសំដៅតែទៅលើជនរងគ្រោះម្នាក់ៗ។

**៦៥៦.** ទ្រង់ទ្រាយនៃការសម្លាប់រង្គាលអាចត្រូវបានបង្ហាញដោយផ្អែកលើមូលដ្ឋានប្រមូលផ្តុំនៃហេតុការណ៍ដោយឡែកៗ ពីគ្នា។ យ៉ាងណាមិញ ហេតុការណ៍ទាំងនេះចាំបាច់ត្រូវស្ថិតនៅក្នុងប្រតិបត្តិការនៃការធ្វើមនុស្សឃាតតែមួយ។ វាមិនគ្រប់គ្រាន់ទេនៅក្នុងការពិចារណាជារួមនូវ«ព្រឹត្តិការណ៍ផ្សេងៗគ្នាដែលបានប្រព្រឹត្តនៅ ទីតាំងផ្សេងគ្នា កាលៈទេសៈខុសគ្នា ប្រព្រឹត្តដោយចារីខុសគ្នានៅក្នុងរយៈពេលដ៏វែង» នោះ។ គ្មានភាគីណាមួយបានជំទាស់ទៅនឹងនិយមន័យនៃធាតុផ្សំសត្យានុម័ត នៃការសម្លាប់រង្គាល ដែលបានរៀបរាប់ខាងលើនេះទេ។

**៦៥៧.** អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ធាតុផ្សំអត្តនោម័តិនៃការសម្លាប់រង្គាលដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឲ្យមានចេតនាផ្ទាល់របស់ចារីក្នុងការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំៗ ដោយសារតែគោលបំណងនៃការសម្លាប់រង្គាលគឺសំដៅកម្ទេចបុគ្គលដែលស្ថិតនៅក្នុងក្រុមណាមួយ ហេតុនេះឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលមិនស៊ីចង្វាក់នឹងសញ្ញាណនៃចេតនាដោយប្រយោល (dolus eventualis) នោះ



ព្រលានយន្តហោះពោធិ៍ចិនតុង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឡើយ។ វាមិនតម្រូវឲ្យមានការយល់ដឹងរបស់ចារី អំពីការសម្លាប់ជាក់លាក់នោះទេ។ ការបង្ហាញនៃការសម្លាប់សមាជិករបស់ក្រុមមួយកើតចេញពីចេតនារបស់ចារី មានភាពគ្រប់គ្រាន់នៅក្នុងការកំណត់នៃធាតុផ្សំអត្តនោម័តិនៃបទល្មើសនេះ។

**៦៥៨**. សហព្រះរាជអាជ្ញាលើកឡើងថា អង្គជំនុំជម្រះតុលាការកំពូលបានអនុវត្តបទដ្ឋាននៃធាតុផ្សំអត្តនោម័តដែលរួមបញ្ចូលចេតនារបស់ចារីក្នុងការបង្កើតលក្ខខណ្ឌនៃការរស់នៅ ដែលនាំឲ្យមានការបាត់បង់អាយុជីវិតមនុស្សមួយចំនួនធំ។ អង្គជំនុំជម្រះកត់សម្គាល់ថា ជាក់ស្តែងអង្គជំនុំជម្រះតុលាការកំពូលបានយោងនិងយល់ស្របនឹងយុត្តិសាស្ត្រដែលស៊ីសង្វាក់ជាមួយនឹងបទដ្ឋាននៃធាតុផ្សំអត្តនោម័តិនៃចេតនា សំដៅទៅលើមនុស្សមួយចំនួនដោយ «ដាក់លក្ខខណ្ឌនៃការរស់នៅដែលបង្កឲ្យមានការស្លាប់មិនអាចជៀសផុតបាន ហើយថា ជនជាប់ចោទមានចេតនាចង់បានលទ្ធផលបែបនេះ តាមរយៈអំពើសកម្ម ឬអសកម្មរបស់ខ្លួន»។ សហព្រះរាជអាជ្ញាអះអាងទៀតថា ពុំមានលក្ខខណ្ឌតម្រូវដែលថាជនរងគ្រោះ«ប្រាកដជាត្រូវប្រឈមនឹងលក្ខខណ្ឌ ដែលមិនអាចចៀសរួចពីសេចក្តីស្លាប់នោះឡើយ»។ ភាគីផ្សេងទៀតមិនបានដាក់សារណាពាក់ព័ន្ធនឹងបញ្ហានេះនោះទេ។ ដូចដែលអង្គជំនុំជម្រះបានសម្រេចពីមុនរួចមកហើយ សំណុំរឿងនានាដែលយោងទៅលើលក្ខខណ្ឌតម្រូវនៃ«ការចៀសមិនរួចពីសេចក្តីស្លាប់» ពុំមានមូលដ្ឋានសំអាង និងត្រូវបានពិភាក្សាឡើយ។ ផ្អែកលើធាតុផ្សំអត្តនោម័តិនៃការស្លាប់រង្គាលដែលតម្រូវឲ្យជនជាប់ចោទមានចេតនាដោយចំពោះក្នុងការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំនោះ វាជាការគ្រប់គ្រាន់ក្នុងការកំណត់ធាតុផ្សំនៃបទល្មើសនេះ ប្រសិនបើ ចារី មានចេតនាបង្កឲ្យមនុស្សស្លាប់ក្នុងចំនួនដ៏ច្រើន។

មិនចាំបាច់មានការបង្ហាញបន្ថែមអំពីលក្ខខណ្ឌដែលបណ្ដាលឲ្យមានការស្លាប់ប្រជាជនទាំងអស់ដោយចៀសមិនរួចនោះឡើយ ដរាបណាគេអាចបង្ហាញថា ចារីមានចេតនាបង្កើតលក្ខខណ្ឌនៃការរស់នៅដើម្បីសម្លាប់មនុស្សជាទ្រង់ទ្រាយធំ។

**៦៥៩.** *អង្គជំនុំជម្រះតុលាការកំពូលបានឯកភាពលើការរកឃើញរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អត្ថិភាពនិងការដឹងឮរបស់ជនជាប់ចោទអំពីការសម្លាប់ក្នុងទ្រង់ទ្រាយធំ មិនមែនជាធាតុផ្សំនៃការសម្លាប់រង្គាល នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងឆ្នាំ១៩៧៥ ទេ។*

### ៩.១.៣. ការធ្វើឱ្យទៅជាទាសករ

**៦៦០.** *ទាក់ទិនសំណុំរឿង០០២/០២ ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការឲ្យទៅជាទាសករ នៅសហករណ៍ត្រាំកក់ ការដ្ឋានការងារ ទំនប់ត្រពាំងថ្ម ការដ្ឋានការងារទំនប់១មករា និងការដ្ឋានសាងសង់ព្រលានយន្តហោះយោធាកំពង់ឆ្នាំង មន្ទីរសន្តិសុខស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល។*

**៦៦១.** *អង្គជំនុំជម្រះបានសម្រេចពីមុនរួចមកហើយថា ការធ្វើឲ្យទៅជាទាសករត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥។ ពុំមានការលើកឡើងនូវទឡ្ហីករណ៍ថ្មីៗ ពីសំណាក់ភាគីនានានៅក្នុងករណីនេះដែលតម្រូវឲ្យអង្គជំនុំជម្រះត្រូវពិចារណាបន្ថែមទៀតលើបញ្ហានេះនោះឡើយ។ ទាក់ទិនភាពអាចប្រមើលឃើញជាមុនថាជាបទល្មើស និងភាពអាចដឹងថាមានច្បាប់ចែងអំពីការធ្វើឲ្យទៅជាទាសករថា ជាបទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះពិចារណាទៅលើក្របខណ្ឌនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម និងតួនាទីរបស់ជនជាប់ចោទក្នុងនាមជាសមាជិកនៃអាជ្ញាធរគ្រប់គ្រងប្រទេសកម្ពុជា។ បន្ទាប់ពីបានថ្លឹងថ្លែងទៅលើកត្តាទាំងនេះដោយសត្យានុម័តអង្គជំនុំជម្រះសន្និដ្ឋានថា ជនជាប់ចោទអាចប្រមើលឃើញនិងដឹងជាទូទៅថា ការធ្វើឲ្យទៅជាទាសករត្រូវផ្ដន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពីឆ្នាំ១៩៧៥។ អង្គជំនុំជម្រះកត់សម្គាល់ថា សំអាងហេតុនេះស្របគ្នាជាមួយនឹងសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង០០១ ដែលថាត្រឹមឆ្នាំ១៩៧៥ ជនជាប់ចោទអាចប្រមើលឃើញជាមុនថា ជាអំពើឧក្រិដ្ឋ និងអាចដឹងថាមានច្បាប់ចែងថា ខ្លួនអាចត្រូវបានតុលាការចោទប្រកាន់អំពីការធ្វើឲ្យទៅជាទាសករ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។*

**៦៦២.** *និយមន័យនៃការធ្វើឲ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទាញចេញពីនិយមន័យនៃទាសភាពនៅក្នុងអនុសញ្ញាស្ដីពីទាសភាពឆ្នាំ១៩២៦។ ធាតុផ្សំសត្យានុម័តនៃការធ្វើឲ្យទៅជាទាសករត្រូវបានកំណត់ដោយការប្រើប្រាស់អំណាចមួយ ឬទាំងស្រុងដែលភ្ជាប់ជាមួយនឹងសិទ្ធិដែលជាម្ចាស់កម្មសិទ្ធិទៅលើមនុស្ស។ បើទោះបីជាសញ្ញាណនៃពាក្យ «ម្ចាស់កម្មសិទ្ធិលើវត្ថុណាមួយ» ក៏ដោយ ប៉ុន្តែអំពើមួយអាចចាត់ទុកថាជាការធ្វើឲ្យទៅជាទាសករ នៅពេលដែលចារី «បង្ហាញអាកប្បកិរិយាជាកម្មសិទ្ធិលើជនរងគ្រោះ»។ នៅក្នុងការធ្វើការវាយតម្លៃនោះ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះត្រូវតែកំណត់អំពីសញ្ញាណនៃកម្មសិទ្ធិពោល គឺអង្គហេតុទាំងនោះដែលចង្អុលបញ្ជាក់ថា ជនរងគ្រោះត្រូវបានគេបន្ទាបមកជាទំនិញត្រូវបានគេយកមកប្រើ ត្រូវបានគេជិះជាន់ជាប្រយោជន៍សេដ្ឋកិច្ច «ត្រូវបានគេប្រើប្រាស់» និង «ទីបញ្ចប់ត្រូវបានគេបោះបង់ចោល»។ ការប្រើប្រាស់អំណាចទាំងឡាយក្នុងនាមជាម្ចាស់ លើមនុស្សតម្រូវឲ្យមានការត្រួតត្រាច្រើនមកលើជនរងគ្រោះ។ ការធ្វើឲ្យទៅជាទាសករមិនមានអត្ថិភាពឡើយ«ក្នុងករណីដែលការត្រួតត្រាមានគោលដៅច្បាស់លាស់ផ្សេងក្រៅពីការផ្ដល់លទ្ធភាពឲ្យមានការប្រើប្រាស់អំណាចទាំងឡាយក្នុងនាមជាម្ចាស់»។ «ការខិតខំប្រឹងប្រែងក្នុងការបង្កើតផលចំណេញ» ដែលមិនមែនជា*

ធាតុផ្សំបន្ថែមនៃបទឧក្រិដ្ឋ គឺជាគោលបំណងយ៉ាងច្បាស់នៅក្នុងការប្រើប្រាស់អំណាចក្នុងនាមជាម្ចាស់។

**៦៦៣.** តម្រុយទាំងអស់នៃការធ្វើឲ្យទៅជាទាសករ ដែលបានលើកឡើងខាងក្រោមនេះមានលក្ខណស្រប ច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលជាការគ្រប់គ្រងលើការធ្វើដំណើររបស់មនុស្សណាម្នាក់ ការគ្រប់គ្រងកន្លែងរស់នៅជារូបវ័ន្តការគ្រប់គ្រងលើផ្លូវចិត្ត ការចាត់វិធានការនានាដើម្បីទប់ស្កាត់ឬរារាំងមិនឲ្យគេចខ្លួន ការប្រើកម្លាំង ការគំរាមកំហែងថានឹងប្រើកម្លាំង ឬការបង្ខិតបង្ខំរយៈពេលនៃការធ្វើជាទាសករ ការអះអាងជាម្ចាស់កម្មសិទ្ធិផ្តាច់មុខ ការដាក់ឲ្យស្ថិតនៅក្រោមការប្រព្រឹត្តយ៉ាងព្រៃផ្សៃ និងការរំលោភបំពាន ការគ្រប់គ្រងលើផ្លូវភេទ និងការធ្វើការងារដោយបង្ខំ។

**៦៦៤.** មិនចាំបាច់មានការបង្ហាញថា ជនរងគ្រោះមិនបានយល់ព្រមឡើយ ប៉ុន្តែភ័ស្តុតាងនៃការយល់ព្រមអាចជាប់ពាក់ព័ន្ធយ៉ាងសំខាន់ក្នុងការកំណត់អំពីការអនុវត្តសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ នៅក្នុងស្ថានភាពដែលមិនអាចបង្ហាញការយល់ព្រមបាន គេសន្មតថាពុំមានការយល់ព្រមឡើយ។

**៦៦៥.** នៅក្នុងការពិភាក្សាអំពីធាតុផ្សំនៃការធ្វើឲ្យទៅជាទាសករ ទាំងអង្គជំនុំជម្រះតុលាការកំពូលក៏ដូចជាតុលាការ ICTY បានយោងទៅរឿងក្តី Pohl ដែលបានសន្និដ្ឋានថា «យើងអាចលុបបំបាត់ចោលរាល់ភ័ស្តុតាងនៃការធ្វើបាប អាចមើលរំលងការស្រេកឃ្លាន ការវាយដំ និងអំពើឃោរឃៅដទៃទៀត ប៉ុន្តែអង្គហេតុនៃទាសករដែលត្រូវបានទទួលស្គាល់ គឺការធ្វើការងារដោយទាសភាពដែលមិនមានការស្ម័គ្រចិត្ត នៅតែជាទាសភាពដដែល ទោះបីជាមានប្រព្រឹត្តដោយមនុស្សធម៌ខ្លះៗ ក៏ដោយ»។

**៦៦៦.** ប្រសិនបើធាតុផ្សំទាំងអស់នៃឧក្រិដ្ឋកម្មនោះត្រូវបានបំពេញ ការងារដោយបង្ខំអាចមានលក្ខណៈគ្រប់គ្រាន់បង្កើតបានជាការធ្វើឲ្យទៅជាទាសករដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ទោះបីជាយ៉ាងណា វាមិនមែនជាបុរេលក្ខខណ្ឌក្នុងការបង្ហាញអំពីឧក្រិដ្ឋកម្មនោះឡើយ។ ទាក់ទិនការងារដោយបង្ខំការធ្វើឲ្យទៅជាទាសករនោះ មេធាវីការពារក្តី នួន ជា លើកឡើងថា នៅក្នុងការបង្ហាញនត្ថិភាពនៃការយល់ព្រម «ទស្សនៈអត្តនោម័តតែមួយប៉ុណ្ណោះរបស់ជនរងគ្រោះដែលជាភ័ស្តុតាងសត្យានុម័ត»។ ភាគីផ្សេងទៀតមិនបានធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងបញ្ហានេះនោះទេ។ អង្គជំនុំជម្រះយល់ឃើញថា ទស្សនៈអត្តនោម័តរបស់ជនរងគ្រោះតែមួយមិនគ្រប់គ្រាន់នោះទេ ហើយនៅទីបំផុតត្រូវតែមានភ័ស្តុតាងជាសត្យានុម័តដែលបង្ហាញថា ជនរងគ្រោះមិនមានជម្រើសផ្សេងក្រៅពីការបង្ខំចិត្តធ្វើការនោះទេ។

**៦៦៧.** មេធាវីការពារក្តី នួន ជា អះអាងថា ការចោទប្រកាន់អំពីការធ្វើឲ្យទៅជាទាសករទាក់ទងនឹងមន្ទីរសន្តិសុខកម្រិតត្រឹមការងារដោយបង្ខំ។ ភាគីផ្សេងទៀតមិនបានធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងបញ្ហានេះនោះទេ។ ទាក់ទងនឹងការចោទប្រកាន់នានាដែលផ្អែកលើការងារដោយបង្ខំ អង្គជំនុំជម្រះកត់សម្គាល់ថា ដីកាដំណោះស្រាយបញ្ជាក់ថា វាមិនមែនជាការងារដោយបង្ខំតែមួយនោះទេ ប៉ុន្តែការងាររួមជាមួយនឹងការដាក់កំហិតទៅលើជនរងគ្រោះដែល «បានដកហូតពីជនរងគ្រោះនូវអំណាចសម្រេចរបស់ខ្លួនបង្កើតបានជាការធ្វើឲ្យទៅជាទាសករ»។ លើសពីនេះទៀតដីកាដំណោះស្រាយ កំណត់អំពីធាតុផ្សំសត្យានុម័តដែលមានលក្ខណៈទូលាយមួយ ពាក់ព័ន្ធនឹងសហករណ៍ការដ្ឋានការងារ និងមន្ទីរសន្តិសុខ ដែលថាបានអនុវត្ត «ការគ្រប់គ្រងនិងអំណាច ទាំងស្រុងដែលដូចគ្នានឹងសិទ្ធិលើកម្មសិទ្ធិទៅលើបុគ្គលដែលស្ថិតនៅទីនោះ ដោយមិនឲ្យបុគ្គលទាំងនោះមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទទួលយកឡើយ។ ដីកាដំណោះស្រាយចោទប្រកាន់បន្ថែមទៀតថា ប.ក.ក. បានបង្កើតបណ្តាញសហករណ៍ ការដ្ឋានការងារ និងមន្ទីរសន្តិសុខដែល «រាល់ការសម្រេចស្ទើរតែទាំងអស់ទាក់ទងទៅនឹងមជ្ឈដ្ឋានផ្លូវកាយរបស់ជនរងគ្រោះ ត្រូវធ្វើឡើងដោយយកកម្មាភិបាលមូលដ្ឋានរបស់ ប.ក.ក.។

៦៦៨. ទាក់ទិនការចោទប្រកាន់នានាផ្អែកលើការងារដោយបង្ខំ មេធាវីការពារក្តី នួន ជា លើកឡើងថា ដើម្បីកំណត់ជាបទឧក្រិដ្ឋការធ្វើឲ្យទៅជាទាសករ ការងារដោយបង្ខំត្រូវតែខុសច្បាប់និងមានភាពធ្ងន់ធ្ងរមួយជាក់លាក់។ មេធាវីការពារក្តីអះអាងថា ការប្រើប្រាស់ការងារដោយបង្ខំពុំមែនខុសច្បាប់រហូតនោះទេហើយថា ការតម្រូវឲ្យបុគ្គលម្នាក់ៗធ្វើការនៅក្នុងដំណើរការឃុំខ្លួនស្របច្បាប់ ពុំអាចចាត់ទុកជាការរំលោភសិទ្ធិមនុស្សនោះឡើយ។ លើសពីនេះទៀតមេធាវីការពារក្តីអះអាងថា «សេវាណាមួយដែលតម្រូវឲ្យធ្វើឡើងក្នុងករណីស្ថានភាពបន្ទាន់ឬការគំរាមកំហែងជីវិត ឬសុខភាពរបស់សហគមន៍» ពុំត្រូវបានចាត់ទុកជាការរំលោភសិទ្ធិមនុស្សនោះឡើយ។ នៅក្នុងការវាយតម្លៃអំពីភាពធ្ងន់ធ្ងរនៃការងារដោយបង្ខំបានចោទប្រកាន់នោះ មេធាវីការពារក្តី នួន ជា លើកឡើងថា អំពើនេះគួរត្រូវបានយកមកពិនិត្យដោយពិចារណាអំពីស្ថានភាពរស់នៅនិងលក្ខខណ្ឌការងារលំបាកធ្ងន់ធ្ងររបស់កសិករ និងអ្នកធ្វើការផ្សេងៗទៀត នៅក្នុងប្រទេសកម្ពុជានៅពេលនោះ។ ភាគីផ្សេងទៀតមិនបានធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងបញ្ហានេះនោះទេ។

៦៦៩. អង្គជំនុំជម្រះកត់សម្គាល់ថា អនុលោមតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ការងារដោយបង្ខំឬដោយខានមិនបាន មិនត្រូវរាប់បញ្ចូលការងារ ឬសេវា «ដែលតម្រូវជាធម្មតាចំពោះជនជាប់ឃុំតាមបទបញ្ជាស្របច្បាប់របស់តុលាការ» នោះទេ។ ការងារបែបនេះ មិនមែនជាផលវិបាកនៃការបំពារបំពានទៅលើសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួនរបស់ជនណាម្នាក់ឡើយ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ បានបញ្ជាក់ច្បាស់ថាការហាមឃាត់ប្រឆាំងនឹងការងារដោយបង្ខំឬដោយខានមិនបានមិនត្រូវយកមកបកស្រាយថា ហាមឃាត់ការអនុវត្តទោសឲ្យធ្វើការដោយបង្ខំ ស្របតាមការវិនិច្ឆ័យទោសដោយតុលាការមានសមត្ថកិច្ចនៅក្នុងប្រទេសកម្ពុជាដែលបទឧក្រិដ្ឋខ្លះអាចមានទោសជាប់គុកឲ្យធ្វើការដោយបង្ខំទេ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយចែងបន្ថែមទៀតថា ការងារដោយបង្ខំ ឬដោយខានមិនបានមិនត្រូវរាប់បញ្ចូល «សេវាដែលតម្រូវក្នុងករណីមានអាសន្ន ឬគ្រោះមហន្តរាយនោះ លក្ខណៈ និងលក្ខខណ្ឌការងារត្រូវតែមានតុល្យភាពជាមួយនឹងលក្ខណៈនៃការគំរាមកំហែងដល់សុខុមាលភាពសហគមន៍និងកាលៈទេសៈនៃស្ថានភាពអាសន្ននោះ។ លើសពីនេះទៀតប្រសិនបើវិបត្តិឬស្ថានភាពអាសន្នគឺជាលទ្ធផលនៃសកម្មភាពខុសច្បាប់ផ្ទាល់របស់ចារីនោះ វិធានការបែបនោះមិនមានយុត្តិកម្មឡើយ។ ដូចបានពិភាក្សាពីខាងលើរួចហើយ ទោះបីជាយុត្តិសាស្ត្របានបញ្ជាក់ច្បាស់ថាការធ្វើឲ្យទៅជាទាសករ មានលក្ខណៈទូលំទូលាយជាងទាសភាព (ដែលការហាមឃាត់ចំពោះបទល្មើសនេះជាបទដ្ឋានមានលក្ខណៈអាជ្ញាបញ្ជាក់) ក៏ដោយ ប៉ុន្តែវាមានប្រភពដើមតែមួយដែរ។ ហេតុដូច្នេះទោះបីជាមានស្ថានភាពតិចតួចដែលប្រជាជនត្រូវបានបង្ខំឲ្យធ្វើការក៏ដោយ ប្រសិនបើលក្ខខណ្ឌនានាហួសពីការងារមនុស្ស អំពើបែបនេះបង្កើតបានជាការធ្វើឲ្យទៅជាទាសករ ដូច្នេះមិនមានយុត្តិធម៌ឡើយ ទោះបីជាក្នុងកាលៈទេសៈណាក៏ដោយ។ យ៉ាងណាមិញ ការវាយតម្លៃចុងក្រោយនឹងត្រូវធ្វើឡើងដូចខាងក្រោមនេះ តាមការចាំបាច់ទៅលើអង្គហេតុនានានៃរឿងក្តី។

៦៧០. ធាតុផ្សំអត្តនោម័តិនៃការធ្វើឲ្យទៅជាទាសករ គឺការប្រើប្រាស់ដោយចេតនានូវ«អំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់»ទៅលើមនុស្ស។

### ៩.១.៤. ការនិរទេស

៦៧១. ទាក់ទិនសំណុំរឿង ០០២/០២ ដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការនិរទេស នៅសហគមន៍ត្រាំកក់ ព្រមទាំងនៅខេត្តព្រៃវែង និង ខេត្តស្វាយរៀង។ មានការចោទប្រកាន់ថា ជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជាត្រូវបានបង្ខំឲ្យចាកចេញពីទឹកដីដែលពួកគេបានស្នាក់នៅដោយស្របច្បាប់ និងឲ្យឆ្លងព្រំដែនទៅប្រទេសវៀតណាម។

**៦៧២.** *ជាបញ្ហាបឋម អង្គជំនុំជម្រះត្រូវកំណត់ថា តើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាការនិរទេសត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មដែរឬទេ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅមុនថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥។ ការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានវិវត្តចេញពីការនិរទេសដែលជាឧក្រិដ្ឋកម្មសង្គ្រាម ដែលត្រូវបានទទួលស្គាល់នៅមុនសង្គ្រាមលោកលើកទីពីរ។ ការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រមូលចងក្រងនៅក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ (IMT) ធម្មនុញ្ញតុលាការយោធាអន្តរជាតិចុងបូព៌ា (IMT-FE) ច្បាប់លេខ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង និងគោលការណ៍ Nuremberg។ បន្ទាប់មកទៀតតុលាការបង្កើតក្រោយសង្គ្រាមលោកលើកទីពីរមួយចំនួនបានធ្វើការផ្តន្ទាទោសទៅលើឧក្រិដ្ឋកម្មនេះ។ នៅក្នុងឆ្នាំ១៩៤៦ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តជាឯកច្ឆន្ទនូវសេចក្តីសម្រេចលេខ៩៥ (I) គាំទ្រដល់ធម្មនុញ្ញតុលាការយោធាអន្តរជាតិ និងសាលក្រមដែលឆ្លុះបញ្ចាំងពីគោលការណ៍នៃច្បាប់អន្តរជាតិ។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថាសេចក្តីសម្រេចនេះជាភស្តុតាងនៃ «ការបង្ហាញឆន្ទៈទទួលយកជាច្បាប់ (Opinion juris) ក្នុងចំណោមរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ដែលធម្មនុញ្ញតុលាការយោធាអន្តរជាតិ និងសាលក្រមនេះ»។ ផ្អែកលើការពិនិត្យមើលឡើងវិញរបស់ខ្លួនទៅលើយុត្តិសាស្ត្រលិខិតុបករណ៍មុនឆ្នាំ១៩៧៥ អង្គជំនុំជម្រះពិចារណា ការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានកំណត់នៅក្នុងច្បាប់ ទំនៀមទម្លាប់អន្តរជាតិត្រឹមឆ្នាំ១៩៧៥។*

**៦៧៣.** *ពាក់ព័ន្ធភាពអាចប្រមើលឃើញជាមុនថាជាបទល្មើស និងអាចដឹងថាមានច្បាប់ចែងអំពីការនិរទេសថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អង្គជំនុំជម្រះពិចារណាទៅលើក្របខណ្ឌនៃច្បាប់ទំនៀមទម្លាប់ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មប្រឆាំងនិងតួនាទីរបស់ជនជាប់ចោទក្នុងនាមជាសមាជិកនៃអាជ្ញាធរគ្រប់គ្រងប្រទេសកម្ពុជា។ បន្ទាប់ពីបានថ្លឹងថ្លែងទៅលើកត្តាទាំងនេះដោយសត្យានុម័ត អង្គជំនុំជម្រះសន្និដ្ឋានថា ជនជាប់ចោទអាចមើលឃើញនិងដឹងជាទូទៅថាការនិរទេសត្រូវបានផ្តន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គិតត្រឹមឆ្នាំ១៩៧៥។*

**៦៧៤.** *ធាតុផ្សំសត្យានុម័តនៃការនិរទេស គឺការផ្លាស់ទីលំនៅមនុស្សដោយបង្ខំតាមរយៈការបណ្តេញចេញ ឬអំពើបង្ខិតបង្ខំផ្សេងៗទៀតអំពីតំបន់ដែលពួកគេកំពុងមានវត្តមានដោយស្របច្បាប់ឲ្យឆ្លងកាត់ព្រំដែនដោយមិនមានមូលដ្ឋានអនុញ្ញាតក្រោមច្បាប់អន្តរជាតិ។ មិនមានភាគីណាមួយជំទាស់ចំពោះនិយមន័យនេះទេ។*



*យោធាខ្មែរក្រហមឈរនៅជិតយន្តហោះដែលខូចខាតដោយសារគ្រាប់ផ្លោងនៅព្រលានយន្តហោះពោធិ៍ចិនតុង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

៦៧៥. សហព្រះរាជអាជ្ញាបានលើកឡើងថា លក្ខខណ្ឌតម្រូវដែលថា ជនរងគ្រោះ«មានវត្តមានដោយស្របច្បាប់» នៅក្នុងតំបន់នោះគឺមិនអាចដូចគ្នាទៅនឹងទស្សនៈនៃ«លំនៅដ្ឋានស្របច្បាប់ហើយថាអ្នករស់នៅស្របច្បាប់ រួមបញ្ចូលទាំងជនភៀសខ្លួន និងបុគ្គលដែលគ្មានសញ្ជាតិ។ ភាគីផ្សេងទៀតមិនបានដាក់សារណាពាក់ព័ន្ធបញ្ហានេះនោះឡើយ។

៦៧៦. បញ្ហានេះត្រូវបានដោះស្រាយនៅចំពោះមុខតុលាការ ICTY ដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងរឿងក្តី Popovic ដែលបញ្ជាក់ថា៖

អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ពាក្យ «មានវត្តមានដោយស្របច្បាប់» គួរទទួលបាននូវអត្ថន័យទូទៅរបស់ពាក្យនេះ ហើយមិនគួរចាត់ទុកថាមានន័យដូចគ្នាទៅនឹងទស្សនៈនៃច្បាប់នៃពាក្យលំនៅដ្ឋានស្របច្បាប់ឡើយ។ ចេតនាច្បាស់លាស់នៃការហាមឃាត់មិនឲ្យផ្លាស់ទៅដោយបង្ខំនិងការនិរទេស គឺដើម្បីរារាំងមិនឲ្យមានការបំផ្លិចបំផ្លាញជាទ្រង់ទ្រាយធំទៅលើសហគមន៍។ ក្នុងន័យនេះ ទោះបីជាបុគ្គលម្នាក់បានរស់នៅក្នុងទីកន្លែងមួយក្នុងរយៈពេលសមស្របគ្រប់គ្រាន់ឬមិនគ្រប់គ្រាន់ដើម្បីបំពេញបានតាមលក្ខខណ្ឌតម្រូវការនៃការតាំងទីលំនៅឬថាតើបុគ្គលនោះត្រូវបានផ្តល់នូវឋានៈបែបនេះ តាមច្បាប់អន្តោប្រវេសន៍ គឺជាបញ្ហាដែលមិនមានភាពពាក់ព័ន្ធឡើយ។ ប៉ុន្តែអ្វីដែលសំខាន់គឺថា ការការពារត្រូវបានផ្តល់ជូនទៅអ្នកទាំងឡាយណាដែលបានមក«រស់នៅ» នៅក្នុងសហគមន៍មួយ ទោះបីជាដោយសារហេតុផលអ្វីក៏ដោយ មិនថាការរស់នៅនោះជាការរស់នៅរយៈពេលវែងឬបណ្តោះអាសន្នឡើយ[...]។

៦៧៧. អង្គជំនុំជម្រះសាលាដំបូងពិចារណាថា សំអាងហេតុនេះ គឺអាចជឿជាក់បាន។ អង្គជំនុំជម្រះក៏កត់សម្គាល់ផងដែរថា យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរ បានសម្រេចថា ការនិរទេសគ្របដណ្តប់ផងដែរទៅលើបុគ្គលដែលគ្មានសញ្ជាតិ ជនភៀសខ្លួននៅក្នុងតំបន់ដែលត្រូវបានគ្រប់គ្រង និងអ្នកដទៃទៀតដែលបានស្នាក់នៅជាក់ស្តែងនៅក្នុងរដ្ឋជាក់លាក់ណាមួយដោយមិនបានយោងទៅលើឋានៈតាមច្បាប់នៃការស្នាក់នៅរបស់ពួកគេនោះឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះពិចារណាថា មិនចាំបាច់ត្រូវបង្ហាញភស្តុតាងដើម្បីកំណត់ឋានៈផ្លូវច្បាប់របស់ជនរងគ្រោះឡើយ។

៦៧៨. នាពេលនោះ អង្គជំនុំជម្រះនឹងពិនិត្យទៅលើលក្ខខណ្ឌតម្រូវ គឺការឆ្លងកាត់ព្រំដែនសម្រាប់ការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ យុត្តិសាស្ត្ររបស់តុលាការ ICTY បានពិចារណាយ៉ាងលម្អិតទៅលើលក្ខណៈនៃលក្ខខណ្ឌតម្រូវឆ្លងកាត់ព្រំដែន ហើយបានសន្និដ្ឋានថាការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតម្រូវថា បុគ្គលទាំងឡាយត្រូវបានផ្លាស់ទី«ឆ្លងកាត់ព្រំដែនរដ្ឋឬក្នុងកាលៈទេសៈជាក់លាក់គឺព្រំដែនជាក់ស្តែង»។ អង្គហេតុដែលបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០២ មានត្រឹមតែការផ្លាស់ទីឆ្លងកាត់ព្រំដែនប្រទេស រវាងប្រទេសកម្ពុជា នឹងប្រទេសវៀតណាមប៉ុណ្ណោះ។ ហេតុដូច្នេះ អង្គជំនុំជម្រះពិចារណាថា អង្គជំនុំជម្រះគ្រាន់តែត្រូវកំណត់ដោយយោងទៅបទប្បញ្ញត្តិច្បាប់ និងយុត្តិសាស្ត្រនៅមុនឆ្នាំ១៩៧៥ ប៉ុណ្ណោះ ដើម្បីថាតើច្បាប់នៅក្នុងឆ្នាំ១៩៧៥ បានគ្របដណ្តប់ទៅលើការផ្លាស់ទីឆ្លងកាត់ព្រំដែនរដ្ឋបែបនេះដែរឬយ៉ាងណា។

៦៧៩. រឿងក្តីក្រោយសង្គ្រាមលោកលើកទីពីរជាច្រើនបានធ្វើការសម្រេចលើអង្គច្បាប់ ឬអង្គហេតុ ថាការនិរទេសគ្របដណ្តប់ទៅលើការឆ្លងកាត់ព្រំដែនរដ្ឋ។ សាលក្រមនៃរឿងក្តី The Krupp បានអនុម័តយកមតិស្របរបស់ចៅក្រម Philips ពីសាលក្រមនៃរឿងក្តី Milch ដោយបញ្ជាក់ថា « ការផ្លាស់ទីក្រុមមនុស្សពីប្រទេសមួយទៅប្រទេសមួយទៀត គឺជាក្តីកង្វល់ដ៏សមស្របរបស់ច្បាប់អន្តរជាតិ ដោយសារតែវានាំឲ្យមានផលប៉ះពាល់ដល់សហគមន៍ប្រជាជាតិ។ ច្បាប់អន្តរជាតិបានបញ្ជាក់យ៉ាងច្បាស់នូវលក្ខខណ្ឌមួយចំនួន ដែលអង្គហេតុនៃការនិរទេស ពីប្រទេសមួយទៅប្រទេសមួយទៀត ក្នុងអំឡុងសង្គ្រាមអាចក្លាយទៅជាឧក្រិដ្ឋកម្មបាន» ។ ក្នុងន័យប្រហែលគ្នានេះនៅ

ក្នុងសាលក្រមនៃតុលាការ Nuremberg តុលាការយោធាអន្តរជាតិបានសម្រេចថា «មិនត្រឹមតែប្រឆាំងយ៉ាងផងដើលទៅនឹងវិធានច្បាប់អន្តរជាតិដែលបានកំណត់យ៉ាងច្បាស់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនខ្វល់ខ្វាយទាល់តែសោះអំពីវិធានជាសារវន្តនៃមនុស្សជាតិ[...] ប្រជាជនទាំងអស់ត្រូវបាននិរទេសទៅកាន់ប្រទេសអាល្លឺម៉ង់ ក្នុងគោលដៅធ្វើជាពលកម្មទាសករ»។ សាលក្រមនៃតុលាការ Nuremberg បានសម្រេចទៅលើការនិរទេសប្រជាជនរាប់ពាន់លាននាក់ពីតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រង ទៅកាន់ប្រទេសអាល្លឺម៉ង់ ហើយនិងការនិរទេសជនជាតិជ្វីបពី «តំបន់រណបរបស់ក្រុមសម្ព័ន្ធមិត្ត» ទៅកាន់ភាគខាងកើតមុនពេលដែលពួកគេត្រូវបានសម្លាប់ផ្តាច់ពូជ។ សាលក្រមនៃរឿងក្តី Flick ក៏បានធ្វើការសម្រេចចិត្តដូចដែរ ទាក់ទងទៅនឹង «ការនិរទេសទៅធ្វើជាពលកម្មទាសករ [នៅក្នុងឧស្សាហកម្មអាល្លឺម៉ង់] ក្នុងទ្រង់ទ្រាយធំសម្បើមរបស់សមាជិកនៃប្រជាជនស៊ីវិល នៅក្នុងបណ្តាប្រទេសដែលស្ថិតក្រោមការកាន់កាប់របស់ពួកឈ្លានពានអាល្លឺម៉ង់ ឬស្ថិតក្រោមការត្រួតត្រារបស់អាល្លឺម៉ង់»។

**៦៨០.** អង្គជំនុំជម្រះក៏បានពិចារណាផងដែរថា ប្រភពនានាពាក់ព័ន្ធនឹងការនិរទេសជាឧក្រិដ្ឋកម្មសង្គ្រាមមានលក្ខណៈ «ជួយផ្តល់ព័ត៌មាន ដោយសារតែការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិកើតចេញពីការនិរទេសដែលជាឧក្រិដ្ឋកម្មសង្គ្រាម»។ មាត្រា២៣ នៃក្រម Lieber ឆ្នាំ១៨៦៣ បានហាមឃាត់មិនឲ្យមានការនិរទេសនៅក្នុងអំឡុងពេលសង្គ្រាម ដោយបង្ហាប់ថា ក្រម Lieber មិនបានយោងជាក់ច្បាស់ទៅរកលក្ខខណ្ឌតម្រូវនៃការផ្លងកាត់ព្រំដែនក៏ដោយ តែនេះជាកត្តានាំមុខដែលឈានទៅដល់ការហាមឃាត់នៅពេលក្រោយមកទៀត ទៅលើការនិរទេសដែលរួមបញ្ចូលនូវលក្ខខណ្ឌតម្រូវបែបនេះ។ អង្គជំនុំជម្រះបានកត់សម្គាល់បន្ថែមថា មាត្រា ៤៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV បានយោងទៅរក « ការនិរទេសបុគ្គលដែលទទួលបានការការពារពីតំបន់ដែលស្ថិតនៅក្រោមការត្រួតត្រា ទៅកាន់តំបន់មហាអំណាចត្រួតត្រា ឬទៅកាន់ប្រទេសដទៃផ្សេងទៀត» ដែលករណីនេះស្របគ្នាជាមួយនឹងនិយមន័យនៃការនិរទេសដែលតម្រូវឲ្យមានការផ្លាស់ទីឆ្លងកាត់ព្រំដែនប្រទេស។

**៦៨១.** បន្ទាប់ពីបានត្រួតពិនិត្យរួចហើយ អង្គជំនុំជម្រះសម្រេចថា នៅក្នុងឆ្នាំ១៩៧៥ ការនិរទេសតម្រូវឲ្យមានការផ្លាស់ទីឆ្លងកាត់ព្រំដែនប្រទេសមួយ។

**៦៨២.** លក្ខណៈបង្ខំនៃការផ្លាស់ទីលំនៅ ត្រូវបានសម្រេចតាមរយៈការមិនមានជម្រើសពិតប្រាកដហើយពាក្យថា «បង្ខំ» អាចរួមបញ្ចូលទាំងការបង្ខំខាងរាយកាយ ព្រមទាំងការគំរាមថានឹងប្រើកម្លាំងឬការបង្ខិតបង្ខំ ដែលមានដូចជាការធ្វើឲ្យភ័យខ្លាចដោយអំពើហិង្សា ការបង្ខិតង្ខំ ការឃុំខ្លួន ការគាបសង្កត់ផ្លូវចិត្ត ការរំលោភអំណាច ឬអំពើកេងយកផលប្រយោជន៍ពីបរិយាកាសបង្ខិតបង្ខំ។ ដោយសារតែមិនមានជម្រើសពិតប្រាកដ ដែលធ្វើឲ្យមានការផ្លាស់ទីលំនៅក្លាយជាអំពើខុសច្បាប់ ហើយក្នុងករណីដែលមានការយល់ព្រម ការយល់ព្រមនោះត្រូវធ្វើឡើងដោយស្ម័គ្រចិត្តដែលជាលទ្ធផលនៃឆន្ទៈដោយសេរីរបស់បុគ្គលនោះ ហើយត្រូវវាយតម្លៃផ្អែកលើកាលៈទេសៈដែលនៅជុំវិញនោះ។

**៦៨៣.** មានកាលៈទេសៈមានកម្រិតមួយចំនួនតាមច្បាប់អន្តរជាតិ ដែលអនុញ្ញាតឲ្យមានការផ្លាស់ទីមនុស្សដោយពុំស្ម័គ្រចិត្ត ឧទាហរណ៍ ការផ្លាស់ទីមនុស្សដើម្បីសន្តិសុខផ្ទាល់ខ្លួនរបស់ពួកគេ ឬដោយសារហេតុផលយោធាចាំបាច់។ សហព្រះរាជអាជ្ញាបានលើកឡើងថា ដោយសារតែលក្ខណៈធ្ងន់ធ្ងរនៃការផ្លាស់ទីលំនៅដោយបង្ខំយុត្តិកម្មសម្រាប់ការជម្លៀស «អាចស្របច្បាប់ទៅបានតែក្នុងកាលៈទេសៈដ៏ធ្ងន់ធ្ងរបំផុតប៉ុណ្ណោះ»។ សហព្រះរាជអាជ្ញាបានលើកឡើងបន្ថែមទៀតថា ដើម្បីផ្តល់យុត្តិកម្មលើការផ្លាស់ទីលំនៅដោយបង្ខំ ដោយផ្អែកលើមូលដ្ឋាននៃភាពចាំបាច់ផ្នែកយោធានោះ ផ្នែកយោធាគឺជាកត្តាចាំបាច់ត្រូវពិចារណា ហើយបើត្រឹមតែដើម្បីផលប្រយោជន៍ផ្នែកយោធា

តែមួយគត់នោះ គឺមិនគ្រប់គ្រាន់ឡើយ។ ក្នុងន័យនេះ សហព្រះរាជអាជ្ញាលើកឡើងថា ការជម្លៀសក្នុងគោលបំណង«ទប់ស្កាត់ចារកម្មដកហូតកម្លាំងខ្មាំង» ពុំមែនជាយុត្តិកម្មឡើយ។ មេធាវីការពារក្តី នួន ជា បានលើកឡើងថាសហព្រះរាជអាជ្ញាមិនបានអនុវត្តបន្ទុកក្នុងការបង្ហាញភស្តុតាងដែលកំណត់ថាការផ្លាស់ទីលំនៅប្រជាជនបានលើឡើងជាការរំលោភទៅលើច្បាប់អន្តរជាតិនោះទេ។ ភាគីផ្សេងទៀតមិនបានដាក់សារណាពាក់ព័ន្ធនឹងបញ្ហានេះនោះឡើយ។

**៦៨៤**. អង្គជំនុំជម្រះកត់សម្គាល់ថា ការសម្រេចថាតើអំពើមួយអាចអនុញ្ញាតបានដែរឬទេ តាមច្បាប់អន្តរជាតិនោះ គឺត្រូវឲ្យមានការវាយតម្លៃទៅលើបទប្បញ្ញត្តិនៃក្របខណ្ឌច្បាប់ជាធរមាននិងអំពើបរិបទអង្គហេតុតាមករណីនីមួយៗ។ ក្នុងករណីដែលវិធាននៃការជម្លៀសបុគ្គលធ្វើឡើងដើម្បីប្រយោជន៍សន្តិសុខដល់ជនស៊ីវិលឬភាពចាំបាច់ផ្នែកយោធា វិធានការនេះត្រូវតែសមាមាត្រទៅនឹងផលប្រយោជន៍ដែលត្រូវបានការពារ និងត្រូវតែ«ធ្វើឡើងតាមមធ្យោបាយដែលមិនបង្កផលប៉ះពាល់ធ្ងន់ធ្ងរ ក្នុងចំណោមវិធានការទាំងឡាយដែលអាចយកមកប្រើដើម្បីសម្រេចគោលដៅដែលចង់បាន»។ ដោយស្របគ្នាជាមួយនឹងការការពារដែលមានចែងនៅក្នុងមាត្រា ៤៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV អង្គជំនុំជម្រះយល់ឃើញថា បើទោះបីជាបុគ្គលទាំងឡាយត្រូវបានជម្លៀសដោយស្របច្បាប់ដើម្បីសន្តិសុខរបស់ពួកគេឬដោយសារភាពចាំបាច់ផ្នែកយោធាក៏ដោយ តែអ្នកដែលត្រូវជម្លៀសទាំងអស់នោះចាំបាច់ត្រូវតែបញ្ជូនឲ្យវិលត្រឡប់មកកាន់ផ្ទះសម្បែងរបស់ពួកគេវិញភ្លាមៗ បន្ទាប់ពីភាពប្រទូសរ៉ាយនៅក្នុងតំបន់នោះបានបញ្ចប់។ បន្ថែមពីលើនេះទៀត អ្នកដែលទទួលខុសត្រូវចំពោះការជម្លៀស«ត្រូវធានាក្នុងកម្រិតដែលអាចអនុវត្តជាក់ស្តែងបានថា កន្លែងស្នាក់អាស្រ័យសមរម្យត្រូវបានផ្តល់ជូន ដើម្បីទទួលជនដែលត្រូវទទួលបានការការពារ ហើយការផ្លាស់ទីលំនៅត្រូវធ្វើឡើងនៅក្នុងលក្ខខណ្ឌផ្នែកអនាម័យ សុខភាព សុវត្ថិភាព និងអាហារូបត្ថម្ភ ហើយសមាជិកគ្រួសារមិនត្រូវបានបំបែកចេញពីគ្នាឡើយ»។ ទោះបីជាការផ្លាស់ទីលំនៅដោយមូលហេតុមនុស្សធម៌អាចធ្វើយុត្តិកម្មបាននៅក្នុងស្ថានភាពមួយចំនួនក៏ដោយ តែអំពើនេះមិនអាចធ្វើយុត្តិកម្មបានឡើយ ក្នុងករណីដែលស្ថានភាពមនុស្សធម៌នោះបណ្តាលមកពីអំពើមិនស្របច្បាប់របស់ជនដាប់ចោទខ្លួនឯងដែលបណ្តាលឲ្យមានការផ្លាស់ទីលំនៅដូច្នេះ។

**៦៨៥**. មេធាវីការពារ នួន ជា បានលើកឡើងថា អត្ថិភាពនៃជម្លោះរវាងវៀតណាម និង កម្ពុជាបង្កើតឲ្យមាន«មូលហេតុស្របច្បាប់ដែលនាំដល់ការបញ្ជូនជនជាតិវៀតណាមទៅប្រទេសវៀតណាមវិញ» ដែលជាទស្សនៈមួយគាំទ្រដោយការពិតដែលថា រដ្ឋអំណាចកម្ពុជា និងវៀតណាមបានសហការគ្នានៅក្នុងបញ្ហានេះ។ ភាគីផ្សេងទៀតមិនបានធ្វើសេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងបញ្ហានេះបញ្ហានោះទេ។ អង្គជំនុំជម្រះយល់ឃើញថា ត្រឹមតែអត្ថិភាពនៃកិច្ចព្រមព្រៀងរវាងរដ្ឋអំណាចតំណាងឲ្យភាគីនៃជម្លោះប្រដាប់អាវុធក្នុងការផ្លាស់ប្តូរក្រុមមនុស្សដែលត្រូវផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយ គឺមិនមានផលប៉ះពាល់ទៅលើលក្ខណៈស្ម័គ្រចិត្តឬភាពស្របច្បាប់នៃការផ្លាស់ទីលំនៅនោះឡើយ។ ផ្ទុយពីការលើកឡើងរបស់មេធាវីការពារក្តី នួន ជា «មេបញ្ជាការយោធាឬមេដឹកនាំនយោបាយមិនអាចផ្តល់ការយល់ព្រមក្នុងនាមបុគ្គលម្នាក់ៗឡើយ» កិច្ចព្រមព្រៀងបែបនេះមិនអាចផ្លាស់ប្តូរស្ថានភាពដែលធ្វើឲ្យការផ្លាស់ទីលំនៅ ក្លាយទៅជាស្របច្បាប់ឡើយ» ហើយ «អ្វីដែលសំខាន់គឺការយល់ព្រមផ្ទាល់ឬបំណងប្រាថ្នាផ្ទាល់របស់បុគ្គលម្នាក់ៗដែលខុសគ្នាពីការយល់ព្រមជារួមក្នុងនាមជាក្រុមមួយ ឬការយល់ព្រមដែលធ្វើឡើងដោយរដ្ឋអំណាចផ្លូវការក្នុងនាមមនុស្សម្នាក់ៗឬក្រុមមនុស្សមួយក្រុមៗ។

**៦៨៦**. ធាតុផ្សំអត្តនោម័តិនៃការនិរទេស តម្រូវឲ្យមានចេតនាក្នុងការផ្លាស់ទីលំនៅជនរងគ្រោះដោយបង្ខំឲ្យឆ្លងកាត់ព្រំដែនប្រទេសមួយ។ មិនមានភាពចាំបាច់ក្នុងការបង្ហាញនូវចេតនាក្នុងការផ្លាស់ទីតាំងនៅមនុស្សឆ្លងកាត់ព្រំដែនជាអចិន្ត្រៃយ៍នោះឡើយ។

**តទៅលេខក្រោយ**

# រឿងរ៉ាវសង្ខេបរបស់ប្រជាជន
## នៅស្រុកអន្លង់វែងតាមរយៈវេទិកាប្រវត្តិសាស្ត្រគ្រួសារ

**សួត វិចិត្រ**

ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង រួមមានបណ្ឌិត លី សុខឃាង, សួត វិចិត្រ មេក វិន, ហ៊ាន ពិសី តាមរយៈគម្រោងប្រវត្តិសាស្ត្រគ្រួសារ បានរៀបចំវេទិកាសាធារណ និងសម្ភាសន៍ប្រជាជននៅក្នុងសហគមន៍អន្លង់វែងអំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម រយៈពេល៤ថ្ងៃ ចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០២១។ ខាងក្រោមគឺជាសាច់រឿងសង្ខេបរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម៖



អៀ ណុប

អៀ ណុប ភេទប្រុស អាយុ៦៣ឆ្នាំ មានស្រុកកំណើតនៅក្នុងភូមិព្រៃស្បាត ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ សព្វថ្ងៃរស់នៅក្នុងឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

កាលពីសម័យសង្គមរាស្ត្រនិយម គ្រួសាររបស់ខ្ញុំមានជីវភាពលំបាកណាស់។ ខ្ញុំមានបងប្អូនបង្កើតចំនួន៩នាក់។ កាលពីកុមារភាព ខ្ញុំមិនបានរៀនសូត្រជ្រៅជ្រះទេ ដោយសារតែជីវភាពខ្វះខាត ម្យ៉ាងទៀតស្រុកទេសកំពុងកើតមានសង្គ្រាម។ នៅចន្លោះឆ្នាំ១៩៧៣-១៩៧៤ ខ្ញុំបានសម្រេចចិត្តចូលធ្វើជាកងទ័ព។ បន្ទាប់ពីខ្ញុំចូលធ្វើកងទ័ព ខ្មែរក្រហមបានបញ្ជូនខ្ញុំទៅខាងភ្នំដិន។ បន្ទាប់ពីទៅដល់ទីនោះ ការងារដែលខ្ញុំត្រូវធ្វើគឺស្ពាយបាយឲ្យកងទ័ពនៅសមរភូមិមុខ។ ខ្ញុំឈរជើងនៅទីនោះរហូតដល់ឆ្នាំ១៩៧៥ ខ្មែរក្រហមទទួលបានជ័យជម្នះនៅទីក្រុងភ្នំពេញ។ ខ្ញុំត្រូវបានបញ្ជូនឲ្យនៅទីរួមខេត្តតាកែវវិញ។ នៅទីនោះ ខ្មែរក្រហមមិនបានឲ្យខ្ញុំធ្វើការធំដុំទេ គឺខ្ញុំទៅឃ្វាលគោ និងឃ្វាលក្របី។ ចំណែកខែប្រាំង ខ្ញុំទៅជួយស្ទូងស្រូវមីងៗ។ កាលណោះអ្នកគ្រប់គ្រងនៅទីរួមខេត្តតាកែវ គឺមានតាម៉ុក និងតាសោម។ តាសោមមានតួនាទីជាប្រធានតំបន់។ របបអាហារនៅក្នុងឆ្នាំ១៩៧៥ មិនទាន់មានការខ្វះខាតប៉ុន្មានទេ។ រហូតដល់ឆ្នាំ១៩៧៦ ទើបមានការលំបាកខ្លាំង ទាំងការហូបចុក ទាំងការរស់នៅ ដោយសារខ្មែរក្រហមបញ្ចូលប្រជាជនទៅក្នុងសហករណ៍ ហូបរួម ដេករួម និងធ្វើការរួម។ ខ្ញុំរស់នៅ និងធ្វើការនៅសហករណ៍ដូចជា ស្ទូងស្រូវ និងរែកដី។ រហូតដល់ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានចូលដល់ខេត្តតាកែវ។ នៅដើមឆ្នាំ១៩៨០ ខ្ញុំបានធ្វើដំណើរត្រឡប់ទៅជួបជុំឪពុកម្តាយនៅស្រុកកំណើតវិញ។ ខ្ញុំជួយឪពុកម្តាយធ្វើស្រែចម្ការ និងឡើងត្នោត។ នៅឆ្នាំ១៩៨១ ខ្ញុំបានរៀបការ។

នៅឆ្នាំ២០០០ ខ្ញុំបានសម្រេចចិត្តមករកស៊ីកាន់ម៉ាស៊ីនអាឈើឲ្យតា នូ រ៉ាត់ បានរយៈពេល១ឆ្នាំនៅអន្លង់វែង។ បន្ទាប់មកខ្ញុំបានទាក់ទងទៅប្រពន្ធកូននៅឯស្រុកកំណើតឲ្យមករស់នៅក្នុងស្រុកអន្លង់វែងជាមួយគ្នា។ នៅពេលដែលខ្ញុំមកដល់តំបន់អន្លង់វែងមុនដំបូងគឺសុទ្ធតែព្រៃ មិនសូវមានប្រជាជនរស់នៅដូចសព្វថ្ងៃនេះទេ។ ទឹកដីអន្លង់វែងសម្បូរទៅដោយ

ដើមឈើមានតម្លៃៗ ខ្ញុំមករស់នៅអន្លង់វែងក្នុងគោលបំណងប្រកបរបរចិញ្ចឹមជីវិត ប៉ុន្តែក្រោយមកទើបដឹងថាអ្នក មករស់នៅអន្លង់វែងភាគច្រើនមានស្រុកកំណើតនៅតាកែវដូចខ្ញុំដែរ ទើបខ្ញុំសម្រេចចិត្តរស់នៅអន្លង់វែងបន្តរហូតដល់សព្វថ្ងៃនេះ។



**ឆាំ ឡុង**

ឆាំ ឡុងភេទស្រីអាយុ៦៥មានស្រុកកំណើតនៅឃុំកៀនសង្កែ ស្រុកជីក្រែង ខេត្តសៀមរាប។ សព្វថ្ងៃរស់នៅក្នុងភូមិទឹកជុំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

នៅក្នុងឆ្នាំ១៩៧១ ខ្ញុំបានធ្វើដំណើរមកកាន់ទឹកដីអន្លង់វែង។ កាលណោះខ្ញុំមកអន្លង់វែងដោយមើលត្រីវិស័យ។ ខ្ញុំមកជាមួយក្រុមគ្រូពេទ្យមួយចំនួនរួមជាមួយកងពលនិងវរសេនាតូចៗ ខ្ញុំ និងអ្នករួមដំណើរទាំងអស់បានដើរកាត់ព្រៃស្អាក។ នៅតាមផ្លូវជួបសត្វជាច្រើនប្រភេទដូចជា ខ្លា ដំរី ទន្សោង និង ខ្ទីញ ជាដើម។ ក្រុមខ្ញុំដើររហូតមកដល់ភូមិរំចេក ក៏ស្នាក់នៅទីនោះដើម្បីព្យាបាលជំងឺឲ្យប្រជាជននៅក្នុងស្រុកអន្លង់វែង។ នៅពេលដែលខ្ញុំទៅដល់ភូមិរំចេកមុនដំបូង ប្រជាជននៅទីនោះភាគច្រើនកើតជំងឺក្រាំង។ ជំងឺប្រភេទនេះភាគច្រើនចេញដំបៅនៅលើមាត់ និងច្រមុះ។ ក្រុមគ្រូពេទ្យរបស់ខ្ញុំបានព្យាបាលជំងឺក្រាំងឲ្យប្រជាជនក្នុងភូមិរំចេករហូតជាសះស្បើយ។ បន្ទាប់មកក្រុមរបស់ខ្ញុំត្រូវទៅព្យាបាលប្រជាជន នៅភូមិផ្អាវបាក់នឹម តាដេវ លំទង និង ភូមិចា ទៀត។ ចំពោះជំងឺគ្រុនចាញ់ ប្រជាជនរួមទាំងក្រុមខ្ញុំក៏កើតមានច្រើនដែរ ដោយសារយើងចាញ់ទឹកដី។ រហូតដល់ឆ្នាំ១៩៧៣ មានការទម្លាក់គ្រាប់បែកនៅក្នុងភូមិរំចេក ដូច្នេះខ្ញុំរួមទាំងប្រជាជនទាំងអស់នាំគ្នារត់ឡើងភ្នំដងរែក។ នៅចន្លោះឆ្នាំ១៩៧៥-១៩៧៦ ចាប់ផ្តើមមានការផ្លាស់ប្តូរការរស់នៅដោយប្រជាជនទាំងអស់ត្រូវប្រមូលទ្រព្យសម្បត្តិដាក់ចូលក្នុងសហករណ៍ ហើយត្រូវហូបបាយរួម និងធ្វើការងាររួមៗ ចាប់ពីពេលនោះមកការហូបចុកមិនបានគ្រប់គ្រាន់ទេ។ ពេលខ្លះខ្ញុំហូបបាយ ពេលខ្លះហូបបបរ ដំឡូង និងក្តួចខ្លះ។ ចំណែកការស្លៀកពាក់អ្នកនៅក្នុងសហករណ៍ និងអង្គភាពស្លៀកពាក់ពណ៌ខ្មៅ។

នៅដើមឆ្នាំ១៩៧៩ កងទ័ពវៀតណាមចូលមកដល់រំចេក ខ្ញុំបានរត់ឡើងភ្នំ និងបន្តទៅរស់នៅក្នុងជំរំភូណយ។ ការរស់នៅក្នុងជំរំភូណយយើងមានជីវភាពប្រសើរជាងមុន។ ចំពោះការហូបចុក កាកបាទក្រហម និងតាម៉ុកជាអ្នកផ្គត់ផ្គង់ឲ្យមិនមានការខ្វះខាតឡើយ។ បន្ទាប់ពីទៅដល់ទីនោះបានមួយឆ្នាំ ខ្ញុំបានរៀបការ។ ក្រោយពីរៀបការរួច ខ្ញុំបន្តរស់នៅក្នុងជំរំភូណយទៀត។ នៅឆ្នាំ១៩៩៨ យោធាខ្មែរក្រហមនៅតំបន់អន្លង់វែងធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាល។ ដូច្នេះខ្ញុំរួមទាំងប្រជាជនដែលរស់នៅក្នុងជំរំភូណយចេញពីជំរំមករស់នៅក្នុងស្រុកអន្លង់វែងរហូតមកដល់សព្វថ្ងៃនេះ។



**យូ ណោត**

យូ ណោត ភេទប្រុស អាយុ៦៧ឆ្នាំ មានស្រុកកំណើតនៅឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល។ សព្វថ្ងៃរស់នៅក្នុងភូមិទឹកជុំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

កាលពីខ្ញុំនៅស្រុកកំណើតក្នុងកំឡុងឆ្នាំ១៩៧០ មានការទម្លាក់គ្រាប់បែកក្នុងភូមិឃុំរបស់ខ្ញុំយ៉ាងសន្ធោសន្ធៅ។ ដោយសារតែមានភាពវឹកវរអសន្តិសុខខ្លាំងពេក ខ្ញុំសម្រេចចិត្តចូលបម្រើយោធាខ្មែរក្រហម។ ចំណែកបងប្រុសរបស់ខ្ញុំ២នាក់ទៀត ត្រូវបានជ្រើសរើសឲ្យចូលធ្វើជាពេទ្យ។ បន្ទាប់ពីខ្ញុំចូលធ្វើយោធាខ្មែរក្រហម ខ្ញុំត្រូវបានបញ្ជូនឲ្យទៅឈរជើងនៅខេត្តរតនគិរី។ ខ្ញុំនៅទីនោះរហូតដល់ឆ្នាំ១៩៧៧ កងទ័ពវៀតណាមចាប់ផ្តើមមានជម្លោះជាមួយ ខ្មែរក្រហម។ ចាប់តាំងពីពេលនោះមកយោធាខ្មែរក្រហម និងកងទ័ពវៀតណាមវាយប្រហារគ្នាជាប់រហូតដល់ឆ្នាំ១៩៧៩។ បន្ទាប់មក ខ្ញុំភៀសខ្លួនទៅកាន់ទន្លេរពៅ ស្ថិតនៅជាប់ព្រំដែនឡាវ។ ខ្ញុំរស់នៅទន្លេរពៅបានរយៈពេលមួយខែ ធ្វើដំណើរទៅភ្នំ១០០៣វិញ។ នៅទីនោះ តាម៉ុក គឺជាអ្នកគ្រប់គ្រង និងផ្គត់ផ្គង់ការហូបចុកដល់ប្រជាជនរួមទាំងយោធាខ្មែរក្រហមទាំងអស់។ បន្ទាប់មកតាម៉ុក ហៅខ្ញុំរួមទាំងកងយោធាដទៃទៀតទៅរៀនសូត្រពីតស៊ូជាមួយសត្រូវ។ រហូតដល់ឆ្នាំ១៩៨៧ តាម៉ុក បានឲ្យខ្ញុំរៀបការជាមួយកូនស្រីរបស់គាត់។ ក្រោយពីរៀបការហើយ ខ្ញុំបន្តរស់នៅជាមួយប្រពន្ធខ្ញុំរហូតដល់ឆ្នាំ១៩៨៩។ ជើងរបស់ខ្ញុំពិការដោយសារជាន់មីន។ ចាប់តាំងពីនោះមក ខ្ញុំឈរជើងនៅសមរភូមិក្រោយដោយមានតួនាទីមើលការខុសត្រូវឃ្លាំងសម្ភាររហូត។

ខ្ញុំរួមទាំងប្រពន្ធបន្តរស់នៅលើភ្នំដងរែករហូតដល់ឆ្នាំ១៩៩០ ទើបចុះមកនៅក្នុងស្រុកអន្លង់វែងវិញ ហើយ តាម៉ុក បានចាត់តាំងខ្ញុំឲ្យកាន់ឃ្លាំងអង្ករដដែលៗ។ នៅឆ្នាំ១៩៩៣ ខ្ញុំបានរត់ឡើងភ្នំម្តងទៀត។ ខ្ញុំរស់នៅលើភ្នំដងរែកដល់ឆ្នាំ១៩៩៨ កងកម្លាំងខ្មែរក្រហមដែលឈរជើងនៅទឹកដីអន្លង់វែងបានផ្សះផ្សាគ្នាជាមួយរាជរដ្ឋាភិបាលដើម្បីបញ្ចប់សង្គ្រាម។ បន្ទាប់មក ខ្ញុំរួមទាំងក្រុមគ្រួសារបានសម្រេចចិត្តមករស់ក្នុងភូមិទឹកជុំរហូតមកដល់បច្ចុប្បន្ន។




**ហោម សាន**

ហោម សាន ភេទស្រី អាយុ៦០ឆ្នាំ មានទីកន្លែងកំណើតនៅឃុំកណ្តាល ស្រុកឈូក ខេត្តកំពត។ សព្វថ្ងៃរស់នៅភូមិស្វាយចេក ឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សានចែករំលែករឿងរ៉ាវជីវិតដូចខាងក្រោម៖

កាលពីកុមារ ខ្ញុំបានរៀនត្រឹមថ្នាក់ទី៧។ បន្ទាប់មកខ្ញុំត្រូវបានជ្រើសរើសឲ្យចូលធ្វើជាជាងកាត់ដេរខោអាវផ្គត់ផ្គង់ដល់សហករណ៍។ ការងារជាអ្នកកាត់ដេរនៅជំនាន់នោះ គឺពេលព្រឹកចាប់ពីម៉ោង៧ ដល់ម៉ោង១១ និងពេលរសៀលពីម៉ោង១ ដល់ម៉ោង៥។ ការហូបចុកខ្ញុំទទួលបានបាយហូបគ្រប់គ្រាន់។ លុះដល់ឆ្នាំ១៩៧៣ អង្គការជ្រើសរើសខ្ញុំឲ្យចូលធ្វើជាពេទ្យ។ អង្គការជ្រើសរើស និងសួរខ្ញុំថា តើខ្ញុំចេះមើលអក្សរបារាំងដែរឬទេ ដើម្បីងាយស្រួលក្នុងការមើលឈ្មោះថ្នាំ។ ចំណែកការវះកាត់អ្នកជំងឺ គឺខ្ញុំរៀនជាមួយតា ជួន ជឿន ដោយផ្ទាល់។

ខ្ញុំបានដើរព្យាបាលអ្នកជំងឺជាមួយកងទ័ពដោយមិនដែលមានឧបសគ្គអ្វីឡើយ។ ខ្ញុំបានដើរតាមព្យាបាលកងទ័ពរហូតដល់ឆ្នាំ១៩៧៥ទើបខ្ញុំចូលមកទីក្រុងភ្នំពេញ។ ចំពោះសម្លៀកបំពាក់ក្នុងមួយឆ្នាំខ្មែរក្រហមបើកឲ្យចំនួន២សម្រាប់។ ចំពោះការហូបចុកខ្ញុំទទួលបានគ្រប់គ្រាន់ ដោយសារតែក្រុមខ្ញុំជាក្រុមគ្រូពេទ្យជំនាញ។ ខ្ញុំបន្តធ្វើជាពេទ្យនៅប្រចាំការនៅភ្នំពេញរហូតដល់កងទ័ពវៀតណាមវាយចូលមកដល់នៅឆ្នាំ១៩៧៩។ ប្រជាជនបានបំបែកគ្នាទៅស្វែងរកបងប្អូននិងស្រុកកំណើតរៀងៗខ្លួនវិញ។ ចំណែកឯក្រុមគ្រូពេទ្យខ្ញុំបានភៀសខ្លួនទៅនៅខាងភូមិភាគឧត្តរ និងព្យាបាលអ្នកជំងឺនៅទីនោះរហូតដល់មានការផ្សះផ្សាជាតិ។



**ស៊ិន ណុល**

ស៊ិន ណុល ភេទប្រុស អាយុ៥៦ឆ្នាំ មានស្រុកកំណើតនៅក្នុងឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ សព្វថ្ងៃរស់នៅក្នុងភូមិទឹកជុំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

កាលពីកុមារភាពខ្ញុំរស់នៅជាមួយគ្រួសារនៅស្រុកកំណើត។ ខ្ញុំរៀនបានបន្តិចបន្តួចប៉ុណ្ណោះកាលពីសង្គម។ នៅចន្លោះឆ្នាំ១៩៧៤ និងឆ្នាំ១៩៧៥ ខ្ញុំបានចូលជាកងកុមារ។ ការងារដែលខ្ញុំធ្វើគឺឃ្វាលគោ ឃ្វាលសេះ ច្រូតស្មៅឲ្យគោស៊ី ដឹកដីដំបូក កាប់ទន្រ្ទានខែត្រយកទៅធ្វើជី។ កាលណោះ ខ្ញុំទើបតែមានអាយុ៩ឆ្នាំប៉ុណ្ណោះ។ ខ្ញុំរួមទាំងកុមារដទៃទៀតបានបែកពីឪពុកម្ដាយទៅដេកនៅរោងកុមារដែលមានចម្ងាយប្រមាណជា១០គីឡូពីភូមិ។ កាលណោះមួយកងខ្ញុំមានកុមារចំនួន៥០នាក់រួមទាំងកុមារា និងកុមារី។ ចំពោះការហូបចុក ថ្ងៃខ្លះខ្ញុំហូបបបរ ថ្ងៃខ្លះហូបដំឡូង និងថ្ងៃខ្លះទៀតហូបបាយ។ ក្នុងមួយថ្ងៃ កុមារអាចទៅរៀនបានមួយម៉ោង។ កុមារត្រូវសរសេរ និងចាំអក្សរឲ្យបាន៥តួ។ នៅពេលដែលកុមារនឹកឪពុកម្ដាយ អាចសុំច្បាប់ប្រធានកងមួយឬពីរថ្ងៃទៅលេងឪពុកម្ដាយបាន។ ខ្ញុំនៅក្នុងកងកុមាររហូតដល់ឆ្នាំ១៩៧៩ កងទ័ពវៀតណាមបានវាយចូលមក ទើបខ្មែរក្រហមរំសាយកងកុមាររបស់ខ្ញុំឲ្យមករកជួបជុំគ្រួសារវិញ។ ខ្ញុំនិងម្ដាយបានបន្តរត់គេចគ្រាប់ពីផ្លោង។ នៅពេលនោះប្រជាជនជាច្រើននាក់បានស្លាប់បាត់បង់ជីវិតនៅតាមផ្លូវដោយសារអត់អាហារ។

នៅឆ្នាំ១៩៨៣ ខ្ញុំបានរៀបការ។ នៅក្នុងឆ្នាំដដែលខ្ញុំបានពិការជើងម្ខាង។ បន្ទាប់មក តាម៉ុក ឲ្យខ្ញុំមកនៅភូមិស្រះឈូក។ តាម៉ុក បានឲ្យខ្ញុំនៅបើកត្រាក់ទ័រដឹកអង្ករយកទៅឲ្យកងទ័ពនៅសមរភូមិមុខ។ ក្រោយពីបើកត្រាក់ទ័រ ខ្ញុំត្រូវទៅថ្នេមីននៅភូមិទឹកជុំ។ កាលណោះមានមនុស្ស៧នាក់បានស្លាប់ដោយសារផ្ទុះមីនពេលកំពុងថ្នេ។ ចាប់តាំងពីពេលនោះមកប្រពន្ធរបស់ខ្ញុំក៏ឈប់ឲ្យខ្ញុំទៅកែថ្នេមីនទៀត។



**បាវ ណាង**

បាវ ណាង ភេទស្រី អាយុ៦១ឆ្នាំ មានស្រុកកំណើតនៅក្នុងភូមិព្រៃខ្លា ស្រុកកោះអណ្ដែត ខេត្តតាកែវ។ សព្វថ្ងៃរស់នៅក្នុងភូមិទួលសាលា ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

កាលពីសម័យសម្ដេចព្រះ នរោត្តម សីហនុ ខ្ញុំនៅតូចៗណាស់។ គ្រួសាររបស់ខ្ញុំប្រកបមុខរបរធ្វើស្រែចម្ការ។ នៅឆ្នាំ១៩៧៣ បងប្រុសរបស់ខ្ញុំ៤នាក់បានចូលធ្វើបដិវត្តន៍ជាមួយខ្មែរក្រហម។ ចំណែកខ្ញុំ និងប្អូនៗរួមទាំងម្ដាយរស់នៅក្នុងសហករណ៍នៅក្នុងភូមិព្រៃខ្លាដដែល។ នៅពេលដែលម្ដាយឪពុកខ្ញុំចេញទៅធ្វើការលើកភ្លឺស្រែ ស្ទូងស្រូវ ខ្ញុំជាអ្នកនៅមើលថែប្អូនៗ។ នៅពេលម៉ោងឈប់សម្រាក ទើបម្ដាយរបស់ខ្ញុំយកអាហារមកឲ្យខ្ញុំនិងប្អូនៗហូប។ បន្ទាប់ពីយកអាហារឲ្យខ្ញុំនិងប្អូនហើយម្ដាយខ្ញុំត្រឡប់ទៅធ្វើការរហូតដល់ល្ងាច ទើបបានមកជួបជុំគ្នាវិញ។ នៅក្នុងសម័យខ្មែរក្រហមអ្វីដែលខ្ញុំចាំមិនភ្លេចនោះគឺបងប្រុសខ្ញុំត្រូវបានបែកបាក់ពីគ្រួសារ ចំណែកការហូបចុកមិនបានគ្រប់គ្រាន់ទេ។ មុនពេលខ្ញុំមកដល់ស្រុកអន្លង់វែង ខ្ញុំធ្លាប់ដឹងថាអន្លង់វែងជាតំបន់សង្រ្គាម តំបន់គ្រាប់ផ្លោង និងមានអតីតខ្មែរក្រហមរស់នៅច្រើន។

ខ្ញុំសម្រេចចិត្តមករស់នៅក្នុងស្រុកអន្លង់វែង ដោយខ្ញុំមានបងប្រុសខ្ញុំរស់នៅទីនេះ។ ម្យ៉ាងទៀតខ្ញុំមិនមានដីធ្លីសម្រាប់ធ្វើស្រែចម្ការ និងដាំដំណាំនៅស្រុកកំណើត។ ខ្ញុំរួមទាំងគ្រួសាររស់នៅក្នុងភូមិទួលសាលានេះរហូតដល់សព្វថ្ងៃនេះ។ ប្រជាជននៅទីនេះស្រឡាញ់រាប់អានគ្នាដូចបងប្អូន និងមិនមានការរើសអើងអ្នកចំណូលថ្មីដូចជារូបខ្ញុំទេ។ ខ្ញុំមិនចង់ឲ្យរបបខ្មែរក្រហមកើតឡើងម្តងទៀតទេ ព្រោះនៅសម័យខ្មែរក្រហមលំបាកខ្លាំងណាស់។ សព្វថ្ងៃនេះការរស់នៅ គឺធូរធាជាងមុន ថែមទាំងមានសេរីភាពក្នុងការរស់នៅក្នុងសង្គម។



**សៀង ថេន**

សៀង ថេន ភេទស្រី អាយុ៥៦ឆ្នាំ មានស្រុកកំណើតនៅភូមិពាក់បង្អោង ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ សព្វថ្ងៃរស់នៅក្នុងភូមិថ្នល់ថ្មី ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

កាលពីកុមារភាពខ្ញុំរស់នៅជាមួយឪពុកម្តាយ។ រហូតដល់ឆ្នាំ១៩៧១ ខ្មែរក្រហមស្នើសុំឪពុកម្តាយរបស់ខ្ញុំយកខ្ញុំទៅចូលក្នុងកងកុមារ។ ការងារដែលខ្ញុំត្រូវធ្វើក្នុងកងកុមារ រួមមាន កាប់ទន្ទ្រានខែត្រ វែកដីដំបូក រើសអាចម៍គោ ធ្វើជាជីដាក់ស្រែ។ ខ្ញុំវែកដីដែលធ្វើហើយយកទៅដាក់ក្នុងស្រែ។ ក្នុងមួយក្រុមកុមារមានកុមារចំនួន១២នាក់។ កាលណោះសម្បុរណាស់ក្មេងៗដែលរត់ទៅរកឪពុកម្តាយដោយក្តីនឹករឭក។ កុមារខ្លះលួចទៅផ្ទះ ប៉ុន្តែពេលប្រធានកងកុមារចាប់បានគឺដាក់វិន័យឲ្យកុមារដែលលួចទៅជួបឪពុកម្តាយឲ្យវែកដី។ ក្នុងមួយខែ ខ្ញុំសុំប្រធានកងទៅលេងឪពុកម្តាយបាន២ដង។ ជារៀងរាល់ថ្ងៃកុមារអាចទៅរៀនបានមួយម៉ោងជាមួយគ្រូបង្រៀននៅក្នុងសហករណ៍។ គ្រូដែលបង្រៀនខ្ញុំជំនាន់នោះឈ្មោះយ៉ាន ហើយគាត់គឺជាប្រធានកងកុមារដែរ។ ខ្ញុំនៅក្នុងកងកុមារ ហូបតែបបរ ចំណែកឯបាយវិញយូរៗទើបខ្ញុំបានហូបម្តង។ បន្ទាប់មកទៀតកុមារដែលមានមាឌធំៗត្រូវដកឲ្យទៅមើលក្មេងៗវិញ។ កាលនោះខ្ញុំមាឌធំ ទើបប្រធានកងកុមារឲ្យខ្ញុំទៅមើលក្មេងៗ តូចៗ ចំនួន៣នាក់។ ខ្ញុំត្រូវបញ្ចុកបាយ បបរ រៀបចំឲ្យក្មេងៗដេករហូតដល់ម្តាយក្មេងៗទាំងនោះមកពីច្រូតស្រូវវិញ ទើបខ្ញុំបានសម្រាក។ ការងារនោះគឺលំបាកណាស់ ព្រោះខ្ញុំមិនហ៊ានដើរទៅណាទេ ទោះបីខ្ញុំចង់ទៅដកដំឡូងមកហូប។ ខ្ញុំនៅមើលក្មេងៗ អស់រយៈពេល ២ខែ កងទ័ពវៀតណាមបានវាយចូលមកដល់។ នៅពេលនោះម្តាយរបស់ក្មេងៗបានមកយកកូនៗពីខ្ញុំហើយរត់ចេញទៅ និងប្រាប់ខ្ញុំឲ្យរត់ទៅរកឪពុកម្តាយខ្ញុំវិញ។ ក្រោយពីជួបម្តាយហើយ ម្តាយខ្ញុំរបស់ខ្ញុំនាំខ្ញុំរត់តាមប្រជាជនដទៃទៀតដែលមានយោធាខ្មែរក្រហម អមដំណើរ។ កាលណោះ យោធាខ្មែរក្រហមមិនឲ្យយើងបកក្រោយឡើយ។ ប្រសិនបើមានអ្នកជំទាស់គឺយោធាខ្មែរក្រហមបាញ់សម្លាប់ចោលភ្លាមៗ។ យោធាខ្មែរក្រហមបានប្រាប់គ្រួសារខ្ញុំរួមទាំងប្រជាជនទាំងអស់ធ្វើដំណើរតាមផ្លូវជាតិលេខ១២ និងលេខ១៣ ឆ្ពោះទៅទិសខាងលិចរហូតទៅដល់ភ្នំលះបង់។ ភ្នំលះបង់គឺជាភ្នំមួយដែលមានប្រជាជនស្លាប់ជាច្រើននាក់ ពីព្រោះគ្រួសារដែលមានឪពុកម្តាយចាស់ជរា អ្នកកូនតូចដែលឡើងភ្នំមិនរួច គឺត្រូវទុកចោល។ ខ្ញុំនិងគ្រួសារមិនទាន់បានឡើងភ្នំទេ ស្រាប់តែមានអ៊ំម្នាក់មកប្រាប់គ្រួសារឲ្យគេចទៅទិសខាងកើតវិញ ប្រសិនបើទៅមុខទៀតប្រាកដជាស្លាប់។ ក្រោយមកទៀត មានកងយោធាខ្មែរក្រហមដែលផ្តាច់ខ្លួនចូលជាមួយកងទ័ពវៀតណាម បានប្រាប់ឲ្យយើងត្រឡប់ទៅស្រុកភូមិវិញ ព្រោះប្រទេសបានរំដោះ និងគ្មានភ័យខ្លាចទៀត។ ខ្ញុំរួមទាំងគ្រួសារក៏ធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញ។ ពេលទៅដល់ភូមិខ្ញុំឃើញសុទ្ធតែកងទ័ពវៀតណាម ប៉ុន្តែកងទ័ពវៀតណាមមិនធ្វើបាបយើងទេ ថែមទាំងប្រាប់ឲ្យយើងរស់នៅផ្ទះសម្បែង។



ខៀវ ថន

ខៀវ ថន ភេទប្រុស អាយុ៦០ឆ្នាំ មានស្រុកកំណើតនៅភូមិសំរោង ឃុំមនោរម្យ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ សព្វថ្ងៃរស់នៅក្នុងភូមិទួលគ្រួស ឃុំថ្លាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

នៅក្នុងជំនាន់ខ្មែរក្រហម ខ្ញុំបានចូលរួមធ្វើជាកងកុមារ។ ខ្ញុំរែកដី កាប់ទន្រ្ទានខែត្រធ្វើជី និងកាប់ដីដំបូក។ ខ្ញុំធ្វើការនៅក្នុងកងកុមារបានមួយរយៈ។ បន្ទាប់មកខ្ញុំក៏ចូលធ្វើជាកងទ័ពខ្មែរក្រហមនៅ ខាងភូមិភាគបស្ចិម។ ខ្ញុំនៅក្នុងកងពល១១៧ ដែលគ្រប់គ្រងដោយ តារុំ តានឹម តានាង។ មុខសញ្ញាដែលខ្ញុំឡើងទៅវាយគឺ ខេត្តកំពង់ឆ្នាំង។ មួយរយៈក្រោយមក ខ្ញុំត្រូវបានបញ្ជូនឲ្យទៅ ឈរជើងនៅតាមព្រំដែន ដោយសារនៅឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ មានជម្លោះនៅតាមព្រំដែនវៀតណាម។ ចាប់តាំងពីខ្ញុំទៅ ឈរជើងនៅតាមព្រំដែន ខ្ញុំបានដាច់ទំនាក់ទំនងពីឪពុកម្តាយបងប្អូន។ ក្រោយមក យោធាខ្មែរក្រហមចាប់ផ្តើមវាយជាមួយកងទ័ពវៀតណាម។ រហូតដល់ចុងឆ្នាំ១៩៧៨ ការវាយប្រយុទ្ធកាន់តែខ្លាំងក្លា ហើយដោយសារយោធាខ្មែរក្រហម មានចំនួនតិចជាងកងទ័ពវៀតណាម ទើបបណ្តាលឲ្យយោធាខ្មែរក្រហមត្រូវស្លាប់អស់ជាច្រើននាក់។ យោធាខ្មែរក្រហមវាយ ទប់កងទ័ពវៀតណាមនៅព្រំដែន ប៉ុន្តែនៅខេត្តក្រចេះយោធាខ្មែរក្រហមមិនអាចវាយ ទប់ទល់ និងរុញច្រានកងទ័ពវៀតណាមទៅក្រោយវិញបានទេព្រោះកងទ័ពវៀតណាមមានចំនួនច្រើន។

នៅឆ្នាំ១៩៧៩ ខ្ញុំបានរត់ទៅនៅក្នុងព្រៃ ក្នុងខេត្តរតនគិរី។ កងទ័ពខ្មែរក្រហមចាប់ផ្តើមបាក់បែកគ្នា និងខ្វះខាតស្បៀងអាហារហូបចុក។ ដើម្បីបានរស់បន្ត ខ្ញុំរួមទាំងប្រជាជន កងទ័ពដែលនៅសេសសល់បាននាំគ្នាជីកដំឡូង មើមក្តួច យកមកធ្វើអាហារហូបនៅក្នុងព្រៃខេត្តរតនគិរីដើម្បីរងចាំដំណឹងពីខាងខ្មែរក្រហម។ កម្លាំងដែលនៅក្នុងព្រៃមានទាំងប្រជាជន និងកងទ័ពចំនួន ៦០០នាក់។ មកដល់ឆ្នាំ១៩៨០ ខ្ញុំបានធ្វើដំណើរឆ្ពោះទៅកាន់មុំបី ឬហៅថាទន្លេរល្ពៅ។ ការធ្វើដំណើរតាមផ្លូវខ្ញុំជួបការលំបាកច្រើនណាស់ រហូតដល់មានកងកម្លាំងខ្មែរក្រហម ចុះមកទទួលខ្ញុំ។ ពេលទៅដល់ទីនោះហើយខ្មែរក្រហមបានយកអាហារហូបចុកមកបំប៉នប្រជាជន និងកងទ័ពដែលទើបទៅដល់។ កងទ័ពមានអាវុធច្រើនជាងមុនក្នុងការវាយតទល់ជាមួយវៀតណាម ព្រោះអាវុធទំនើបនិងសម្បូរបែបដូចជា៤០,៤៧,៦៧ និងគ្រាប់បែក រួមទាំងមានកងនារីដឹកជញ្ជូន។ កងទ័ពខ្មែរក្រហមចាប់ផ្តើមវាយ ទប់ទល់ជាមួយកងទ័ពវៀតណាមរហូតដល់ឆ្នាំ១៩៨៥។ បន្ទាប់ពីវៀតណាមវាយចូលខ្លាំង ខ្ញុំរួមទាំងកងទ័ពបានរត់មកនៅភ្នំ ១០០៣វិញ ដោយមានតាម៉ុក គឺជាអ្នកគ្រប់គ្រង។ ខ្ញុំបន្តនៅ១០០៣ រហូតដល់ឆ្នាំ១៩៩៣ មានការចុះកិច្ចព្រមព្រៀងទីក្រុងប៉ារីសបញ្ចប់សង្រ្គាម។ បន្ទាប់មកបងប្អូនប្រជាជនដែលរស់នៅលើភ្នំដងរែកបានចុះមកធ្វើស្រែចម្ការនៅក្នុងស្រុកអន្លង់វែង ដោយតាម៉ុក គឺជាអ្នកចែកដីធ្លីសម្រាប់ធ្វើផ្ទះសម្បែងរស់នៅ។



ឡុង ចាន់ថន

ឡុង ចាន់ថន ភេទប្រុស អាយុ៥៥ឆ្នាំ មានទីកន្លែងកំណើតនៅភូមិជ្រៃ ឃុំទឹកវិល ស្រុកពួក ខេត្តសៀមរាប។ ចាន់ថន សព្វថ្ងៃរស់នៅភូមិថ្នល់ថ្មី ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ចាន់

ផងបានចែករំលែករឿងរ៉ាវរបស់គាត់ដូចខាងក្រោម៖

កាលពីជំនាន់ខ្មែរក្រហម ខ្ញុំមានអាយុប្រហែលជា១០ឆ្នាំ។ ខ្ញុំត្រូវបានខ្មែរក្រហមជ្រើសរើសឲ្យចូលធ្វើជាកងកុមារនៅក្នុងភូមិអណ្តូងតាអោន ឃុំគោកធ្លកលើ ស្រុកជីក្រែង ខេត្តសៀមរាប។ ចំណែកឪពុកខ្ញុំ និងបងប្អូនខ្ញុំផ្សេងទៀតត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើការនៅកងចល័ត។ ការងារខ្ញុំនៅពេលនោះ ខ្មែរក្រហមបានប្រើឲ្យខ្ញុំឃ្វាលគោនៅខែវស្សា ហើយកាប់ដីដឹបូកធ្វើជី និងរើសគួរស្រូវនៅខែប្រាំង។ ចំណែកការហូបចុកនៅជំនាន់នោះគឺខ្ញុំហូបចុកបានគ្រប់គ្រាន់ ដោយសារតែមេភូមិអណ្តូងតាអោនយកចិត្តទុកដាក់ចំពោះការហូបចុករបស់ប្រជាជន។ កាលនោះខ្ញុំពុំចាំថាគាត់ឈ្មោះអ្វីនោះទេ ប៉ុន្តែដោយសារតែចិត្តល្អសន្តោសប្រណីរបស់គាត់នៅពេលនោះ គាត់ក៏ត្រូវបានខ្មែរក្រហមចោទថាក្បត់។ នៅក្នុងជំនាន់នោះអ្វីដែលធ្វើឲ្យខ្ញុំចងចាំមិនភ្លេច គឺខ្ញុំបានប្រទះឃើញសាកសពជាច្រើនដេកស្លាប់ ហើមស្អុយពេញមាត់ទឹកបារាយណ៍ ខេត្តសៀមរាប។ សាកសពទាំងនោះសុទ្ធតែប្រជាជនដែលត្រូវបានខ្មែរក្រហមកុហកថា ឲ្យទទួលសម្តេចព្រះនរោត្តម សីហនុ ប៉ុន្តែការពិត គឺយកមកសម្លាប់ចោលទាំងអស់។ នៅដើមឆ្នាំ១៩៧៩ កងវៀតណាមចូលមកប្រទេសកម្ពុជា ខ្ញុំបានរត់ភៀសខ្លួនមកនៅផ្ទះវិញ។ ពេលនោះក្នុងភូមិខ្ញុំចាប់កើតមានការចលាចលដោយសារខ្មែរក្រហមយកភូមិអណ្តូងតាអោន ជាទីតាំងវាយព្រលានយន្តហោះ។ ដូច្នេះប្រជាជនមិនហ៊ានរស់នៅទេ។ ប្រជាជនរត់ចេញពីផ្ទះសម្បែងទៅដេកនៅតាមផ្លូវជាតិលេខ៦។ អស់រយៈពេលមួយសប្តាហ៍ក្រោយពេលដែលភាពការណ៍ស្ងប់ស្ងាត់ ទើបយើងហ៊ានចូលទៅក្នុងភូមិវិញ។

នៅឆ្នាំ១៩៨៤ ខ្ញុំមានអាយុ១៦ឆ្នាំខ្ញុំក៏ចូលធ្វើជាកងទ័ពសាធារណរដ្ឋកម្ពុជា។ ក្រោយមកខ្ញុំក៏ត្រូវបានបញ្ជូនឲ្យមកកាន់អន្លង់វែង នៅឆ្នាំ១៩៨៨។ ខ្ញុំនៅឈរជើងការពារនៅព្រំដែនខ្មែរ-ថៃបាន៥ខែ ខ្ញុំក៏លួចរត់មកផ្ទះនៅចុងឆ្នាំ១៩៨៨។ ប៉ុន្តែខណៈពេលដែលរត់មកនោះ ខ្ញុំក៏បានជួបនឹងខ្មែរក្រហមពាក់កណ្តាលផ្លូវ ខ្ញុំក៏លែងហ៊ានបន្តដំណើរទៅមុខទៀតដោយសារខ្លាចខ្មែរក្រហមសម្លាប់។ ខ្ញុំនៅតស៊ូជាមួយខ្មែរក្រហមដល់ថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៩៨ ខ្ញុំក៏ផ្តាច់ខ្លួនរួមរស់ជាមួយនឹងរាជរដ្ឋាភិបាលវិញ។



ស្រី សុខ

ស្រី សុខ ភេទប្រុស អាយុ៧២ឆ្នាំ មានទីកន្លែងកំណើតនៅស្រុកកោះធំ ខេត្តកណ្តាល។ បច្ចុប្បន្នរស់នៅក្នុងភូមិទួលសាលា ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ សុខបានរៀបរាប់ថា៖

ខ្ញុំរស់នៅក្នុងសម័យសង្គមរាស្ត្រនិយម នៅពេលខ្ញុំមានអាយុប្រហែល១៨ឆ្នាំ។ ក្រោយមកក៏មានការបំផុសបំផុលឲ្យប្រជាជននៅក្នុងភូមិចូលរួមជាមួយចលនាខ្មែរក្រហម បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុចេញពីតំណែងព្រះប្រមុខរដ្ឋ។ ភ្លាមៗនោះ ខ្ញុំមិនទាន់បានចូលរួមក្នុងចលនាខ្មែរក្រហមទេ។ រយៈពេលប្រមាណ៥ខែក្រោយមក ទើបខ្ញុំបានសម្រេចចិត្តចូលរួមជាមួយខ្មែរក្រហម។ នៅមុនពេលនៃការចូលរួមជាមួយចលនានេះ ខ្ញុំបានកត់សម្គាល់មើលពីបាតុភូតនៃផ្កាយដុះកន្ទុយជាបន្តបន្ទាប់ធ្លាក់ពីលើមេឃ ដែលសន្និដ្ឋានថាប្រទេសជាតិរបស់យើងប្រាកដជាមានរឿងមិនល្អកើតឡើង។ ក្រោយមកទៀត ខ្ញុំឃើញរឿងរ៉ាវទាំងនោះបានកើតឡើងពិតប្រាកដមែនដោយឧទ្ធម្ភាគចក្រប្រមាណ១០០គ្រឿង បានហោះចូលមកក្នុងប្រទេសកម្ពុជា។ ពេលមួយ ខ្ញុំបានទៅនេសាទត្រីនៅក្នុងព្រៃកដូចសព្វមួយដង ប៉ុន្តែសំណាងអាក្រក់ កងទ័ព លន់ នល់ ចាប់ខ្លួន និងដកហូតលុយកាក់អស់។ ក្រោយមកទៀត

យើងត្រូវបានបញ្ជូនឲ្យធ្វើដំណើរថ្មើរជើងតាមបណ្តោយមាត់ព្រែកទៅកាន់តំបន់ដីក្រហមនៅទួលបាក់ភ្លើងៗ មិនយូរប៉ុន្មាន យើងត្រូវបានបញ្ជូនឲ្យត្រឡប់មកផ្ទះវិញ។ ប្រជាជនក្នុងស្រុករបស់ខ្ញុំចាប់ផ្តើមបង្កើតជាកងជីវពលតស៊ូ។ យើងរត់ទៅលាក់ខ្លួននៅក្នុងព្រៃ ដើម្បីគេចចេញពីការទម្លាក់គ្រាប់បែករបស់កងទ័ពលន់នល់។ ខ្ញុំឃើញកងទ័ពលន់នល់បានធ្វើបាបប្រជាជនខ្លាំងពេក ខ្ញុំក៏បានចាកចេញពីផ្ទះ ទៅចូលតស៊ូជាមួយចលនាខ្មែរក្រហម។ កាលណោះ មានមេខ្មែរក្រហមម្នាក់ឈ្មោះ គួក ដែលមានដំណើរប៉ាក់ពាចៗ និងមានចរិតម៉ឺងម៉ាត់។ នៅពេលប្រយុទ្ធគ្នា កងកម្លាំងរបស់យើងទទួលរងរបួសជាច្រើននាក់ ដែលបង្ខំចិត្តឲ្យយើងដកកងទ័ព។ ខណៈពេលនោះ ខ្ញុំបានត្រូវរបួសបំគ្រង់ឆ្អឹងជំនី។ អង្គភាពបានបញ្ជូនខ្ញុំទៅព្យាបាលនៅពេទ្យកំពង់គរ។ ក្រោយជាសះស្បើយ ខ្មែរក្រហមបានដាក់ឲ្យខ្ញុំរស់នៅក្នុងមន្ទីរពិការ។ ខ្ញុំបានដឹកនាំកុមារធ្វើការដាំដើមចេក ដើម្បីផ្គត់ផ្គង់កងកម្លាំងនៅសមរភូមិមុខ។ ក្រោយមកនៅពេលមានការគ្រប់គ្រង និងវិសុទ្ធកម្មពីកម្មាភិបាលភូមិភាគនិរតី មេអង្គភាពរបស់ខ្ញុំក៏ត្រូវបានចាប់ខ្លួនដែរ។



ក្រុមការងារមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងជួបសម្ភាសន៍ ព្រំ វ៉ាន់ រស់នៅក្នុងភូមិ អូរតាម៉ែង ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ តាមរយៈគម្រោងប្រវត្តិសាស្ត្រគ្រួសារ ខែឧសភា ឆ្នាំ ២០២១។
(សួត វិចិត្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# «ទួលពិឃាដ»

## មីត្នោត មេគោអង្គការ

### សភាវគតិមីត្នោតនាំឱ្យខ្ញុំឃើញរណ្តៅមរណៈគ្រួសារ

ជំនោរពេលព្រឹកនាខែកត្តិកបក់បោកមករអើកពីទិសខាងជើងត្រជាក់ស្រិបៗ ក្លិនប្រហើរពិដោរនៃម្អម និងលម្អងស្រូវកំពុងធ្វើខ្លួនសាយភាយមកម្តងៗធ្វើឲ្យអារម្មណ៍ជ្រះថ្លាធូរស្បើយ ក្នុងទ្រូង ដែលធ្លាប់ដក់នូវទុក្ខកង្វល់កប់ ងំមិនអាចបំភ្លេចបានៗ តែទោះជាយ៉ាងណាក៏មិនអាចលុបលាងនូវស្លាកស្នាមឈឺចាប់ និងស្រមោលអនុស្សាវរីយ៍ខ្លោចផ្សាដែលធ្លាប់កើតមានកន្លងមកបានឡើយៗ

ខ្ញុំជិះម៉ូតូពីក្រោយមានអ្នកឌុបកាត់ផ្លូវលំ កាត់ភ្លឺស្រែសំដៅទៅភូមិកំណើតរបស់ខ្ញុំម្តាយ និងជីដូនជីតានៅឯភូមិក្រាំងយុំព្រៃស្រឡិត ស្រុកពារាំង ខេត្តព្រៃវែងៗ ជិះបណ្តើរភ្នែកខ្ញុំងាកមើលទេសភាពជុំវិញខ្លួនបណ្តើរអារម្មណ៍រវើរវាយ ស្រមើស្រមៃនឹកគិតវែងឆ្ងាយៗ

នៅពេលនោះស្រមោលអនុស្សាវរីយ៍ខ្លោចផ្សាបាននាំគ្នារត់ចេញមកប្រសេចប្រសាចហើយសាច់រឿងឈឺចាប់ខ្លោចផ្សាក៏ចាប់ផ្តើមបញ្ចាំងហ្វីលសាជាថ្មីម្តងមួយៗ នៅចំពោះភ្នែកខ្ញុំៗ ខ្ញុំអួលដើមក ខំបិទភ្នែកបំភ្លេចទុក្ខតែបំភ្លេចមិនបាន ព្រោះតែការឈឺចាប់វាមានទំហំធំធេងពេក ធ្វើឲ្យខ្ញុំប្រឹងពង្រឹងស្មារតី ហើយខំបើកភ្នែកតាមដានសាឡើងវិញ នូវសាច់រឿងចាស់ទាំងអស់ដែលខ្ញុំ និងគ្រួសារបានឆ្លងកាត់ក្នុងរបបអាវខ្មៅៗ

ម៉ូតូបាននាំខ្ញុំមកដល់ទីទួលមួយដែលខ្ញុំធ្លាប់បានស្គាល់យ៉ាងច្បាស់បំផុត កាលពី៣៩ឆ្នាំមុន (១៩៧៨-២០១៧ ដែលកាលនោះខ្ញុំមានអាយុប្រហែលដប់មួយឆ្នាំ)ៗ ទីនេះហើយគឺជាទួលមួយដែលស្ថិតនៅខាងជើងភូមិកំណើតរបស់ម្តាយ ជីដូនជីតា និងរូបខ្ញុំ គឺភូមិក្រាំង ហើយទួលនេះអ្នកភូមិគេហៅថា ទួលស្វាំងតែពេលនោះសម្រាប់ខ្ញុំហៅថា «ទួលស្លាប់» ស្ថិតក្នុងភូមិក្រាំង យុំព្រៃស្រឡិត ស្រុកពារាំង ខេត្តព្រៃវែងៗ

ម៉ូតូបានឈប់ ខ្ញុំស្រក់ទឹកភ្នែកប្រោកឈរសម្លឹងមើលទីទួលនោះ ព្រោះទីទួលនោះហើយដែលជាកន្លែងបានផ្ទុកនូវស្លាកស្នាមអនុស្សាវរីយ៍រាប់រយលានតំណក់ទឹកភ្នែកឈាមដ៏ជូរចត់ក្នុងឆាកជីវិតខ្ញុំក្នុងរបបខ្មៅងងឹត ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ដែលឪពុកម្តាយ ប្អូនប្រុសពៅភ្លោះ និងបងប្អូនអ្នក ១៧មេសា ដទៃទៀត ត្រូវបានក្រុមពេជ្ឈឃាដខោអាវខ្មៅខ្មែរក្រហម សម្លាប់គ្មានញញើតដៃ សូម្បីតែរូបខ្ញុំក៏សឹងតែអស់ជីវិតនៅពេលនោះដែរៗ

ខ្ញុំអង្គុយចុះគិត រួចងាកមើលជុំវិញខ្លួនៗ ខ្ញុំបិទភ្នែកបន្តិចរួចបើកមកវិញខំរកនឹកមើលពីគ្រប់ជ្រុងជ្រោយនៃរឿងរ៉ាវដែលបានកើតមានឡើងនៅទីនេះកាលពីជិត៤០ឆ្នាំមុនៗ ដោយសារអ្នកបើកម៉ូតូជាអ្នកភូមិស្គាល់គ្នាទើបខ្ញុំមានឱកាសច្រើនក្នុងការស្រមៃរើកកាយមកវិញនូវគ្រប់រូបភាពទាំងអស់ដែលធ្លាប់មានៗ

ខ្ញុំចាំបានថា ថ្ងៃមួយមិត្តនារីប្រធានក្រុមកុមារបានឲ្យខ្ញុំទៅឃ្វាលគោនៅវាលស្រែត្រពាំងលាក់ស្រូវខាងជើងទួលនោះៗ ទីទួលនោះមានរបងដើមបន្ទាអម្ពិល ទឹក និងដើមរំចាកពទ្ធ័ជុំវិញៗ ខ្ញុំមានមេគោមួយដែលអង្គការឲ្យខ្ញុំមើលថែទាំវាៗ ខ្ញុំស្រឡាញ់វាណាស់ហើយបានដាក់ឈ្មោះថា «មីត្នោត» ព្រោះវាមានសម្បុរពណ៌ត្នោតៗ ថ្ងៃនោះមិនដឹងថាមីត្នោតមានបំណងប្រុកឹ ដោយចៃដន្យទេ មីត្នោតបានរុលរបងចូលទៅក្នុងទួលនោះៗ ទីនោះ ជា

កន្លែងដែលអង្គការហាមឃាត់មិនឲ្យអ្នកណាចូលឡើយ។

ថ្ងៃបាក់រសៀលកុមារទាំងអស់ត្រូវកៀងគោបញ្ចូលក្រោល។ បាត់មីត្នោតពីវាល ខ្ញុំក៏សួរទៅកុមារចាំគោទាំងនោះថា "មិត្តកុមារអើយ មានឃើញមីត្នោតគោខ្ញុំទេ?" កុមារម្នាក់ក្នុងចំណោមបួនប្រាំនាក់ ដែលខ្ញុំភ្លេចឈ្មោះបានប្រាប់ខ្ញុំថា "មិត្តកុមារវង្ស" ខ្ញុំឃើញមីត្នោតរុលរបងចូលទៅក្នុងទួលស្វាំង។ ខ្ញុំង៉េមង៉ាមស្ទាក់ស្ទើរមិនហ៊ានចូលព្រោះទើបតែឃើញពួកកងឈ្លបខ្មែរក្រហមដេញបាញ់មនុស្សរត់ចេញពីទួលស្វាំងដោយកាំភ្លើងអាកា និងសឺវិនធីណាយ (M79) ប៉ុន្មានថ្ងៃមុនរត់តាមត្រពាំងលាក់ស្រូវដែលក្មេងៗ ចាំគោទាំងនោះបានស្គាល់ច្បាស់ថាគឺជាមេភូមិអ៊ុី។ ពេលនោះខ្ញុំគិតថាត្រូវធ្វើដូចម្តេចទៅ! បើបាត់មេគោ គេប្រាកដជាដាក់ទណ្ឌកម្មខ្ញុំជាមិនខាន។ កន្ទង់មកមេកង់តែងតែហៅខ្ញុំធ្វើស្វ័យទិតៀនមិនដែលខានពីកំហុសក្នុងការងារ។ ភ្លាមនោះ ខ្ញុំក៏រុលតាមប្រលោះតូចមួយចូលទៅក្នុងទួលឱនងើបៗ ភ្នែកសម្លឹងរេរកមីត្នោតក្នុងអារម្មណ៍ភ័យខ្លាច។

ខណៈនោះខ្ញុំឮសំឡេងកាប់ដីគឹបៗ និងមនុស្សនិយាយគ្នា។ ខ្ញុំក្រឡេកសម្លឹងទៅរកសំឡេងនោះ ស្រាប់តែឃើញមនុស្សប្រុសបីបួននាក់អាយុបងខ្ញុំបីបួនឆ្នាំ ពាក់ខោអាវខ្មៅ ជួតក្បាលក្រមាកំពុងជីករណ្តៅទំហំប្រហែលបួនម៉ែត្របួនជ្រុងជម្រៅប្រមាណមួយម៉ែត្រ និងបញ្ឈរកាំភ្លើងបង់ត្រឡោកកញ្ចាស់មួយដើមនៅមាត់រណ្តៅបែរទៅទិសខាងជើង។

ខ្ញុំរកកន្លែងបាំងខ្លួនខំតាមមើលសកម្មភាពពួកគេបន្តទៀត ទាំងខ្លួនភ័យញ័រ។ រំពេចនោះក៏ឃើញមនុស្សប្រុសមាឌធំម្នាក់ស្លៀកពាក់ខោអាវខ្មៅ ពាក់មួកកាតិបបង់កក្រមា ក្រវាត់កាំភ្លើងខ្លី និងខ្សែសេនណារ៉ុងនៅនឹងចង្កេះប្រហែលជា មេគេ ស្រែកសួរទៅមនុស្សកំពុងជីករណ្តៅនោះថា "មើល៍សមមិត្ត តើរណ្តៅនេះដាក់បានគោប៉ុន្មានក្បាល?" ពេលនោះមនុស្សទាំងនោះបានឆ្លើយតបព្រមៗគ្នាថា "បាទ សមមិត្តបានប្រហែលជាងម្ភៃក្បាលដែរ។"

ខ្ញុំព្រឺក្បាលខ្លាកពេលឮពាក្យសម្តីនេះភ្លាម ខ្ញុំគិតថា មិនមែនដាក់គោទេ ប្រាកដជាគេសម្លាប់មនុស្សដាក់ក្នុងរណ្តៅនេះរួមទាំងគ្រួសារខ្ញុំផង ព្រោះខ្ញុំបានឮឪពុកម្តាយខ្ញុំ ប្រាប់ថា "គ្រួសារយើង ត្រូវប្រធានកងចាត់តាំងឲ្យទៅរស់នៅលើទួលស្វាំងនេះ។" រួចគេក៏ដើរទៅវិញ ពួកគេចាប់ផ្តើមជីករណ្តៅបន្តទៅទៀត។

ពេលពួកគេត្រឡប់ទៅវិញ ឆ្លៀតឱកាសនោះស្រាប់តែខ្ញុំឃើញមីត្នោតនៅក្បែរខ្លួន ហើយក៏កៀងមីត្នោតមកក្រៅវិញយ៉ាងលឿនដោយភ័យឡើងដង្ហក់ត្រដរខ្យល់ខ្លួនញ័រចំប្រប់ដូចកូនចាបធ្លាក់ទឹក។

## ជីវិតមិនអស់

នេះជាសំណាងមួយក្នុងមួយលានគ្រោះថ្នាក់ បើសិនជាពួកវាឃើញពិតជាពួកវាបាញ់សម្លាប់ខ្ញុំចោលជាមិនខាន។

ដោយមិនបានគិតវែងឆ្ងាយ និងគំនិតនៅក្មេងខ្ចីផង ខ្ញុំបែរជាខឹងមីត្នោតយ៉ាងខ្លាំងទៅវិញ ព្រោះគិតថាបាននាំខ្ញុំទៅរកសេចក្តីស្លាប់។

គិតចុះគិតឡើងដោយទ្រាំពុំបាន ខ្ញុំបានយកដំបងដើមត្របែកដែលជាប់នឹងដៃវាយខ្នងវាមួយទំហឹងរហូតមានស្នាមកន្ទួលនៅនឹងខ្នងវា។ មីត្នោតមិនបានខឹងប្រលោតទេ បែរជាស្ងាត់ស្ងៀម។ មិនតែប៉ុណ្ណោះ វាបានយកអណ្តាតមកលិឍលើក្បាលរបស់ខ្ញុំទៀតផង។ ខ្ញុំឈប់វាយមីត្នោត ហើយសម្លឹងមើលមុខវា រួចក៏ប្រែជាអាណិតទៅវិញ។

ខ្ញុំអង្អែលក្បាលវាតិចៗ ហើយគិតថា នេះជាប្រផ្នូលមួយដែលនាំខ្ញុំឱ្យឃើញរណ្តៅពិឃាដ និងដឹងពីហេតុការណ៍គ្រោះថ្នាក់ជីវិតនៃគ្រួសារខ្ញុំ។ ខ្ញុំមានចិត្តអាណិតវាវិញស្ទើរស្រក់ទឹកភ្នែក។ សូម្បីតែសត្វក៏មានសភាវគតិឱ្យយើងដឹងដែរ។

កាលនោះកម្ពស់ខ្ញុំនិងកម្ពស់មីត្នោតគឺប្រហែលគ្នា ខ្ញុំយកដៃទៅអង្អែល

(តទៅលេខក្រោយ)

**ឡុង ឧទ្យសមិទ្ធ**

រូបក្របមុខ៖

ទិដ្ឋភាពកន្លែងឈ្លបដឹករណ្តៅ សម្លាប់មនុស្សនៅលើទួលស្វាំង។

(សៀវភៅ ទួលពិឃាដ/ ឡុង វង្សសមិទ្ធ)

រូបក្របក្រោយ៖

ឡុង វង្សសមិទ្ធ

(សៀវភៅ ទួលពិឃាដ/ ឡុង វង្សសមិទ្ធ)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 262, October 2021 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.